សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de droit et des sciences Èconomiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ជនល្មើសក្នុងរឿងព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

តាក់តែងឡើងដោយ

និស្សិតឈ្មោះ ៖ **កញ្ញា. ផាន់ លក្ខិណា**

**លោក. កែ បញ្ញាវិសាល**

សាស្ត្រាចារ្យណែនាំ

**លោកស្រី ចាំង ស៊ីណាត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# **លិខិតថ្លែងអំណរគុណ**

ក្រុមសិក្សាស្រាវជ្រាវយើងខ្ញុំ ទាំងពីររូបមានឈ្មោះ **ផាន់ លក្ខិណា** និង **កែ បញ្ញាវិសាល** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៨-២០២២។ យើងខ្ញុំបានសរសេរសារណាបញ្ចប់ការសិក្សា ដោយជ្រើសរើសយកប្រធានបទស្តីពី " **ជនល្មើសក្នុងរឿងព្រហ្មទណ្ឌ** "។

**យើងខ្ញុំសូមគោរពលំឱនកាយវាចាចិត្តសម្តែងនូវគារវកិច្ច និងមហាកតញ្ញូដឹងគុណ យ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ**

- លោកឪពុក **ផាន់ សុភ័ក្រ្ត** - លោកឪពុក **កែ សុខរិទ្ធ**
- **អ្នកម្តាយ** **ខៀវ សុរ៉ាវី** - **អ្នកម្តាយ** **សៅ ស៊ីថា**

កូនសូមអនុញ្ញាតសម្តែងនូវការដឹងគុណចំពោះ គុណូបការៈដ៏ធំធេងបំផុតមិនអាចកាត់ថ្លៃបាន របស់ **លោកឪពុក អ្នកម្តាយទាំងទ្វេ** ដែលលោកទាំងទ្វេបានផ្តល់កំណើតដល់រូបយើងខ្ញុំ ហើយលោកបានចំណាយពេលវេលា និងខិតខំបីបាច់ថែរក្សាតាំងពីតូចរហូតដល់ធំដឹងក្តីដោយមិនគិតពីភាពនឿយហត់។

**ឯកឧត្តមបណ្ឌិត លុយ ចន្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រួមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងលោក លោកស្រី សាស្ត្រាចារ្យទាំងអស់ ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការអប់រំបណ្តុះបណ្តាលយ៉ាងយកចិត្តទុកដាក់ និងលើកទឹកចិត្តយើងខ្ញុំនៅក្នុងការសិក្សា ដើម្បីជាគ្រឹះ និងជាស្ពានចម្លងយើងខ្ញុំឱ្យទទួលបានពុទ្ធិច្បាស់លាស់។

**លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត** ជាសាស្ត្រាចារ្យដឹកនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ ដែលបានយកចិត្តទុកដាក់ក្នុងការបង្ហាញការណែនាំ និងផ្តល់នូវយោបល់ ឬអនុសាសន៍ល្អៗដល់យើងខ្ញុំទាំងពីរក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ តាំងពីដើមរហូតដល់ចប់។

ជាទីបញ្ចប់នេះ យើងខ្ញុំទាំងពីរអ្នកសូមការអនុញ្ញាត ដើម្បីបានគោរពបន្ទន់កាយ លើកហត្ថាទាំងទ្វេប្រណម្យបួងសួង លំអោនកាយវាចាចិត្ត និងសូមប្រសិទ្ធពរជ័យ ព្រមទាំងសម្តែងនូវសេចក្តីដឹងគុណជូនចំពោះអ្នកមានគុណទាំងពីរ និងថ្នាក់ដឹកនាំនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ឱ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២

**កញ្ញា. ផាន់ លក្ខិណា លោក. កែ បញ្ញាវិសាល**

# អារម្ភកថា

នៅក្នុងសង្គមបច្ចុប្បន្ន មនុស្សខ្លះបានប្រព្រឹត្តិល្អបានធ្វើឱ្យសង្គមមានការរីកចម្រើន ចំណែកមនុស្សមួយចំនួនក៏បានបង្កឱ្យសង្គមមានភាពរឹករវដោយសារតែសកម្មភាពរបស់ពួកគេ ជាពិសេសធ្វើឱ្យសង្គមពោរពេញដោយអំពើអាក្រក់ បង្កើតបានជាសង្គមខ្វះសណ្តាប់ធ្នាប់។ នៅក្នុងទិដ្ឋភាពជារួម ដើម្បីដោះស្រាយនូវអស្ថិរភាពសង្គម ក៏ដូចជាទប់ស្កាត់នូវអំពើអាក្រក់ដែលបង្កឱ្យប្រទេសបាត់បង់សណ្តាប់ធ្នាប់នោះ ប្រទេសកម្ពុជាបានបង្កើតឱ្យមាននូវលិខិតបទដ្ឋានគតិយុត្តជាច្រើន ដើម្បីយកមកអនុវត្តក្នុងការគ្រប់គ្រងនូវសកម្មភាពទាំងឡាយណាដែលបង្កើតឱ្យមានភាពអវត្តមាននៅក្នុងសង្គម។ ជាហេតុដូច្នេះហើយ ដើម្បីបង្កើតឱ្យមានរបាំងការពារសង្គមក៏ដូចជាធ្វើយ៉ាងក្នុងការទប់ស្កាត់នូវភាពរឹករវ និងភាពល្អក់កករនៅក្នុងសង្គមពីសំណាក់ជនល្មើស ទើបអំណាចដែលដឹកនាំប្រទេសបង្កើតឱ្យមានច្បាប់ ជាពិសេសច្បាប់ព្រហ្មទណ្ឌនេះតែម្តង។ នៅក្នុងច្បាប់ព្រហ្មទណ្ឌបានកំណត់ថាហៅបុគ្គលម្នាក់ជាជនល្មើសដោយសារតែបុគ្គលនោះបានប្រព្រឹត្តនូវកំហុសដែលច្បាប់ព្រហ្មទណ្ឌបានហាមឃាត់។ ព្រោះហេតុផលថាច្បាប់ព្រហ្មទណ្ឌមានគោលបំណងដើម្បីអប់រំ កែប្រែ បង្ក្រាប បង្ការ និងធ្វើឱ្យជនល្មើសអាចវិវឌ្ឍខ្លួនទៅរស់ក្នុងសង្គមវិញបានក្នុងនាមជាមនុស្សល្អ។ ត្បិតតែថា បុគ្គលដែលបានប្រព្រឹត្តកំហុសនោះ ត្រូវបានចាត់ទុកថាជាជនល្មើសក៏ពិតមែន ប៉ុន្តែនៅក្នុងច្បាប់ ជនល្មើសក៏មានសិទ្ធិមិនឱ្យនរណាម្នាក់មកបំពានបានដែរ ជាពិសេសនៅពេលដែលជនល្មើសត្រូវបានឃាត់ខ្លួន ពួកគេក៏មានសិទ្ធិក្នុងការស្វែងរកមេធាវីដើម្បីការពារខ្លួន និងសិទ្ធិដទៃផ្សេងទៀតផងដែរ។ ផ្ទុយទៅវិញ ក្នុងច្បាប់ក៏បានកំណត់ពីការទទួលខុសត្រូវរបស់ជនល្មើស និងការមិនទទួលខុសត្រូវរបស់ជនល្មើសផងផង។ ដូច្នេះជារួមមក ដើម្បីឆ្លើយតបទៅនឹងប្រធានបទ ជនល្មើសក្នុងរឿងព្រហ្មទណ្ឌ ក៏ដូចជាដើម្បីទទួលបាននូវពុទ្ធិថ្មីៗទាក់ទងនឹងប្រធានបទនេះ និងដើម្បីឈ្វេងយល់ឱ្យកាន់តែមានភាពស៊ីជម្រៅនោះ ក្រុមយើងខ្ញុំបានធ្វើការសម្រេចចិត្តចាប់យកប្រធាននេះមកធ្វើជាសារណាបទ ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងទុកជាឯកសារសម្រាប់អ្នកសិក្សាគ្រប់ជំនាន់។

ដោយមានការតាំងចិត្តជឿជាក់យ៉ាងមុតមាំថា ការសិក្សាស្រាវជ្រាវអំពីសារណានេះ នឹងបានផ្តល់ជាប្រយោជន៍សម្រាប់អ្នកសិក្សាស្រាវជ្រាវ ជាពិសេសសម្រាប់និស្សិតចង់ដឹងអំពីជនល្មើស សិទ្ធិសេរីភាព ការទទួលខុសត្រូវ និងការមិនទទួលខុសត្រូវរបស់ជនល្មើសនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ហើយស្នាដៃនេះក៏អាចនឹងមាននូវចន្លោះខ្វះខាត ក៏ដូចជាមាននូវកំហុសខុសឆ្គងនូវពាក្យពេចន៍ អក្ខរាវិរុទ្ធ អត្ថន័យ អត្ថរស ខ្លឹមសារមិនពេញលេញ ឬប្រយោគឯណានីមួយដោយប្រការណាមួយនោះ។ យើងខ្ញុំសូមធ្វើការអភ័យទោសអំពីសំណាក់អ្នកសិក្សាគ្រប់មជ្ឈដ្ឋាន និងរង់ចាំទទួលនូវពាក្យ ក៏ដូចជាមតិរិះគន់ក្នុងន័យស្ថាបនា និងជួយផ្តល់ជាគោលគំនិត ដើម្បីធ្វើយ៉ាងណាឱ្យសារណាបទនេះ មានភាពល្អប្រសើរ និងមានសុក្រឹតភាព ជាពិសេសកែលម្អនូវចំណុចខ្វះខាតដែលកើតឡើងដោយកំហុសអចេតនារបស់ក្រុមយើងខ្ញុំជានិស្សិត។

**សូមអរគុណ**!

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ **១**

## ជំពូកទី ១
## សញ្ញាណទូទៅនៃជនល្មើស

១.១. និយមន័យ ........ **៤**

១.១.១. ជនសង្ស័យ ........ **៤**

១.១.២. ជនល្មើស ........ **៤**

១.១.៣. ជនត្រូវចោទ ........ **៤**

១.១.៤. ជនជាប់ចោទ ........ **៤**

១.១.៥. ពិរុទ្ធជន ........ **៤**

១.១.៦. ទណ្ឌិត ........ **៥**

២.១. បុគ្គលដែលទទួលខុសត្រូវព្រហ្មទណ្ឌ ........ **៥**

២.១.១. ការចូលរួមប្រព្រឹត្តបទល្មើសដោយផ្ទាល់ ........ **៥**

២.១.១.១. ចារី ........ **៥**

២.១.១.២. សហចារី ........ **៦**

២.២.១. ការចូលរួមប្រព្រឹត្តបទល្មើសដោយប្រយោល ........ **៦**

២.២.១.១. ការផ្តើមគំនិត និង ការសមគំនិត ........ **៦**

២.២.១.២. លក្ខខណ្ឌនៃការផ្តើមគំនិត និង ការសមគំនិត ........ **៧**

២.២.៣. ធាតុផ្សំសត្យានុម័តនៃការផ្តើមគំនិត និង ការសមគំនិត ........ **៩**

២.២.៣.១. ធាតុផ្សំសត្យានុម័តនៃការផ្តើមគំនិត ........ **៩**

២.២.៣.២. ធាតុផ្សំសត្យានុម័តនៃការសមគំនិត ........ **១១**

២.២.៣.៣. ធាតុផ្សំអត្តនោម័តនៃការផ្តើមគំនិត និងការសមគំនិត ........ **១៤**

២.៤. ការដាក់ទណ្ឌកម្មលើការផ្តើមគំនិត និង ការសមគំនិត ........ **១៦**

## ជំពូកទី ២
## សិទ្ធរបស់ជនល្មើសក្នុងពេលឃាត់ខ្លួន


៣.១. សិទ្ធិដឹងពីមូលហេតុចាប់ ឬឃាត់ខ្លួន ........ ១៨

៣.២. សិទ្ធិមានជំនួយមេធាវី ........ ១៨

៣.៣. សិទ្ធិមិនត្រូវបានឃាត់ខ្លួនហួសរយៈពេលកំណត់ ........ ១៨

៣.៤. សិទ្ធិមានជំនួយពីគ្រូពេទ្យ ........ ១៩

៣.៥. អនីតិជនដែលត្រូវបានឃាត់ខ្លួន ........ ១៩

៣.៦. សិទ្ធិរក្សាភាពស្ងៀមស្ងាត់ ........ ១៩

៣.៧. សិទ្ធិមិនឆ្លើយសារភាព ........ ១៩

៣.៨. សិទ្ធិត្រូវបាននាំខ្លួនទៅតុលាការ ........ ១៩

៣.៩. សិទ្ធិប្ដឹងនឹងការបដិសេធផ្សេងៗរបស់មន្ត្រីនគរបាលយុត្តិធម៌ ........ ២០


## ជំពូកទី ៣
## ប្រភេទជនល្មើសក្នុងរឿងព្រហ្មទណ្ឌ


៤.១. និយមន័យ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ........ ២១

    ៤.១.១. លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ........ ២៤

        ៤.១.១.១. អត្ថិភាពនៃច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត ........ ២០

        ៤.១.១.២. ការប្រព្រឹត្តដើម្បីប្រយោជន៍ដល់នីតិបុគ្គល ........ ២០

    ៤.២.១. ការដាក់ទណ្ឌកម្មលើនីតិបុគ្គល ........ ២៦

    ៤.៣.១. ដំណើរការនីតិវិធីប្រឆាំងនឹងនីតិបុគ្គល ........ ២៨

៥.១. និយមន័យ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ........ ២០

    ៥.១.១. វិធានការអនុវត្តចំពោះអនីតិជនក្រៅពីទោស ........ ២៩

    ៥.២.១. ទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជន ........ ៣៣

**សេចក្ដីសន្និដ្ឋាន** ........ ៣៦

**អនុសាសន៍** ........ ៣៨

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហា

ជាទូទៅ ការរស់នៅប្រចាំថ្ងៃរបស់មនុស្សមិនអាចកាត់ផ្ដាច់ដោយរស់នៅតែម្នាក់ឯងបានទេ ពួកគេតែងតែមានការប្រាស្រ័យទាក់ទងគ្នាមិនថានៅក្នុងស្ថានភាពបែបណានោះទេ។ នៅក្នុងមិត្តភាពរមែងទទួលបានផ្លែផ្កាដែលជាប្រយោជន៍រវាងគ្នានិងគ្នា ជាពិសេសពួកគេអាចជួយទុក្ខធុរៈពេលមានបញ្ហា ផ្ទុយទៅវិញនៅក្នុងវង្វង់នៃការទំនាក់ទំនងគ្នាមួយចំនួនបានបង្កជាបញ្ហាជាច្រើន ដែលកើតឡើងអំពីការកេងប្រវ័ញ្ច ការក្បត់សន្យា ឬការមិនគោរពនូវគោលការណ៍សុចរិតនិងភាពស្មោះត្រង់ជាដើម ហើយវាបានបង្កើតឡើងនូវវិវាទរវាងភាគីទាំងអស់។

ជាក់ស្ដែងនៅក្នុងទំនាក់ទំនងនៃការរស់នៅរបស់មនុស្សគ្រប់រូប គឺមានគ្រប់រស់ជាតិទាំងសេចក្ដីសុខសុភមង្គល ភាពលំបាកវេទនា ទុក្ខសោកគ្រប់បែបយ៉ាង។ ស្ថានភាពទាំងអស់នេះពេលខ្លះកើតឡើងដោយធម្មជាតិដោយឯកឯង ហើយពេលខ្លះទៀតក៏កើតឡើងដោយសារសកម្មភាពរបស់មនុស្ស។ ដោយសារតែសង្គមមានការប្រកួតប្រជែង ដណ្ដើមផលប្រយោជន៍គ្នាទៅវិញទៅមក ដើម្បីបំពេញសេចក្ដីត្រូវការផ្ទាល់ខ្លួនគ្មានព្រំដែនឡើយ ដែលកត្តានេះបានធ្វើឲ្យមនុស្សហ៊ានប្រព្រឹត្តនូវអំពើដែលប្រាសចាកសីលធម៌ ហើយសង្គមនេះមិនទទួលស្គាល់។

អំពើទាំងអស់នេះមិនត្រឹមតែធ្វើឲ្យមានការប៉ះពាល់ដល់មនុស្សគ្រប់រូបនោះទេ ប៉ុន្តែវាបានបង្កផលប៉ះពាល់ដល់សង្គមជាតិទៀតផង។ អំពើដែលឥតសណ្ដាប់ធ្នាប់ គ្មានសីលធម៌ទាំងនេះ អាចស្ដែងចេញជាបទល្មើសជាច្រើន ដូចជាការកាប់សម្លាប់ រំលោភ លួច ឆក់ ប្លន់ អំពើហឹង្សា និងអំពើផ្សេងទៀតដែលសង្គមបានថ្កោលទោស។ ដោយសារអំពើទាំងនោះហើយ សង្គមចាំបាច់ត្រូវតែបង្កើតឡើងនូវមធ្យោបាយក្នុងការបង្ការ បង្ក្រាប និងទប់ស្កាត់នៅអំពើទាំងនោះដោយមិនឲ្យកើតមានឡើង។

នៅពេលដែលមានសកម្មភាពទុច្ចរិតបង្កឱ្យសង្គមមានភាពចលាចល ប្រាកដណាស់វាកើតឡើងដោយសារតែបុគ្គលជាអ្នកបង្កឡើយ ហើយបុគ្គលដែលបានបង្កនោះត្រូវបានកំណត់ដោយច្បាប់អាចជាជនសង្ស័យ ជនល្មើស ឬក៏អ្វីផ្សេងទៀត។ នៅក្នុងច្បាប់ព្រហ្មទណ្ឌ មានកំណត់យ៉ាងច្បាស់លាស់អំពីជនល្មើស សិទ្ធិដែលជនល្មើសត្រូវតែទទួលបាន ការទទួលខុសត្រូវរបស់ជនល្មើស និងការមិនទទួលខុសត្រូវជាដើមនៅក្នុងរឿងព្រហ្មទណ្ឌ។

## ២. ចំណោទបញ្ហា

នៅក្នុងសង្គមបច្ចុប្បន្ន មនុស្សទាំងឡាយមានការយល់ដឹងប្រាស្រ័យទាក់គ្នាក្នុងគោលដៅផ្សេងៗ ដូចជាការទាក់ទង ឬធ្វើជំនួញពាណិជ្ជកម្មជាដើម ដែលនៅក្នុងនោះក៏បានបង្កើតឱ្យមានជម្លោះ ឬការមិនចុះសម្រុងគ្នាដោយសារតែការបំពានកាតព្វកិច្ច ការបង្កើតនូវបទល្មើស ការមិនបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួន ដែលជាហេតុធ្វើឱ្យមានរឿងក្ដីក្ដាំទាស់ទែងគ្នារវាងគ្នានិងគ្នា រហូតឈានដល់ការប្ដឹងផ្ដល់តាមផ្លូវតុលាការផង។ ទន្ទឹមនឹង

នោះ យើងឃើញថា នៅក្នុងច្បាប់ជាច្រើនបានកំណត់នូវឋានៈនៃបុគ្គលដែលបានប្រព្រឹត្តនូវបទល្មើសអាចថាជាជនសង្ស័យ ជនជាប់ចោទ ជនត្រូវចោទ ឬជនល្មើស ប៉ុន្តែនៅក្នុងទីនេះយើងផ្តោតសំខាន់លើតែជនល្មើសនៅក្នុងរឿងក្តីព្រហ្មទណ្ឌតែប៉ុណ្ណោះ។

**តើនៅក្នុងច្បាប់ត្រូវបានកំណត់ថា បុគ្គលណាម្នាក់ជាជនល្មើសដោយផ្អែកតាមលក្ខណៈបែបណា? តើជនល្មើសទទួលបានសិទ្ធិអ្វីខ្លះ អំឡុងពេលឃាត់ខ្លួន? តើជនល្មើសទទួលខុសត្រូវនូវទង្វើរបស់ខ្លួនបែបណា? ហើយតើមូលហេតុអ្វីបានជាជនល្មើសមិនទទួលខុសត្រូវព្រហ្មទណ្ឌ?**

## ៣. គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងវង្វង់នៃការសិក្សាស្រាវជ្រាវចំពោះប្រធានបទមួយនេះ គឺត្រូវបានធ្វើការសិក្សាយ៉ាងសំខាន់ទៅលើជនល្មើសក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលនឹងធ្វើការបកស្រាយទាំងស្រុងការកំណត់នូវឋានៈជាជនល្មើស សិទ្ធិដែលជនល្មើសទទួលបានអំឡុងពេលឃុំខ្លួន ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនល្មើស និងមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ។ ជាពិសេសការសិក្សាស្រាវជ្រាវនេះ មានគោលបំណងបង្ហាញឱ្យឃើញពីស្ថានភាពមួយ នៅពេលដែលមានជនណាម្នាក់បង្កឱ្យមានព្យសនកម្ម ហើយត្រូវបានច្បាប់កំណត់នូវឋានៈជាជនល្មើសក្នុងរឿងក្តីព្រហ្មទណ្ឌ។

ម្យ៉ាងវិញទៀត គោលគំនិតដ៏សំខាន់ផ្សេងទៀតនោះ ក្រុមនឹងធ្វើការបង្ហាញពីគោលការណ៍មួយចំនួននៅពេលដែលជនល្មើសបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែជនល្មើសនៅតែទទួលបានសិទ្ធិក្នុងការការពារខ្លួនដែលច្បាប់បានផ្តល់ឱ្យដើម្បីជាការទប់ស្កាត់ពីការបង្ខិតបង្ខំផ្សេងៗ។ មិនតែប៉ុណ្ណោះ ក៏បើកបង្ហាញពីការទទួលខុសត្រូវនូវសកម្មភាពរបស់ខ្លួនតាមច្បាប់កំណត់ ដោយគ្មាននរណាម្នាក់អាចមកទទួលទោសជំនួសបាននោះឡើយ។ ព្រមទាំងលើកយកពីមូលហេតុផ្សេងៗដែលនាំឱ្យជនល្មើសមិនទទួលខុសត្រូវនូវទោសព្រហ្មទណ្ឌ។

សរុបមកទាំងនេះ គឺជាគោលបំណងដែលនឹងលើកយកមកធ្វើការសិក្សាស្រាវជ្រាវប្រកបដោយភាពស៊ីជម្រៅ និងសុក្រឹតភាព។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការពាំនាំយកនូវប្រធានបទទាក់ទងនឹងជនល្មើសក្នុងរឿងក្តីព្រហ្មទណ្ឌ ដោយឃើញពីភាពមានសារៈសំខាន់នៃការកំណត់នូវជនណាម្នាក់ជាជនល្មើសនៅក្នុងរឿងក្តីព្រហ្មទណ្ឌ មិនតែប៉ុណ្ណោះក៏បានលើកយកអំពីសិទ្ធិសេរីភាពរបស់ជនល្មើសអំឡុងពេលដែលបានឃាត់ខ្លួនមានដូចជា សិទ្ធិទទួលបានការការពារពីមេធាវី និងសិទ្ធិសំខាន់ផ្សេងៗដែលបានផ្តល់ឱ្យជនល្មើសដោយច្បាប់ជាតិនិងច្បាប់អន្តរជាតិ។ បន្ថែមពីនេះទៀត នៅក្នុងគោលការណ៍ច្បាប់ នៅពេលដែលតុលាការរកឃើញថាជនណាម្នាក់មានទោស ហើយជនល្មើសនោះជាអ្នកប្រព្រឹត្ត ដូចនេះជនល្មើលនោះជាអ្នកទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនអាចជារូបវន្តបុគ្គល និងនីតិបុគ្គល។

ម្យ៉ាងទៀតក៏បង្ហាញពីមូលហេតុដែលបុគ្គលជាជនល្មើសមិនទទួលខុសត្រូវព្រហ្មទណ្ឌដូចជាយុត្តិកម្មនៃបទល្មើសព្រហ្មទណ្ឌ និងបញ្ហាផ្សេងៗ។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

ក្នុងនាមជានិស្សិត ដែលជាអ្នកសិក្សាស្រាវជ្រាវនូវឯកសារយកមកធ្វើជាគោល និងធ្វើការបកស្រាយនៅក្នុងសារណាបញ្ចប់ការសិក្សានេះ ក្រុមយើងខ្ញុំបានបានធ្វើការសិក្សា និងដកស្រង់នូវអត្ថន័យខ្លឹមសារដែលជាប់ពាក់ព័ន្ធចេញពីឯកសាផ្សេងៗ ដែលមានមូលដ្ឋានគ្រឹះប្រកបដោយសុក្រឹតភាពរួមមាន ច្បាប់ វិធាន សេចក្តីសម្រេចលិខិតបទដ្ឋានគតិយុត្ត និងសៀវភៅផ្សេងៗ ដែលមានការជាប់ពាក់ព័ន្ធទៅនឹងជនល្មើសក្នុងរឿងក្តីព្រហ្មទណ្ឌ។ លើសពីនេះទៀត វាក៏បានស្តែងចេញឡើងនូវភាពជាដៃគូក្នុងការខិតខំសហការគ្នាយ៉ាងខ្លាំងក្នុងការសរសេរ និងស្រាវជ្រាវពីមជ្ឈដ្ឋានឯកសារនានាដែលពាក់ព័ន្ធ និងឆ្លុះបញ្ចាំងអំពីភាពសាមគ្គីចំពោះការសិក្សាស្រាវជ្រាវក្នុងការសរសេរសារណាបទនេះ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងទំហំនៃការសរសេរសារណានេះ ដើម្បីឱ្យមានភាពងាយស្រួល និងច្បាស់លាស់អំពីជនល្មើសនៅក្នុងរឿងព្រហ្មទណ្ឌ យើងខ្ញុំនឹងធ្វើការបែងចែកជារចនាសម្ព័ន្ធដូចជា៖

**ជំពូកទី១ ៖** ស្តីពីជនល្មើសក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលនឹងបកស្រាយពីសញ្ញាណទូទៅនៃជនល្មើស បុគ្គលដែលទទួលខុសត្រូវព្រហ្មទណ្ឌនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។

**ជំពូកទី២ ៖** ស្តីអំពីសិទ្ធិរបស់ជនល្មើសនៅពេលឃាត់ខ្លួន ដែលនឹងត្រូវធ្វើការបកស្រាយទៅលើសិទ្ធិមួយចំនួនដើម្បីការពារខ្លួនពីការបំពាន និងមានភាពចាំបាច់ក្នុងអំឡុងពេលឃាត់ខ្លួន។

**ជំពូកទី៣ ៖** ប្រភេទជនល្មើសក្នុងរឿងព្រហ្មទណ្ឌ ដែលនឹងត្រូវធ្វើការបកស្រាយអំពីជនល្មើសដែលជានីតិបុគ្គល និងជនល្មើសដែលជាអនីតិជន ព្រមទាំងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះជនល្មើសទាំងពីរនេះផងដែរ។

# ជំពូកទី ១

# សញ្ញាណទូទៅនៃជនល្មើស

# ជំពូកទី ១

# សញ្ញាណទូទៅនៃជនល្មើស

## ១.១. និយមន័យ

### ១.១.១. ជនសង្ស័យ

ជនសង្ស័យ សំដៅលើជនដែលត្រូវបានគេប្តឹងនៅដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬដំណាក់កាលស៊ើបអង្កេតរបស់ព្រះរាជអាជ្ញា។ **ឧទាហរណ៍ ៖** បុរសម្នាក់បានសម្លាប់ប្រពន្ធរបស់ខ្លួនបណ្តាលឱ្យបាត់បង់ជីវិត ហើយត្រូវបានសមត្ថកិច្ចស្រាវជ្រាវចុះឃាត់ខ្លួនបុរសជាប្តីនៅក្នុងបន្ទប់ជួលមួយកន្លែង។

### ១.១.២. ជនល្មើស

ជនល្មើស គឺជនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ។ ពាក្យ " **ជនល្មើស** " ត្រូវបានប្រើប្រាស់ជាទូទៅ សម្គាល់ជនដែលបានប្រព្រឹត្តបទល្មើស ដោយមិនផ្តោតជាពិសេសទៅលើដំណាក់កាលណាមួយនៃនីតិវិធីទេ។ **ឧទាហរណ៍៖** ឈ្មោះ **ក.** បានលួចទ្រព្យសម្បត្តិអ្នកដទៃ ដូច្នេះ ឈ្មោះ **ក.** គឺជាជនល្មើស។[1]

### ១.១.៣. ជនត្រូវចោទ

ជាបុគ្គលដែលត្រូវបានចោទប្រកាន់ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។នៅក្នុងមាត្រា១៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា "នៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន។ **ឧទាហរណ៍ ៖** ឈ្មោះ **ក.** ត្រូវបានព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ពី **បទលួច** ហើយនិងបញ្ជូនទៅចៅក្រមស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ។ នៅក្នុងករណីបែបនេះ ឈ្មោះ **ក.** គឺជាជនត្រូវចោទ។

### ១.១.៤. ជនជាប់ចោទ

ជាបុគ្គលដែលត្រូវបានបញ្ជូនទៅចំពោះមុខតុលាការ ដើម្បីជំនុំជម្រះ តាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ឬក៏ដីកាសន្និដ្ឋានបញ្ជូនទៅតុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា ឬមួយក៏តាមកំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាម ដែលធ្វើឡើងដោយព្រះរាជអាជ្ញា **(មាត្រា ២៩១ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)** ។ **ឧទាហរណ៍ ៖** ព្រះរាជអាជ្ញាបានសម្រេចចេញជាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយធ្វើការចោទប្រកាន់លើឈ្មោះ **ក.** ហើយបានបញ្ជូនសំណុំរឿងមកចៅក្រមស៊ើបសួរដើម្បីចាត់ការ។ បន្ទាប់ពីបានធ្វើការស៊ើបសួរចប់សព្វគ្រប់រួចហើយ ចៅក្រមស៊ើបសួរបានសម្រេចចេញដីកាបញ្ជូនសំណុំរឿងរបស់ឈ្មោះ **ក.** ទៅជំនុំជម្រះក្រោយពីទទួលបានដីកាសន្និដ្ឋានស្ថាពរពីព្រះរាជអាជ្ញា។នៅក្នុងករណីដែលដីកាខាងលើនេះផុតរយៈពេលនៃការប្តឹងឧទ្ធរណ៍ឈ្មោះ **ក.** នឹងក្លាយទៅជាជនជាប់ចោទ។[2]

---

[1] នីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ, ទំព័រទី ៦៩៩

[2] នីតិព្រហ្មទណ្ឌទូទៅ ដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រី ចាំង ស៊ីណាត ឆ្នាំ២០២២, ទំព័រទី ៦៩៧

**១.១.៥. ពិរុទ្ធជន**

គឺជាបុគ្គលដែលត្រូវបានរកឃើញថាមានកំហុស ឬជាបុគ្គលដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោស ដោយសេចក្តីសម្រេចនោះមិនទាន់បានចូលជាស្ថាពរនៅឡើយ ។ ក្នុងមាត្រា៣៦៥នៃក្រមនីតិវិធីព្រហ្មទណ្ឌចែង ថា "**ពិរុទ្ធជនអាចធ្វើបណ្តឹងទាស់នឹងសាលក្រមដែលប្រកាសដោយកំបាំងមុខខ្លួនបាន**"។ **ឧទាហរណ៍** ៖ នៅថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១៩ តុលាការបានប្រកាសសាលក្រមសម្រេចផ្តន្ទាទោសឈ្មោះ **ក.** ឱ្យជាប់ពន្ធនាគាររយៈ ពេល ១ឆ្នាំ ពី**បទលួច**។ ដូច្នេះក្រោយពីការប្រកាសសាលក្រមផ្តន្ទាទោសរួចហើយ ឈ្មោះ **ក.** ត្រូវបានគេចាត់ទុក ថាជាពិរុទ្ធជន ។[3]

**១.១.៦. ទណ្ឌិត**

គឺជាជនដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោស ហើយសេចក្តីសម្រេចនេះចូលជាស្ថាពរ។ ក្នុងមាត្រា ៥០២នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា "ទណ្ឌិតដែលបានអនុវត្តទោសរបស់ខ្លួនរួចហើយ ត្រូវដោះលែងនៅក្នុង ចន្លោះពីម៉ោង៦ព្រឹកដល់ម៉ោង១៨ល្ងាច" ។ **ឧទាហរណ៍** ៖ បុរស **ក.** ត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ ពន្ធនាគាររយៈពេល ១ឆ្នាំ ពី**បទលួច** តាមសាលក្រមចំពោះមុខ។ បន្ទាប់ពីរយៈពេល **១ខែ** បានកន្លងផុតទៅចាប់ ពីថ្ងៃប្រកាសសាលក្រម ប្រសិនបើឈ្មោះ **ក.** មិនបានប្តឹងឧទ្ធរណ៍ទេ សាលក្រមដែលបានសម្រេចផ្តន្ទាទោស ឈ្មោះ **ក.** នឹងចូលជាស្ថាពរ។ នៅពេលនោះ ឈ្មោះ **ក.** ត្រូវចាត់ទុកថាជា **ទណ្ឌិត** ហៅម្យ៉ាងទៀតថា **ជនជាប់ទោស**។[4]

## ២.១. បុគ្គលដែលទទួលខុសត្រូវព្រហ្មទណ្ឌ

យោងតាមក្រមព្រហ្មទណ្ឌ បុគ្គលដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌមាន ៖ **ចារី សហចារី អ្នកផ្តើមគំនិត និងអ្នកសមគំនិត**។

### ២.១.១. ការចូលរួមប្រព្រឹត្តបទល្មើសដោយផ្ទាល់

#### ២.១.១.១. ចារី

**ចារី** គឺជាមនុស្សទាំងឡាយដែលអាចត្រូវដាក់ទោសដោយសារការប្រព្រឹត្តបទល្មើសមួយ មានតែអំពើ របស់ចារីទេទើបមានលក្ខណៈធាតុផ្សំបទល្មើសគ្រប់គ្រាន់ ឬយោងតាមមាត្រា២៥ នៃក្រមព្រហ្មទណ្ឌ ត្រូវចាត់ ទុកជាចារី ចំពោះបុគ្គលដែលបានប្រព្រឹត្តបទល្មើស ដែលត្រូវបានចោទប្រកាន់។ ម្យ៉ាងវិញទៀតអ្នកដែលបានប៉ុន ប៉ងប្រព្រឹត្តបទល្មើស ជាបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកចំពោះបទមជ្ឈិម ក៏ត្រូវចាត់ទុកថាជាចារីដែរ។ **ឧទាហរណ៍** ៖ ឈ្មោះ **ក.** បានសម្លាប់ឈ្មោះ **ខ.** ដោយសារមានគំនុំក្នុងរបររកស៊ី។ ដូច្នេះ **ក.** គឺជាចារី។

[3] នីតិព្រហ្មទណ្ឌទូទៅ ដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រី ចាំង ស៊ីណាត ឆ្នាំ២០២២, ទំព័រទី ៧៣៨

[4] នីតិព្រហ្មទណ្ឌទូទៅ ដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រី ចាំង ស៊ីណាត ឆ្នាំ២០២២, ទំព័រទី ៧០៤

**២.១.១.២. សហចារី**

ស្របតាមន័យនៃមាត្រា២៦ នៃក្រមព្រហ្មទណ្ឌ ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់។ត្រូវចាត់ទុកជាសហចារី ផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្ត បទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក។ **ឧទាហរណ៍ ៖** ឈ្មោះ **ក.** ឈ្មោះ **ខ.** និងឈ្មោះ **គ.** បានរួមគ្នាវាយឈ្មោះ **ឃ.** ដោយឈ្មោះ **ក.** ធាក់មួយជើង ឈ្មោះ **ខ.** វាយមួយដៃ និងឈ្មោះ **គ.** ច្រានឱ្យដួល។ ក្នុងសកម្មភាពបែបនេះ បានន័យថា ឈ្មោះ **ក.** ឈ្មោះ **ខ.** និងឈ្មោះ **គ.** គឺជាសហចារី នៃបទល្មើស។

**២.២.១. ការចូលរួមប្រព្រឹត្តបទល្មើសដោយប្រយោល**

**២.២.១.១. ការផ្ដើមគំនិត និង ការសមគំនិត**

ចំពោះជនទាំងឡាយណាដែលបានចូលរួមប្រព្រឹត្តបទល្មើស ដោយមិនផ្ទាល់ ឬខ្លះៗតែប៉ុណ្ណោះ គេអាចចាត់ទុកជាអ្នកផ្ដើមគំនិត ឬអ្នកសមគំនិតទៅវិញ ពីព្រោះថានៅពុំទាន់ឃើញមានធាតុផ្សំសត្យានុម័ត និងធាតុផ្សំអត្តនោម័តដែល បញ្ជាក់ថាជនទាំងនោះជាសហចារីនៅឡើយ ។

ខុសប្លែកពីច្បាប់ព្រហ្មទណ្ឌអន្តរកាល ក្រមព្រហ្មទណ្ឌបានធ្វើការបែងចែក ដាច់ស្រឡះរវាងការផ្ដើមគំនិត និងការសមគំនិត។

ការផ្ដើមគំនិតត្រូវបានបញ្ញត្តិនៅមាត្រា ២៨ នៃក្រមព្រហ្មទណ្ឌដែលមាន ខ្លឹមសារដូចខាងក្រោម ៖

ត្រូវចាត់ទុកជាអ្នកផ្ដើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែល ៖

១-ជំរុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ តាមការណែនាំ ឬការបញ្ជា។

២-បង្កឱ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្ដល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។

អ្នកផ្ដើមគំនិតនឹងអាចត្រូវផ្ដន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង។

អ្នកផ្ដើមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្ដន្ទាទោសដូចគ្នានឹងចារីដែរ។

ការសមគំនិតត្រូវបានបញ្ញត្តិនៅមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌថា៖

ត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គល ដែលជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះដោយផ្ដល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។

អ្នកសមគំនិតនឹងអាចត្រូវផ្ដន្ទាទោសបាន លុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវបានសម្រេច ឬបានប៉ុនប៉ង។

អ្នកសមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្ដន្ទាទោសដូចគ្នានឹងចារីដែរ។

បទប្បញ្ញត្តិខាងលើនេះ បានចែងយ៉ាងជាក់លាក់ពីលក្ខខណ្ឌនៃការផ្តើមគំនិត និងការសមគំនិត ព្រមទាំងទណ្ឌកម្មសម្រាប់ដាក់ទៅលើអំពើទាំង នេះទៀតផង។

**២.២.១.២. លក្ខខណ្ឌនៃការផ្តើមគំនិត និង ការសមគំនិត**

តាមនិយមន័យខាងលើ លក្ខខណ្ឌនៃការផ្តើមគំនិត និង ការសមគំនិត មានបីយ៉ាងគឺ អំពើចម្បងមានទោស ត្រូវមានធាតុផ្សំសត្យានុម័តនៃការផ្តើមគំនិត និង ការសមគំនិត និងត្រូវមានធាតុផ្សំអត្តនោម័តនៃការផ្តើមគំនិត និងការសមគំនិត។

២.១.១. អំពើចម្បងមានទោស

មាត្រា ២៨ កថាខណ្ឌទី ២ និងមាត្រា ២៩ កថាខណ្ឌទី ២ បានកំណត់នូវលក្ខខណ្ឌនៃការផ្តើមគំនិត និងការសមគំនិតដែលអាចត្រូវផ្តន្ទាទោសបាន លុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង។

ដូច្នេះ ដើម្បីឱ្យការផ្តើមគំនិត និងការសមគំនិតអាចទទួលការផ្តន្ទាទោសបាន លុះត្រាតែអំពើចម្បងជាបទល្មើស ទោះបីជាបានសម្រេចផល ឬត្រឹមតែជាការប៉ុនប៉ងក៏ដោយ។ ដូចនេះ ការផ្តើមគំនិត និងការសមគំនិតឱ្យប្រព្រឹត្តអំពើដែលច្បាប់ពុំបានចាត់ទុកជាបទល្មើស គឺពុំមានទោសទេ។

**ឧទាហរណ៍ ៖**

-ការញុះញង់ឱ្យអ្នកដទៃធ្វើអត្តឃាត គឺពុំអាចត្រូវផ្តន្ទាទោសទេ ពីព្រោះថា អត្តឃាតមិនមែនជាបទល្មើសព្រហ្មទណ្ឌឡើយ តាមច្បាប់របស់ប្រទេសកម្ពុជា នាពេលបច្ចុប្បន្ននេះ។

-លោក អេ បានបញ្ជាឱ្យលោក ក. ទៅសម្លាប់លោក ខ. តែឈ្មោះ ក. មិនបានទៅសម្លាប់លោក ខ. តាមការបញ្ជាទេ ។ ក្នុងករណីដូច្នេះ អំពើរបស់លោក អេ មិនត្រូវមានទោសក្នុងរឿងផ្តើមគំនិតទេ ពីព្រោះថា អំពើចម្បងមិនបានកើត ឡើងផង ប៉ុន្តែអំពើរបស់លោក អេ អាចមានទោសពីបទល្មើសផ្សេងទៀតបាន។

ម្យ៉ាងទៀត ច្បាប់ព្រហ្មទណ្ឌអាចកំណត់ថា ការញុះញង់ឱ្យជនណាម្នាក់ទៅប្រព្រឹត្តអំពើអ្វីមួយដែលពុំមែនជាបទល្មើស ឬក៏ការសម្រួលឱ្យជនណាម្នាក់ធ្វើអ្វីមួយ គឺជាបទល្មើសដាច់ដោយឡែកបាន ។

**ឧទាហរណ៍៖**

-មាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌផ្តន្ទាទោស អំពើញុះញង់ដោយផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬប្រព្រឹត្តអំពើបង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម ដោយដាក់ពន្ធនាគារពី ៦ខែ ទៅ ២ឆ្នាំ និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៤លានរៀល ប្រសិនបើការញុះញង់នេះគ្មានប្រសិទ្ធភាព។ ការញុះញង់ឱ្យប្រព្រឹត្តបទល្មើសនេះមិនមែនជាការផ្តើមគំនិតដែលត្រូវទទួលការផ្តន្ទាទោសទេ ព្រោះថាការញុះញង់នេះពុំមានប្រសិទ្ធភាព មានន័យថា ពុំមានជនណាម្នាក់បានប្រព្រឹត្តបទឧក្រិដ្ឋតាមការញុះញង់នេះឡើយ។ ប៉ុន្តែអំពើបែបនេះ ត្រូវបានមាត្រា នៃក្រមព្រហ្មទណ្ឌ ចាត់ទុកជាបទល្មើសដោយឡែកមួយផ្សេងទៀត។

-តាមមាត្រា ៤៩៦ នៃក្រមព្រហ្មទណ្ឌផ្តន្ទាទោស បទញុះញង់ឱ្យ រើសអើងដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២លានរៀល ៦លានរៀល។

- មាត្រា ៤៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនផ្តន្ទាទោសជនដែលសម្រួលឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៥ឆ្នាំ និងអាចត្រូវពិន័យជាប្រាក់ពី ២លានរៀល ទៅ ១០លានរៀល ។

សូមធ្វើការកត់សម្គាល់ថា អំពើចម្បងនៅក្នុងន័យនេះសំដៅតែទៅលើ អំពើដែលបង្កើតជាបទឧក្រិដ្ឋ ឬបទមជ្ឈិមប៉ុណ្ណោះ។ ដោយឡែក ប្រសិនបើអំពើ ចម្បងជាបទលហុវិញ មាត្រា ២៨ និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌពុំបានចែងពី ការដាក់ទោសចំពោះអ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទលហុឡើយ។ ហេតុដូចនេះ គេអាចសន្និដ្ឋានបានថា ប្រសិនបើមានការផ្តើមគំនិត ឬមានការសមគំនិតដើម្បីឱ្យប្រព្រឹត្តបទលហុណាមួយ បុគ្គលដែលផ្តើមគំនិត ឬជួយសម្រួលឱ្យបទលហុកើតមានឡើង គឺពុំត្រូវទទួលរងនូវការផ្តន្ទាទោសទេ។

**ឧទាហរណ៍៖**

-ការញុះញង់ក្នុងបទហិង្សាស្រាល (មាត្រា ២២៨ នៃក្រមព្រហ្មទណ្ឌ)។

-ការបញ្ជាឱ្យមានការជេរប្រមាថអ្នកដទៃជាសាធារណៈ ( មាត្រា ៣០ នៃក្រមព្រហ្មទណ្ឌ)។

-ការញុះញង់អ្នកដទៃឱ្យប្រព្រឹត្តបទធ្វើឱ្យមានការខូចខាតស្រាល ( មាត្រា ៤១៨ នៃក្រមព្រហ្មទណ្ឌ) ។

មួយវិញទៀត នៅក្នុងករណីដែលបទល្មើសកើតឡើងដោយអចេតនា ពោលគឺកើតចេញពីការធ្វេសប្រហែស ឬការខ្ជីខ្ជា ការផ្តើមគំនិត ឬការសមគំនិត ក្នុងបទល្មើសនេះពិតជាពិបាកនឹងកើតឡើងណាស់ ក៏ប៉ុន្តែជាក់ស្តែងយុត្តិសាស្ត្រ នៃតុលាការប្រទេសបារាំងបានគូសបញ្ជាក់ថា ការផ្តើមគំនិត ឬការសមគំនិតក៏អាចកើតមានដែរ ទោះបីជាអំពើចម្បងជាបទល្មើសអចេតនាក៏ដោយ។

**ឧទាហរណ៍ ៖**

ការជំរុញឱ្យអ្នកបើកបររថយន្តកុំឈប់ នៅពេលភ្លើងស្តុបពណ៌ក្រហម ដែលជាមូលហេតុបណ្តាលឱ្យបង្កជាគ្រោះថ្នាក់ចរាចរណ៍កើតឡើង។

ដោយហេតុថា ការផ្តើមគំនិត និងការសមគំនិតត្រូវដាក់ទោសដោយ ផ្អែកទៅលើការផ្តន្ទាទោសលើអំពើចម្បង ហេតុដូច្នេះ ប្រសិនបើអំពើចម្បងបែរ ជាមិនត្រូវបានផ្តន្ទាទោស ដោយសារមូលហេតុណាមួយក៏ដោយ ក៏អំពើផ្តើមគំនិត និងអំពើសមគំនិតដើម្បីឱ្យអំពើចម្បងនោះកើតឡើង មិនត្រូវទទួលរងនូវការផ្តន្ទាទោសតាមផ្លូវច្បាប់ទេ។

**ឧទាហរណ៍ ៖**

-នៅពេលដែលឃើញបុរសជាប្តីម្នាក់ កំពុងតែវាយប្រពន្ធរបស់គាត់នៅតាមដងផ្លូវសាធារណៈ អ្នកជិត

ខាងម្នាក់ក៏បានយកដំបងមួយហុចទៅឱ្យនារីជាប្រពន្ធដើម្បីការពារខ្លួន។ នារីជាប្រពន្ធបានយកដំបងនោះទៅវាយទប់ទល់ជាមួយបុរសជាប្តី ហើយបានបណ្តាលឱ្យបុរសជាប្តីរងរបួសស្រាលត្រង់ជើង។ អំពើរបស់អ្នកជិតខាង គឺជាការផ្តល់ជំនួយឱ្យនារីជាប្រពន្ធប្រព្រឹត្តបទល្មើសទៅលើបុរសជាប្តី ប៉ុន្តែអំពើរបស់នារីជាប្រពន្ធគឺជាការការពារស្របច្បាប់ ដែលមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ ហេតុដូច្នេះ អំពើចម្បង (អំពើរបស់នារីជាប្រពន្ធ) មិនត្រូវផ្តន្ទាទោសឡើយ ដោយសារតែអំពើនោះជាការការពារស្របច្បាប់។ ហេតុនេះ អ្នកជិតខាងដែលបានផ្តល់ដំបងឱ្យនារីជាប្រពន្ធក៏មិនត្រូវទទួលការផ្តន្ទាទោសដែរ។

-ការផ្តល់ជំនួយឱ្យបុគ្គលម្នាក់ចាប់ជនល្មើស ដែលបានប្រព្រឹត្តបទល្មើសជាក់ស្តែង។ អំពើចម្បង (ការចាប់ជនល្មើសដែលបានប្រព្រឹត្តបទល្មើសជាក់ស្តែង) មិនត្រូវបានផ្តន្ទាទោសឡើយ ដោយសារតែអំពើនោះគឺជាអំពើដែលអនុញ្ញាត ដោយច្បាប់។ ក្នុងករណីនេះ ការផ្តល់ជំនួយពុំត្រូវទទួលការផ្តន្ទាទោសឡើយ។

ប៉ុន្តែ ប្រសិនបើចារីមិនត្រូវបានផ្តន្ទាទោស ដោយសារមកពីស្ថានភាពផ្ទាល់ខ្លួនរបស់ជនល្មើស មិនមែនមកពីអំពើរបស់ជនល្មើស អ្នកផ្តើមគំនិត និងអ្នកសមគំនិតមិនអាចរួចផុតពីការទទួលខុសត្រូវបានឡើយ។

**ឧទាហរណ៍៖**

-ចារីបានរត់គេចខ្លួនបាត់ មិនអាចស្វែងរកសាវតារឃើញ។

-ចារីបានស្លាប់បាត់បង់ជីវិត ដែលជាហេតុនាំឱ្យបណ្តឹងអាជ្ញាត្រូវរលត់។

-ចារីគឺជាជនមានវិបល្លាសស្មារតី ដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។

ក្នុងករណីដូចខាងលើនេះ ចារីនៃបទល្មើសមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ក៏ប៉ុន្តែអ្នកផ្តើមគំនិត និងអ្នកសមគំនិតនៅតែត្រូវទទួលខុសត្រូវជាដដែល ។

### ២.២.៣. ធាតុផ្សំសត្យានុម័តនៃការផ្តើមគំនិត និង ការសមគំនិត

- ដើម្បីឱ្យការសិក្សាទៅលើធាតុផ្សំសត្យានុម័តនៃការផ្តើមគំនិត និងការសមគំនិតមានភាពច្បាស់លាស់ ជាការចាំបាច់ត្រូវធ្វើការពិចារណាទៅលើធាតុផ្សំសត្យានុម័តនៃការផ្តើមគំនិត ញែកចេញដាច់ដោយឡែកពីធាតុផ្សំសត្យានុម័តនៃការសមគំនិត។

#### ២.២.៣.១. ធាតុផ្សំសត្យានុម័តនៃការផ្តើមគំនិត

តាមខ្លឹមសារមាត្រា ២៨ នៃក្រមព្រហ្មទណ្ឌ ធាតុផ្សំសត្យានុម័តនៃការផ្តើមគំនិតមានពីរសំខាន់ៗគឺ ៖

**១/ ការជំរុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមតាមការណែនាំ ឬការបញ្ជា**

អ្នកផ្តើមគំនិត គឺជាជនដែលនៅពីក្រោយការប្រព្រឹត្តបទល្មើស ឬជាអ្នកចាប់ផ្តើមឱ្យមានការប្រព្រឹត្តបទល្មើស។ តាមក្រមព្រហ្មទណ្ឌ ការជំរុញនេះធ្វើឡើងតាមរយៈការណែនាំ ឬការបញ្ជា ។

ក្រមព្រហ្មទណ្ឌពុំបានកំណត់អំពីនិយមន័យនៃពាក្យ **ណែនាំ** ឡើយ។ តាមវចនានុក្រមរបស់សម្តេចសង្ឃរាជ **ជួន ណាត** ពាក្យ **ណែនាំ** មានន័យថា **ប្រាប់ទំនង ប្រាប់ឧបាយ ឱ្យយល់ឱ្យភ្លឺ នាំឱ្យធ្វើដោយពន្យល់បណ្តើរ**។ ហេតុនេះ ការណែនាំឱ្យប្រព្រឹត្តបទល្មើស សំដៅលើអំពើរបស់ជនម្នាក់ដែលប្រាប់ពន្យល់ ជនម្នាក់ទៀតឱ្យទៅប្រព្រឹត្តបទល្មើសណាមួយ។ ក្នុងន័យនេះ ពាក្យណែនាំ ខុសប្លែកពីពាក្យ បញ្ជា នៅត្រង់ថា ការបញ្ជាមានលក្ខណៈដាច់ខាតខ្លាំងក្លាជាងការ ណែនាំទៅទៀត ។

**ឧទាហរណ៍ ៖** ឈ្មោះ ក. បានពន្យល់ប្រាប់ឈ្មោះ ខ. ថា បើឈ្មោះ ខ. មានភាពខ្វះខាតក្នុងជីវភាពរស់នៅ ឈ្មោះ ខ. អាចបន្លំយកប្រាក់របស់ក្រុមហ៊ុនដែលកំពុងកាន់កាប់បាន ហើយក៏បានប្រាប់ឈ្មោះ ខ. អំពីរបៀបធ្វើបញ្ជីគណនេយ្យក្លែងបន្លំជាបន្ថែមទៀត ដើម្បីបញ្ច្រាសពីការចាប់អារម្មណ៍ ក្នុងការបន្លំយកប្រាក់ពីសំណាក់ថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន ជាដើម។ ក្នុងករណីនេះ ឈ្មោះ ក. បានណែនាំឱ្យឈ្មោះខ. ប្រព្រឹត្តបទរំលោភលើទំនុកចិត្ត។

ការណែនាំ ឬការបញ្ជាត្រូវមានលក្ខណៈច្បាស់លាស់ដែលអាចឈាន ទៅដល់ការសម្រេចបទល្មើសបាន។

**២/ ការបង្កឱ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្តល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន**

ការបង្កឱ្យមានបទល្មើសធ្វើឡើងតាមទម្រង់ច្រើនយ៉ាង។ ក្រមព្រហ្មទណ្ឌ ពុំបានចែងពីមធ្យោបាយនៃការសម្តែងនូវការបង្កឱ្យមានបទល្មើសទេ ប៉ុន្តែបានកំណត់អំពីទម្រង់នៃការបង្កបទល្មើសដូចតទៅៈ

**-ការផ្តល់អំណោយ**

**ឧទាហរណ៍ ៖** ជនម្នាក់បានប្រាប់ជនម្នាក់ទៀត ឱ្យទៅវាយជនទីបីដែលបានដណ្តើមយកសង្សាររបស់គាត់ ដោយបានសន្យាថានឹងផ្តល់ប្រាក់ចំនួន ២លានរៀល ហើយគាត់បានប្រគល់ប្រាក់ចំនួន ១លានរៀល ជាមុន។ ការផ្តល់ប្រាក់បែបនេះ គឺជាការផ្តល់អំណោយ ដែលជាធាតុផ្សំនៃការផ្តើមគំនិត។

**-ការសន្យា**

**ឧទាហរណ៍ ៖** នារីម្នាក់បានប្រាប់បុរសម្នាក់ដែលស្រឡាញ់នាងថា ប្រសិនបើចង់ឱ្យនាងស្រឡាញ់វិញ ត្រូវទៅប្រដៅបុរសម្នាក់ទៀតដែលជាអតីតសង្សាររបស់នាងដែលបានធ្វើបាបរូបនាងកន្លងមក។

**-ការគំរាមកំហែង**

**ឧទាហរណ៍ ៖** បុរសម្នាក់បានគំរាមកំហែងសង្សាររបស់ខ្លួន ឱ្យលួចទ្រព្យសម្បត្តិរបស់ឪពុកម្តាយនាងយកមកឱ្យរូបខ្លួន បើមិនដូច្នោះទេ គេនឹងយករូបភាពអាសអាភាសរបស់នាងទៅផ្សព្វផ្សាយឱ្យគេដឹង។

**-ការញុះញង់**

ការញុះញង់ គឺជាការនិយាយចាក់រុក នាំអុចអាលឱ្យអ្នកដទៃធ្វើការអ្វីៗដែលមិនគប្បី។[5]

[5] វចនានុក្រមរបស់សម្តេចសង្ឃរាជ ជួន ណាត ទំព័រទី ២៩៦

**ឧទាហរណ៍ ៖** នារីម្នាក់បាននិយាយទៅកាន់មិត្តភក្តិរបស់នាងថា ការដែលនាងទ្រាំរស់នៅជាមួយនឹងប្តីក្បត់ចិត្តបែបនេះ គឺជាការរស់នៅក្នុងឋាននរកដ៏ខ្មៅងងឹតបំផុត ចំណែកឯសហាយរបស់ប្តីនាងរស់នៅក្នុងទ្រនំខ្ពង់ខ្ពស់ ជាការសោយសុខនៅលើឋានសួគ៌ នាងត្រូវតែធ្វើអ្វីម្យ៉ាងឱ្យស្ត្រីជាសហាយនោះឈឺចាប់ ដូចជាទៅជះទឹកអាស៊ីដលើនារីនោះឱ្យខូចសម្រស់ទៅប្តីរបស់នាងនឹងវិលត្រឡប់មករកនាងវិញជាមិនខាន។ ក្រោយពីបានបញ្ចុះបញ្ចូលបែបនេះរួចហើយ មិត្តភក្តិរបស់នារីនោះ ក៏កើតក្តីក្រហល់ក្រហាយខឹងនឹងស្ត្រីកំណាន់ចិត្តរបស់ប្តីនាង ហើយសម្រេចចិត្តរៀបចំផែនការជះទឹកអាស៊ីដលើស្ត្រីកំណាន់ចិត្តរបស់ប្តីនាង។

**-ការល្បួងលោម**

**ឧទាហរណ៍ ៖** បុរសម្នាក់បាននិយាយអង្វរប្រពន្ធរបស់ខ្លួនឱ្យយកប្រាក់របស់ក្រុមហ៊ុនដែលនាងកំពុងតែកាន់កាប់ មកចំណាយទៅលើការព្យាបាលកូនរបស់គាត់ដែលកំពុងតែមានជំងឺត្រូវការប្រាក់ព្យាបាលជាចាំបាច់ បើពុំដូច្នោះទេ កូនរបស់គាត់អាចនិងស្លាប់បាត់បង់ជីវិត។

**-ការរំលោភអាជ្ញា ឬអំណាច**

**ឧទាហរណ៍ ៖** មន្ត្រីនគរបាលយុត្តិធម៌ម្នាក់បានប្រាប់ឱ្យភ្នាក់ងារនគរបាលយុត្តិធម៌នៅក្រោមបង្គាប់របស់ខ្លួន ឱ្យធ្វើទារុណកម្មលើជនសង្ស័យដែលត្រូវបានឃាត់ខ្លួន។

សូមធ្វើការកត់សម្គាល់ថា ការបង្កឱ្យប្រព្រឹត្តបទល្មើសដែលធ្វើឡើងតាមរយៈពាក្យសម្តីទូលំទូលាយគ្មានភាពច្បាស់លាស់មិនអាចឱ្យគេចាត់ទុកជាធាតុផ្សំ នៃការផ្តើមគំនិតបានឡើយ។

**ឧទាហរណ៍ ៖** បុគ្គលម្នាក់ប្រើសម្តីមួយម៉ាត់ថា **សម្លាប់ទៅ** ដោយពុំមានបន្ថែមអ្វីទាំងអស់ រួចហើយក៏បានដើរចេញទៅវិញបាត់ទៅ។

### ២.២.៣.២. ធាតុផ្សំសត្យានុម័តនៃការសមគំនិត

មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌចាត់ទុកការផ្តល់ជំនួយ ឬការឧបត្ថម្ភថាជាធាតុផ្សំនៃការសមគំនិត។ ការផ្តល់ជំនួយ ឬការឧបត្ថម្ភចំពោះការប្រព្រឹត្តបទល្មើស គឺជាអំពើដែលបានធ្វើឱ្យការរៀបចំ និងការប្រព្រឹត្តបទល្មើសប្រព្រឹត្តទៅដោយ មានភាពងាយស្រួល។ ការផ្តល់ជំនួយឬការឧបត្ថម្ភ រួមមាន ៖

**១/ ការផ្តល់មធ្យោបាយផ្សេងៗសម្រាប់ប្រព្រឹត្តបទល្មើស**

ជាក់ស្តែង ការផ្តល់មធ្យោបាយប្រព្រឹត្តបទល្មើសមានច្រើនយ៉ាងដូចជា ការផ្តល់អាវុធ ការផ្តល់ឧបករណ៍ ឬមធ្យោបាយផ្សេងៗទៀតដែលអាចយកទៅប្រើប្រាស់ដើម្បីបំពេញសកម្មភាពល្មើស ដោយដឹងយ៉ាងច្បាស់ថាឧបករណ៍ទាំងនោះនឹងត្រូវយកទៅប្រើប្រាស់ក្នុងគោលដៅប្រព្រឹត្តបទល្មើសជាក់ជាមិនខាន។

**ឧទាហរណ៍ ៖**

- ការផ្តល់អាវុធ។

- ការផ្តល់រថយន្តដើម្បីសម្រួលដល់អំពើលួច។
- ការផ្តល់វិក្កយបត្រក្លែងក្លាយ។
- ការផ្តល់នូវបញ្ជីឈ្មោះបុគ្គលមួយចំនួនដើម្បីធ្វើការឆបោក។
- ការផ្តល់នូវជម្រកដល់ការប្រព្រឹត្តបទល្មើសរំលូតកូនខុសច្បាប់។
- ការបង្កសំឡេងដើម្បីបិទបាំងកុំឱ្យគេឮសម្រែករបស់ជនរងគ្រោះ។
- ការរង់ចាំមើលផ្លូវ ដើម្បីឱ្យចោរចូលលួចទ្រព្យសម្បត្តិ។
- ការធ្វើឱ្យមានទំនាក់ទំនងរវាងស្ត្រីដែលមានបំណងរំលូតកូនខុសច្បាប់ និងជនដែលអាចធ្វើការរំលូតកូនខុសច្បាប់ ។
- ការព្យាយាមបង្វែរការចាប់អារម្មណ៍របស់ជនរងគ្រោះ ដើម្បីឱ្យជនល្មើសងាយស្រួលប្រព្រឹត្តបទល្មើស។
- ការពង្រឹងសតិអារម្មណ៍របស់ជនរងគ្រោះ ឱ្យកាន់តែមានជំនឿជឿជាក់ទៅលើជនឆបោក។
- ការព្យាយាមទូរស័ព្ទទាក់ទងឱ្យជនរងគ្រោះចេញទៅខាងក្រៅផ្ទះ ដើម្បីឱ្យជនល្មើសអាចបាញ់សម្លាប់ជនរងគ្រោះបាន។

ទន្ទឹមនឹងនេះដែរ អំពើអកម្មខ្លះដែលកើតចេញពីការព្រមព្រៀងឃុបឃិតគ្នាជាមុន ក៏អាចជាធាតុផ្សំសត្យានុម័តនៃការសមគំនិតបានដែរ។

**ឧទាហរណ៍ ៖** ការធ្វើជាភ្លេចមិនបានចាក់សោទូរដែកនៅក្នុងធនាគារ ដើម្បីសម្រួលឱ្យចោរចូលលួចទ្រព្យសម្បត្តិមានតម្លៃក្នុងទូរដែក។

**២/ ការផ្តល់ជំនួយ ឬការឧបត្ថម្ភផ្នែកស្មារតី**

ការលើកទឹកចិត្តឱ្យប្រព្រឹត្តបទល្មើស អាចចាត់ទុកថាជាការផ្តល់ជំនួយ ឬការឧបត្ថម្ភផ្នែកស្មារតីឱ្យជនល្មើសសម្រេចបាននូវបទល្មើសផងដែរ។

**ឧទាហរណ៍ ៖** ជនដែលបានឈរមើលការវាយតប់គ្នាដោយចេតនា អាចចាត់ទុកថាជា ការលើកទឹកចិត្ត និងការសម្រួលដល់ការប្រព្រឹត្តបទល្មើសរបស់ចារី ពីព្រោះថា ដោយសារតែវត្តមានរបស់ជននោះហើយ ទើបធ្វើឱ្យចារីមានកម្លាំងចិត្តប្រព្រឹត្ត សកម្មភាពរបស់ខ្លួន ហើយនឹងធ្វើឱ្យតតិយជនមិនអាចចូលមកធានាអំពើខុសច្បាប់របស់ជនល្មើសបាន។

ម្យ៉ាងវិញទៀត ដើម្បីធ្វើឱ្យការផ្តើមគំនិត និងការសមគំនិតមានទោស ជាតុផ្សំសត្យានុម័តនៃការផ្តើមគំនិត និងការសមគំនិត ត្រូវមានមុន ឬស្របពេលជាមួយនឹងអំពើចម្បង។ ក៏ប៉ុន្តែ ធាតុផ្សំសត្យានុម័តនៃការផ្តើមគំនិត និងការ សមគំនិតអាចកើតឡើងនៅក្រោយអំពើល្មើសបាន ប្រសិនបើអ្នកផ្តើមគំនិត ឬអ្នកសមគំនិត និងចារីបាន

ព្រមព្រៀងគ្នាជាមុនថាយ៉ាងដូច្នេះ។ ក្នុងករណីនេះត្រូវរកភស្តុតាងមកបញ្ជាក់ពីការឃុបឃិតព្រមព្រៀងគ្នាជាមុន រវាងអ្នកផ្តើមគំនិត ឬអ្នកសមគំនិត និងចារី។

**ឧទាហរណ៍ ៖** លោក ក. និងលោក ខ. បានព្រមព្រៀងគ្នាថា លោក ក. នឹងរង់ចាំជូន លោក ខ. (ចារី) រត់គេចខ្លួនចេញពីកន្លែងកើតហេតុ នៅពេលដែលលោក ខ. បានប្រព្រឹត្តបទល្មើសរួចហើយភ្លាម។

ប្រសិនបើពុំមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ អំពីការឃុបឃិតព្រមព្រៀងគ្នាជាមុនទេ អំពើរបស់ជនដែលបានសម្រួលដល់បទល្មើស ក្រោយពេលបានប្រព្រឹត្តបទល្មើសរួចហើយ អាចចាត់ចូលជាបទល្មើសដោយឡែកទៅវិញ។

**ឧទាហរណ៍ ៖**

-ការជួយដល់ជនល្មើសក្នុង **បទឃាតកម្ម** ដើម្បីលាក់បាំងសាកសពរបស់ជនរងគ្រោះ គឺជា **បទលាក់បំបាំងសាកសព** ពោលគឺជាអំពើដែលធ្វើឱ្យបាត់ ឬលាក់បំបាំងសាកសពបុគ្គលណាម្នាក់ដែលរងគ្រោះពីបទមនុស្សឃាត ឬ ទទួលមរណភាពបន្ទាប់ពីអំពើហិង្សា។[6] បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ២ឆ្នាំ និងពិន័យជាប្រាក់ពី ១លាន រៀល ទៅ ៤លានរៀល។

-ការជួយជនល្មើស ក្នុងការរៀបចំទីកន្លែងប្រព្រឹត្តបទល្មើសឱ្យបានស្អាតបាត ដើម្បីកុំឱ្យមានសល់ស្លាកស្នាមនៃការប្រព្រឹត្តបទល្មើសនៅកន្លែងកើតហេតុ។ អំពើនេះជា **បទលាក់បំបាំងតម្រុយ**[7] បានសេចក្តីថាជាអំពើកែប្រែ លុបបំបាត់ ឬលាក់បំបាំងតម្រុយ ឬស្លាកស្នាមនៅលើទីកន្លែងនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ក្នុងគោលបំណងធ្វើជាឧបសគ្គដល់ការស្វែងរកឱ្យឃើញនូវការពិត។

-ការជួយជនល្មើស ក្នុងការរើសយកសំបកកាទូសយកទៅបោះចោល។ អំពើនេះគឺជា បទលុបបំបាត់វត្ថុតាងដែលជាអំពើលុបបំបាត់ ឬផ្លាស់ប្តូរទីក ឬយកវត្ថុណាមួយក៏ដោយ នៅលើទីកន្លែងនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ក្នុងគោល បំណងធ្វើជាឧបសគ្គដល់ការស្វែងរកឱ្យឃើញនូវការពិត។[8]

បញ្ហាអាចចោទឡើង នៅពេលដែលមានការផ្តើមគំនិត ឬការសមគំនិត ក្នុងការប្រព្រឹត្តអំពើចម្បងដែលជាការផ្តើមគំនិត ឬជាការសមគំនិតដែរ នោះតើអាចត្រូវទទួលរងការផ្តន្ទាទោសបានដែរឬទេ។

**ឧទាហរណ៍ ៖**

-ឈ្មោះ ក. បានផ្តល់រថយន្តមួយគ្រឿងឱ្យឈ្មោះ ខ. យកទៅប្រើប្រាស់ដោយបានដឹងយ៉ាងច្បាស់ថាឈ្មោះ ខ. នឹងយករថយន្តរបស់ខ្លួនទៅឱ្យឈ្មោះ គ. ដើម្បីធ្វើជាមធ្យោបាយដឹកជញ្ជូនអាវុធដោយខុសច្បាប់។

[6] មាត្រា ៥៣១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[7] មាត្រា ៥៣២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[8] មាត្រា ៥៣៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

អំពើរបស់ឈ្មោះ ខ. គឺជាការផ្តល់ជំនួយឧបត្ថម្ភដល់ឈ្មោះ គ. ក្នុងការប្រព្រឹត្តបទល្មើសដែលជាការ សមគំនិត។ ចំណែកឯអំពើរបស់ឈ្មោះ ក. គឺជាការផ្តល់ជំនួយឧបត្ថម្ភដល់ឈ្មោះ ខ. ដែរ។ នៅក្នុងករណីដូចខាងលើនេះ អំពើរបស់ឈ្មោះ ក. ត្រូវចាត់ទុកថាគឺជា **ការសមគំនិតក្នុងអំពើសមគំនិត**។

-ជនម្នាក់បានញុះញង់ជនម្នាក់ទៀត ឱ្យនាំជនទីបីទៅប្រព្រឹត្តបទល្មើស។

តាមការជាក់ស្តែង អំពើខាងលើក៏ជាអំពើបង្កគ្រោះថ្នាក់ខ្លាំងដល់សង្គមដែរ **ហើយគួរតែទទួលការផ្តន្ទាទោសដូចជាការផ្តើមគំនិត ឬការសមគំនិតដែរ**។

**២.២.៣.៣. ធាតុផ្សំអត្តនោម័តនៃការផ្តើមគំនិត និងការសមគំនិត**

ការផ្តើមគំនិត និង ការសមគំនិត ត្រូវតែកើតចេញពីចេតនាទុច្ចរិតរបស់ អ្នកផ្តើមគំនិត និងអ្នកសមគំនិត ក្នុងការជំរុញ ឬបង្កឱ្យបទល្មើសកើតឡើង។ និយាយជារួម អ្នកផ្តើមគំនិត និងអ្នកសមគំនិត គឺជាជនដែលមានបំណងប្រព្រឹត្ត អំពើផ្តើមគំនិត និងអំពើសមគំនិត ឬឱ្យច្បាស់ជាងនេះទៅទៀតគឺថា អ្នកផ្តើមគំនិត និងអ្នកសមគំនិតបានដឹងថា អំពើរបស់ចារីគឺជាបទល្មើស ហើយខ្លួននៅតែមានបំណងចង់ចូលរួមជាមួយចារីទៀត។ ហេតុដូចនេះ ប្រសិនបើការផ្តល់មធ្យោបាយ ឬការណែនាំដោយសុទ្ធចិត្តទៅឱ្យជនម្នាក់ ដែលក្រោយមកបានយកមធ្យោបាយ ឬការណែនាំនោះទៅប្រព្រឹត្តបទល្មើស គឺពុំអាចចាត់ទុកថាជាការផ្តើមគំនិត ឬជាការសមគំនិតដែលត្រូវទទួលការផ្តន្ទាទោសឡើយ។

**ឧទាហរណ៍ ៖**

-បុគ្គលម្នាក់បានឱ្យរថយន្តរបស់ខ្លួនទៅមិត្តភក្តិខ្ចីប្រើប្រាស់ ប៉ុន្តែចារីបែរជាឆ្លៀតយករថយន្តនោះ ទៅធ្វើជាមធ្យោបាយ ដើម្បីបើកបុកសម្លាប់គូសត្រូវរបស់ខ្លួនទៅវិញ ។

-បុគ្គលម្នាក់បានផ្តល់ព័ត៌មានឱ្យជនម្នាក់ទៀត ពីអវត្តមានរបស់អ្នកដែលរស់នៅជិតផ្ទះរបស់ខ្លួន ឮយ៉ាងដូច្នេះ ជននោះបានចូលទៅលួចទ្រព្យសម្បត្តិនៅ ក្នុងផ្ទះរបស់អ្នកជិតខាងនោះតែម្តង។

ដើម្បីអាចទទួលការផ្តន្ទាទោសបាន ចេតនាទុច្ចរិតរបស់អ្នកផ្តើមគំនិត និងអ្នកសមគំនិត ត្រូវតែមាននៅខណៈពេលចូលរួមសហការជាមួយចារី បានន័យថា អ្នកផ្តើមគំនិត និងអ្នកសមគំនិតដឹងថាចារីប្រាកដជាយកការណែនាំ ឬ មធ្យោបាយដែលខ្លួនផ្តល់ឱ្យទៅដើម្បីប្រព្រឹត្តបទល្មើសជាក់ជាមិនខាន។ ផ្ទុយទៅវិញ ប្រសិនបើបំណងចូលរួមសហការជាមួយចារីកើតមានឡើង ក្រោយពីបានប្រព្រឹត្តបទល្មើសចប់សព្វគ្រប់រួចហើយ គឺពុំអាចមានទោសតាមបទបញ្ញត្តិច្បាប់ខាងលើបានទេ ប៉ុន្តែត្រូវទទួលការផ្តន្ទាទោសតាមទម្រង់នៃបទល្មើសទៀត ដូចជា **បទលាក់បំបាំងសាកសព បទលាក់បំបាំងតម្រុយ និងបទលុបបំបាត់វត្ថុតាង** ជាដើម។

ជាទូទៅ ចារីប្រព្រឹត្តបទល្មើសស្របតាមគំនិតដែលអ្នកផ្ដើមគំនិត និងអ្នកសមគំនិតមានបំណងចូលរួមជាមួយ។ ក៏ប៉ុន្តែបើចារីបែរជាប្រព្រឹត្តបទល្មើស ដែលអ្នកផ្ដើមគំនិត ឬអ្នកសមគំនិតមិនមានបំណងចូលរួមជាមួយ តើនឹងទៅជា យ៉ាងណា? ក្នុងសម្មតិកម្មបែបនេះ គេត្រូវបែងចែកទៅតាមករណីពីរយ៉ាង ៖

**១/ បើភាពខុសគ្នារវាងបំណងរបស់អ្នកផ្ដើមគំនិត ឬអ្នកសមគំនិត និងអំពើដែលបានប្រព្រឹត្តពិតប្រាកដមានខ្លះៗតែប៉ុណ្ណោះ** អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតនៅតែទទួលទោសដដែល ពោលគឺត្រូវតែផ្ដន្ទាទោសទៅតាមអំពើដែលចារី បានប្រព្រឹត្តពិតប្រាកដមែន។

**ឧទាហរណ៍ ៖**

-ចារីបានប្រើប្រាស់សម្ភារៈខុសប្លែកពីអ្វីដែលអ្នកផ្ដើមគំនិតបានព្រៀងទុក ( អ្នកផ្ដើមគំនិតផ្ដល់ការណែនាំឱ្យសម្លាប់ដោយប្រើខ្សែរឹតក ក៏ប៉ុន្តែចារីបែរជាប្រើកាំបិតដើម្បីចាក់សម្លាប់ទៅវិញ)។

-បទល្មើសត្រូវបានប្រព្រឹត្តដោយមានស្ថានទម្ងន់ទោសណាមួយ ដែលតាមពិតអ្នកសមគំនិតមិនចង់បានឡើយ (អ្នកសមគំនិតចង់ឱ្យលួច តែចារីបែរជាលួចហើយថែមទាំងប្រើហិង្សាទៀតផង)។ ក្នុងករណីយ៉ាងនេះ អ្នកសមគំនិតត្រូវទទួលទោសក្នុងឋានៈជាអ្នកសមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយ សារការប្រព្រឹត្តអំពើហិង្សា។

ក្នុងន័យដូចគ្នានេះដែរ បើសិនជាបំណងរបស់អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតមិនសូវច្បាស់លាស់ មានន័យថា គេមិនអាចកំណត់ឱ្យបានច្បាស់លាស់អំពីបំណងរបស់អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតទេ អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតត្រូវទទួលទោសដូចគ្នានឹងចារីដែរ ទោះបីជាចារីបានប្រព្រឹត្តបទល្មើសនៅក្នុងទំហំណាក៏ដោយ។

**ឧទាហរណ៍ ៖** បុគ្គលម្នាក់បានផ្ដល់ប្រាក់ឱ្យចារី ដើម្បីឱ្យចារីទៅសងសឹកលើជនរងគ្រោះ តាមអ្វីដែលចារីអាចធ្វើបាន ។ ហេតុដូច្នេះទោះបីជាចារីទៅប្រព្រឹត្តត្រឹមតែប្រើ អំពើហិង្សាដោយចេតនាលើជនរងគ្រោះ ឬក៏រហូតដល់ទៅសម្លាប់ជនរងគ្រោះក៏ដោយ ក៏អ្នកផ្ដើមគំនិតត្រូវតែទទួលទោសទៅតាមអំពើជាក់ស្ដែងរបស់ចារីដែរ។

**២/ បើបំណងរបស់អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតមានភាពខុសគ្នាដាច់ ស្រឡះពីអំពើដែលបានប្រព្រឹត្តពិតប្រាកដដោយចារី អ្នកផ្ដើមគំនិត ឬ អ្នកសមគំនិតមិនអាចត្រូវទទួលរងការផ្ដន្ទាទោសបានឡើយ** មានន័យថា ចារីបានប្រព្រឹត្តបទល្មើសដែលមិនពាក់ព័ន្ធនឹងបទល្មើសដែលអ្នកផ្ដើមគំនិត ឬអ្នកសមគំនិតមាន បំណងចង់ចូលរួមជាមួយនឹងចារីទាល់តែសោះ។

**ឧទាហរណ៍ ៖** លោក ក. ជាម្ចាស់បំណុល (**អ្នកឱ្យប្រាក់គេខ្ចី**) បានផ្ដល់កាំភ្លើងឱ្យលោក ខ. (**ចារី**) យកទៅប្រើប្រាស់ ដើម្បីគំរាមកំហែងលោក គ. ជាកូនបំណុល (**អ្នកខ្ចីប្រាក់** ) របស់គាត់ឱ្យសងប្រាក់មកគាត់វិញ។ ក៏ប៉ុន្តែនៅពេលទៅដល់លោក គ. លោក ខ. ក៏បានឈ្លោះប្រកែកគ្នាយ៉ាងខ្លាំងជាមួយអ្នកបម្រើ ក្នុងផ្ទះរបស់លោក គ.

រួចហើយលោក ខ. ក៏បានយកកាំភ្លើងទៅប្រើ ដើម្បីសម្លាប់អ្នកបម្រើនោះទៅ។ ក្នុងករណីដូចនេះ លោក ក. មិនត្រូវមានទោស បទឃាតកម្មលើអ្នកបម្រើការក្នុងផ្ទះរបស់លោក គ. ឡើយ។

## ២.៤. ការដាក់ទណ្ឌកម្មលើការផ្តើមគំនិត និង ការសមគំនិត

យោងតាមកថាខណ្ឌចុងក្រោយនៃបទប្បញ្ញត្តិមាត្រា ២៨ និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ បានចែងយ៉ាងច្បាស់ថា អ្នកផ្តើមគំនិត និងអ្នកសមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ។

តាមខ្លឹមសារបញ្ញត្តិនៃក្រមព្រហ្មទណ្ឌខាងលើ ឃើញថា អ្នកផ្តើមគំនិត និងអ្នកសមគំនិត ត្រូវទទួលរងការផ្តន្ទាទោសដូចគ្នាទៅនឹងចារីដែរ បានសេចក្តី ថា អ្នកផ្តើមគំនិត និង អ្នកសមគំនិតក៏ត្រូវទទួលរងនូវមូលទោស និងទោសបន្ថែម ដែលច្បាប់បានចែងសម្រាប់បទល្មើសដែលជាអំពើចម្បងប្រព្រឹត្តដោយចារីដែរ។ មកជាការបញ្ញត្តិយ៉ាងដូច្នេះពុំមែនមានន័យថា អ្នកផ្តើមគំនិត ឬអ្នកសមគំនិតត្រូវរួចខ្លួនទេ ក្នុងករណីដែលច្បាប់ពុំអាចផ្តន្ទាទោសចារី ដោយសារតែមូលហេតុ **ឧទាហរណ៍**ដូចជា ជនល្មើសបានរត់គេចខ្លួនបាត់ ឬជនល្មើសមិនទទួលខុសត្រូវ ព្រហ្មទណ្ឌដោយសារតែបានក្លាយខ្លួនជាមនុស្សវិកលចរិត។ល។ អ្នកផ្តើមគំនិត និងអ្នកសមគំនិតត្រូវតែទទួលការផ្តន្ទាទោស ដោយច្បាប់បានចាត់ទុកដូចជា ជននេះបានប្រព្រឹត្តបទល្មើសដោយផ្ទាល់ដែរ ពោលគឺតុលាការត្រូវតែសម្រេចដាក់ ទោសអ្នកផ្តើមគំនិត និងអ្នកសមគំនិត ដោយគិតថាជននេះបានប្រព្រឹត្តអំពើជាសត្យានុម័តនៃបទល្មើសដោយផ្ទាល់ខ្លួន។ ក្រៅពីនេះ តុលាការព្រហ្មទណ្ឌមានឆន្ទានុសិទ្ធិពេញលេញក្នុងការសម្រួលការផ្តន្ទាទោស ទៅតាមបុគ្គលិកលក្ខណៈរបស់អ្នកផ្តើមគំនិត ឬអ្នកសមគំនិត និងទៅតាមតួនាទីរបស់អ្នកទាំងនេះនៅក្នុង ការប្រព្រឹត្តសកម្មភាពល្មើស។ ក្នុងន័យនេះ ពេលខ្លះ អ្នកផ្តើមគំនិតអាចនឹងត្រូវ ទទួលការផ្តន្ទាទោសធ្ងន់ធ្ងរជាងចារីទៅទៀតក៏មានដែរ។

យ៉ាងណាមិញ ការដាក់ទណ្ឌកម្មលើអ្នកផ្តើមគំនិត និងអ្នកសមគំនិតអាចជួបប្រទះនឹងការលំបាកមួយចំនួនដែលត្រូវតែលើកយកមកពិនិត្យពិចារណា និងពិភាក្សាដូចខាងក្រោម ៖

**១/ សម្រាប់បទល្មើសដែលតម្រូវឱ្យចារីមានលក្ខណៈសម្បត្តិ ឬ មាន មុខងារណាមួយជាក់ច្បាស់ ៖** អ្នកផ្តើមគំនិត ឬក៏អ្នកសមគំនិតនៃបទល្មើសប្រភេទនេះ ក៏ត្រូវតែទទួលការផ្តន្ទាទោសដែរ បើទោះបីជា អ្នកផ្តើមគំនិត ឬអ្នកសមគំនិតពុំមានលក្ខណៈសម្បត្តិដែលច្បាប់តម្រូវឱ្យមានសម្រាប់ចារីក៏ដោយ។

**ឧទាហរណ៍ ៖ បទស៊ីសំណូក** តាមមាត្រា ៥១៧ នៃក្រមព្រហ្មទណ្ឌអាចកើតឡើងបាន លុះត្រាតែចារីមានគុណសម្បត្តិជាចៅក្រម ។ ដូច្នេះ ទោះបីជាអ្នកផ្តើមគំនិត ឬអ្នកសមគំនិតមិនមែនជាចៅក្រមក៏ដោយ ក៏ត្រូវទទួលរងនូវការផ្តន្ទាទោសដូចជា ចារីផងដែរ។

**២/ ក្នុងករណីដែលចារីបានប្រព្រឹត្តបទល្មើស ដែលមានស្ថានទម្ងន់ទោសជាក់ស្តែងជាប់នឹងបទល្មើស** (ហៅម្យ៉ាងទៀតថា ស្ថានទម្ងន់ទោសដែលមានលក្ខណៈសត្យានុម័ត) ៖ ទោះបីជាអ្នកផ្តើមគំនិត ឬអ្នកសមគំនិត

ពុំមានបំណងឱ្យចារីប្រព្រឹត្តបទល្មើស ដោយមានស្ថានទម្ងន់ទោសក៏ដោយ ក៏ជននេះត្រូវទទួលទោសដូចចារីដែរ កាលបើចារីបានប្រព្រឹត្តបទល្មើសដោយមានស្ថានទម្ងន់ទោសបែបនេះ។

**ឧទាហរណ៍ ៖** អ្នកផ្ដើមគំនិតបានផ្ដល់បញ្ជា ឱ្យចារីចូលទៅលួចយកទ្រព្យសម្បត្តិរបស់ជនរងគ្រោះដោយមិនឱ្យប្រើហិង្សាទេ ក៏ប៉ុន្តែចារីបានប្រើហិង្សានៅពេលដែល ធ្វើសកម្មភាពលួចទ្រព្យសម្បត្តិរបស់ជនរងគ្រោះ។ ក្នុងករណីនេះ អ្នកផ្ដើមគំនិតក៏ត្រូវទទួលទោសពីបទលួចមានស្ថានទម្ងន់ទោស ដោយសារការប្រព្រឹត្តអំពើហិង្សាដូចគ្នាទៅនឹងចារីដែរ។

**៣/ ក្នុងករណីដែលចារីត្រូវទទួលរងស្ថានទម្ងន់ទោស ឬ ទទួលបាន ស្ថានសម្រាលទោសផ្ទាល់ខ្លួន** (ហៅម្យ៉ាងទៀតថា ស្ថានទម្ងន់ទោស ឬស្ថានសម្រាលទោសដោយមូលហេតុអត្តនោម័ត) ពោលគឺជាស្ថានទម្ងន់ទោស ឬស្ថានសម្រាលទោសដែលពាក់ព័ន្ធនឹងបុគ្គលរបស់ចារីផ្ទាល់ ៖ ការផ្ដន្ទាទោសអ្នកផ្ដើមគំនិត ឬអ្នកសមគំនិតមិនត្រូវទាក់ ទងនឹងស្ថានទម្ងន់ទោស ឬស្ថានសម្រាលទោសនេះឡើយ។

**ឧទាហរណ៍ ៖** ជនម្នាក់បានផ្ដល់កាំភ្លើងមួយដើមឱ្យទៅចារី ដើម្បីយកទៅសម្លាប់សត្រូវរបស់គាត់។ ក្រោយពីឃាត់ខ្លួនចារីរួចហើយ ឃើញថាចារីជាជនដែលស្ថិតក្នុងភាពមិនរាងចាលដែលត្រូវតែទទួលរងនូវការផ្ដន្ទាទោសធ្ងន់ជាងធម្មតា។ នៅក្នុងលក្ខខណ្ឌបែបនេះ អ្នកផ្ដើមគំនិតមិនត្រូវទទួលរងបន្ថែមនូវស្ថានទម្ងន់ទោសពាក់ព័ន្ធនឹងការមិនរាងចាលរបស់ចារីនោះទេ ពោលគឺថាអ្នកផ្ដើមគំនិតគ្រាន់តែត្រូវទទួលទោសចំពោះបទល្មើសដែលចារីបានប្រព្រឹត្តជាក់ស្ដែងតែប៉ុណ្ណោះ ។

ដូចគ្នាដែរ ប្រសិនបើចារីជាអនីតិជនដែលត្រូវទទួលបាននូវការបន្ថយមូលទោសលើបទល្មើស អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតមិនអាចទទួលប្រយោជន៍ ពីការបន្ថយមូលទោសបែបនេះបានទេ ពីព្រោះថាចារីទទួលបាននូវផលប្រយោជន៍នេះដោយសារតែបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនរបស់ចារីតែប៉ុណ្ណោះ។

**៤/ ក្នុងករណីដែលចារីត្រូវទទួលស្ថានទម្ងន់ទោស ឬស្ថានសម្រាលទោសដែលមានលក្ខណៈចម្រុះ** មានន័យថាជាស្ថានទម្ងន់ទោស ឬស្ថានសម្រាលទោស ដែលពាក់ព័ន្ធនឹងស្ថានភាពផ្ទាល់របស់ចារីផង ព្រមទាំងពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសផងដែរ។

**ឧទាហរណ៍ ៖** ចំពោះការរំលោភសេពសន្ថវៈ ដែលប្រព្រឹត្តដោយឪពុករបស់ជនរងគ្រោះ គឺជាបទរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោស យោងតាមមាត្រា ២៤០ នៃ ក្រមព្រហ្មទណ្ឌ។ ស្ថានភាពរបស់ចារី (អ្នកមានអំណាចលើជនរងគ្រោះ) គឺជាស្ថានទម្ងន់ទោស។ ជាក់ស្ដែង ស្ថានភាពនេះត្រូវបានចាត់ទុកថាជាស្ថានទម្ងន់ទោស ដែលមានលក្ខណៈចម្រុះ ដែលអ្នកផ្ដើមគំនិត ឬអ្នកសមគំនិតត្រូវតែទទួលរងការផ្ដន្ទាទោសរួមផ្សំជាមួយនឹងស្ថានទម្ងន់ទោសនេះ ដូចគ្នាទៅនឹងការផ្ដន្ទាទោសលើចារីផងដែរ។ តាមពិត ស្ថានទម្ងន់ទោសនេះជាស្ថាន

ទម្ងន់ទោសពាក់ព័ន្ធជាមួយនិងបុគ្គលិកលក្ខណៈរបស់ចារីដោយផ្ទាល់ ក៏ប៉ុន្តែជាស្ថានទម្ងន់ដែលបានជ្រៀតចូលរួមជាមួយបទល្មើសតែម្តង។

# ជំពូកទី ២

# សិទ្ធរបស់ជនល្មើសក្នុងពេលឃាត់ខ្លួន

# ជំពូកទី ២

# សិទ្ធរបស់ជនល្មើសនៅពេលឃាត់ខ្លួន

ជាទូទៅបុគ្គលម្នាក់ៗត្រូវបានធានាចំពោះសិទ្ធិ សេរីភាពពេញលេញ ដោយច្បាប់រ៉ាប់រងមិនឱ្យមានការបំពាន ឬដកហូតដោយបង្ខំ ឬដោយខុសច្បាប់ណាមួយឡើយ។

ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូរបស់ប្រជាពលរដ្ឋ រាល់ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនបុគ្គលណាមួយនឹងអាចអនុវត្តទៅកើត លុះត្រាណាតែអនុវត្តត្រឹមត្រូវតាមច្បាប់។ **ហេតុដូចនេះ តើការធានារបស់ច្បាប់ចំពោះជនដែលត្រូវបានចាប់ខ្លួន ឬឃាត់ខ្លួន មានសិទ្ធិអ្វីខ្លះនោះ?**

យោងតាមច្បាប់កម្ពុជា ជនណាក៏ដោយដែលត្រូវបានមន្ត្រីនគរបាលយុត្តិធម៌ ចាប់ខ្លួន ឬឃាត់ខ្លួន មានសិទ្ធមួយចំនួនដើម្បីការពារខ្លួន ដែលសិទ្ធទាំងនោះជាសិទ្ធសំខាន់ និងមិនត្រូវបានបំពាន ឬដកហូតបាននោះឡើយ។ **នៅពេលជនល្មើសត្រូវបានចាប់ខ្លួន ត្រូវបានមន្ត្រីនគរបាលយុត្តិធម៌ធ្វើការឃាត់ខ្លួនជនល្មើសនោះ មានសិទ្ធិមួយចំនួនដូចជា៖**

## ៣.១. សិទ្ធិដឹងពីមូលហេតុចាប់ ឬឃាត់ខ្លួន

នៅពេលឃាត់ខ្លួនបុគ្គលណាម្នាក់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឱ្យដំណឹងជាបន្ទាន់ចំពោះសេចក្តីសម្រេចរបស់ខ្លួន ប្រាប់ឱ្យដឹងពីមូលហេតុនៃសេចក្តីសម្រេចឃាត់ខ្លួន សិទ្ធិមានជំនួយមេធាវី និងសិទ្ធមានអ្នកបកប្រែ ជាអាទិ៍។[9]

## ៣.២. សិទ្ធិមានជំនួយមេធាវី

ក្រោយពេលចាប់ខ្លួន ឬឃាត់ខ្លួន រយៈពេល ២៤ ម៉ោង កន្លងផុតទៅគិតចាប់ពីពេលផ្តើមចាប់ខ្លួន ឬឃាត់ខ្លួន ជនសង្ស័យមានសិទ្ធិជួបសន្ទនាជាមួយមេធាវី ឬជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំឱ្យតែជននោះមានពាក់ព័ន្ធនឹងរឿងជាមួយ។ ក្នុងករណីនេះ មេធាវី ឬជនដែលបានចូលជួបសន្ទនានោះ អាចទទួលបានការជូនដំណឹងតាមគ្រប់មធ្យោបាយ និងជាបន្ទាន់ ហើយមានសិទ្ធិចូលនៅកាន់ទីកន្លែងឃាត់ខ្លួន ដើម្បីទាក់ទងសន្ទនាជាមួយបុគ្គលសាមីខ្លួនបាន ៣០ នាទី ក្នុងលក្ខខណ្ឌធានាការសម្ងាត់នៃការសន្ទនា។[10]

## ៣.៣. សិទ្ធិមិនត្រូវបានឃាត់ខ្លួនហួសរយៈពេលកំណត់

ជនណាម្នាក់មិនត្រូវបានឃាត់ខ្លួនហួសរយៈពេលដែលបានកំណត់ ដោយច្បាប់ដោយគ្មានចំណាត់ការនីតិវិធីចោទប្រកាន់ណាមួយឡើយ ដោយនៅក្នុងនោះចំពោះនីតិជន (ជនដែលមានអាយុ១៨ ឆ្នាំឡើងទៅ) មិនអាចត្រូវបានឃាត់ខ្លួនលើសពី ៤៨ ម៉ោង អាចពន្យាបាន ២៤ ម៉ោង។ ចំពោះអនីតិជនដែលមានអាយុ ១៤ ទៅ

[9] មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[10] មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

១៦ ឆ្នាំ ចំពោះបទឧក្រិដ្ឋមិនត្រូវហួសរយៈពេល ៣៦ ម៉ោង ចំពោះបទជ្រឹម មិនត្រូវលើស ២៤ ម៉ោង ឬឯអនីតិជនដែលមានអាយុ ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំវិញ នៅក្នុងករណីបទឧក្រិដ្ឋមិនឱ្យលើស ៤៨ ម៉ោង និងករណីបទមជ្ឈឹម មិនឱ្យលើសពី ៣៦ ម៉ោងឡើយ។

## ៣.៤. សិទ្ធិមានជំនួយពីគ្រូពេទ្យ

ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិសុំឱ្យគ្រូពេទ្យមកពិនិត្យជនដែលត្រូវបានឃាត់ខ្លួនបានគ្រប់ពេលវេលា។ គ្រូពេទ្យផ្ទៀងផ្ទាត់មើលថាតើស្ថានភាពសុខភាពរបស់ជនដែលត្រូវបានឃាត់ខ្លួននោះ សមស្របនឹងការឃាត់ខ្លួនដែរ ឬទេ។ ប្រសិនបើគ្រូពេទ្យពិនិត្យឃើញថា ស្ថានភាពសុខភាពរបស់បុគ្គលនោះពុំសមស្របនឹងការឃាត់ខ្លួននោះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាអាចចុះមកទីកន្លែងនោះដោយផ្ទាល់ដើម្បីត្រួតពិនិត្យពីលក្ខខណ្ឌនៃការឃាត់ខ្លួន។[11]

## ៣.៥. អនីតិជនដែលត្រូវបានឃាត់ខ្លួន

កាលណាជនដែលត្រូវបានឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងគ្រប់មធ្យោបាយដល់ឪពុកម្ដាយ ដល់អ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារកិច្ចលើអនីតិជននោះ។[12]

## ៣.៦. សិទ្ធិរក្សាភាពស្ងៀមស្ងាត់

ជនដែលត្រូវបានឃាត់ខ្លួនមានសិទ្ធិរក្សាភាពស្ងៀមស្ងាត់ មិនឆ្លើយនូវសំណួររបស់មន្ត្រីនគរបាលយុត្តិធម៌បាន រហូតចាំដល់មានជំនួយពីមេធាវី ហើយគ្មាននណាម្នាក់អាចបង្ខំឱ្យឆ្លើយបានឡើយ។[13]

## ៣.៧. សិទ្ធិមិនឆ្លើយសារភាព

ជនដែលត្រូវបានចាប់ខ្លួន ឬឃាត់ខ្លួនមិនត្រូវឆ្លើយអ្វីដែលខ្លួនមិនបានប្រព្រឹត្តនោះទេ ឬអាចឆ្លើយ ឬមិនឆ្លើយសារភាពរហូតដល់មានមេធាវីការពារសិទ្ធិ ដោយគ្មាននរណាម្នាក់អាចបង្ខំឱ្យសារភាពថាបានប្រព្រឹត្តបទល្មើសណាមួយដោយការគំរាមកំហែង ការវាយដំ ធ្វើទារុណកម្ម ណាមួយនោះឡើយ។ រាល់ការសារភាពដែលកើតចេញពីការបង្ខំតាមផ្លូវកាយក្ដី ផ្លូវចិត្តក្ដី ការគំរាមកំហែង ការវាយដំ ធ្វើទារុណកម្ម មិនត្រូវចាត់ទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។

## ៣.៨. សិទ្ធិត្រូវបាននាំខ្លួនទៅតុលាការ

ក្រោយការឃាត់ខ្លួន ជនល្មើស និងជនសង្ស័យ ត្រូវតែមានការចោទប្រកាន់ ឬទទួលបានការបញ្ជូនទៅតុលាការឆាប់រហ័សតាមដែលអាចធ្វើទៅបាន។ ហើយតុលាការត្រូវធ្វើការពិនិត្យពីនិយ័តភាពនៃនីតិវិធីរបស់មន្ត្រី

[11] មាត្រា ៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[12] មាត្រា ១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[13] មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

នគរបាលយុត្តិធម៌ក្នុងការចាប់ខ្លួន ឬឃាត់ខ្លួននោះ បានធ្វើឡើងត្រឹមត្រូវតាមច្បាប់ដែរឬទេ? និងសម្រេចចំណាត់ការនីតិវិធីឱ្យបានឆាប់រហ័ស និងធានាដល់សិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ចំពោះជនជាប់ចោទនោះផងដែរ។[14]

## ៣.៩. សិទ្ធិប្ដឹងនឹងការបដិសេធផ្សេងៗរបស់មន្ត្រីនគរបាលយុត្តិធម៌

ប្រសិនបើសិទ្ធិណាមួយដែលច្បាប់បានធានាចំពោះជនល្មើស ឬជនសង្ស័យនៅពេលឃាត់ខ្លួនត្រូវបានបំពាន ឬបដិសេធដោយមន្ត្រីនគរបាលយុត្តិធម៌ ជននោះអាចប្ដឹងអំពីការបំពាន ឬតវ៉ានឹងការបដិសេធនោះដោយផ្ទាល់ ឬតាមរយៈមេធាវីរបស់ខ្លួន ទៅដល់ស្ថាប័នអយ្យការ ឬចៅក្រមស៊ើបសួរ ឬក៏តុលាការដែលមានសមត្ថកិច្ចបាន។

សរុបមកនូវរាល់ការចាប់ខ្លួន ឬឃាត់ខ្លួនចំពោះជនល្មើស មន្ត្រីនគរបាលយុត្តិធម៌ និងព្រះរាជអាជ្ញាត្រូវគោរពនូវសិទ្ធិជាមូលដ្ឋានសំខាន់ខាងលើនេះ ហើយបើមានការបំពានណាមួយជនល្មើសអាចធ្វើការប្ដឹងតវ៉ាបានគ្រប់ពេលវេលាផងដែរ។

[14] មាត្រា ១០៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

# ជំពូកទី ៣

# ប្រភេទនៃជនល្មើសក្នុងរឿងព្រហ្មទណ្ឌ

# ជំពូកទី ៣

# ប្រភេទនៃជនល្មើសក្នុងរឿងព្រហ្មទណ្ឌ

ជាធម្មតា នៅក្នុងសង្គមយើងសព្វថ្ងៃតែងតែមានបទល្មើសកើតឡើងជាហូរហែ ក៏ដោយសារតែប្រជាពលរដ្ឋមានការយល់ដឹងពីផ្នែកច្បាប់នៅមានកម្រិត ឬដោយសារតែមជ្ឈដ្ឋានជុំវិញខ្លួន ស្របពេលដែលប្រទេសកម្ពុជាត្រូវបានសម្លាប់អ្នកចេះអ្នកដឹងអស់ជាច្រើនលាននាក់ក្នុងសម័យ **ពល ពត** ដែលបច្ចុប្បន្នទើបតែស្តារឡើងមកវិញនូវធនធាន ទើបបង្កឱ្យមាននូវបទល្មើសជាច្រើនកើតឡើងឥតឈប់ឈរ។ ទន្ទឹមនឹងនោះប្រភេទជនល្មើសត្រូវបានបែងចែកជា ២ធំៗគឺ **ជនល្មើសជានីតិបុគ្គល** និង**ជនល្មើសជាអនីតិជននៅក្នុងរឿងព្រហ្មទណ្ឌ**។

## ៤.១. និយមន័យ និងការទទួលខុសត្រូវរបស់នីតិបុគ្គល

នីតិបុគ្គល គឺជាក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្តហើយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច។[15] ជាទូទៅ នីតិបុគ្គលមានពីរប្រភេទគឺ នីតិបុគ្គលនៃនីតិសាធារណៈ និងនីតិបុគ្គលនៃនីតិឯកជន។ នីតិបុគ្គលនៃនីតិសាធារណៈសំដៅដល់ រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ **(រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)**[16] **គ្រឹះស្ថានសាធារណៈ**។ នីតិបុគ្គលនៃនីតិឯកជនសំដៅលើ ក្រុមហ៊ុន សមាគម ជាដើម។ យោងតាមមាត្រា ៤៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា នីតិបុគ្គលមានពីរប្រភេទ**គឺ នីតិបុគ្គលសាជីវកម្ម** និង**នីតិបុគ្គលមូលនិធិ**។

- **នីតិបុគ្គលសាជីវកម្ម** គឺជាក្រុមដែលមានសមាជិក ហើយត្រូវបានប្រគល់នូវឋានៈជាប្រធានសិទ្ធិ និងកាតព្វកិច្ចដោយឯករាជ្យ។ **ឧទាហរណ៍ ៖** ដូចជាក្រុមហ៊ុន ឬសមាគម ជាដើម។

- **នីតិបុគ្គលមូលនិធិ** គឺជាទ្រព្យសម្បត្តិវិភាគទានដែលត្រូវបានប្រគល់នូវឋានៈជាប្រធានសិទ្ធិ និងកាតព្វកិច្ចដោយឯករាជ្យ។ **ឧទាហរណ៍ ៖** ដូចជាមូលនិធិដើម្បីជួយដល់កុមារពិការ ឬជួយឧបត្ថម្ភដល់ការសិក្សាស្រាវជ្រាវណាមួយ ជាដើម។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ត្រូវបានបញ្ញត្តិជាទូទៅនៅ មាត្រា ៤២ នៃក្រមព្រហ្មទណ្ឌ។ តាមពិត ច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមិនមែនទើបតែទទួលស្គាល់ពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលនៅក្នុងក្រមព្រហ្មទណ្ឌនោះទេ។ បើពិនិត្យទៅលើច្បាប់ពិសេសផ្សេងៗទៀតក្នុងវិស័យព្រហ្មទណ្ឌបង្ហាញឱ្យឃើញថា នីតិបុគ្គលក៏ត្រូវទទួលខុសត្រូវផងដែរសម្រាប់បទល្មើសមួយចំនួន។

[15] សន្ទានុក្រមផ្នែករដ្ឋប្បវេណី រៀបចំដោយ គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ពាក្យលេខរៀងទី៧១

[16] មាត្រា ៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ចែងថា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជានីតិបុគ្គលនៃនីតិសាធារណៈ

ជាក់ស្តែងមាត្រា ៤៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៧/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៧ ដែលជាច្បាប់ចាស់ **(ច្បាប់នេះត្រូវបាននិរាករណ៍ដោយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/រកម/០១១២/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២)** និងមានអានុភាព ក្នុងប្រទេសមុនពេលមានក្រមព្រហ្មទណ្ឌទៅទៀត ក៏ទទួលស្គាល់នូវការទទួលខុសត្រូវព្រហ្មទណ្ឌដោយនីតិបុគ្គលចំពោះបទល្មើសដែលមានចែងនៅក្នុងច្បាប់នេះ។

**- ដោយមាត្រា ៤៦ នៃច្បាប់បានចែងថា៖**

នីតិបុគ្គលទាំងឡាយត្រូវទទួលខុសត្រូវខាងបទព្រហ្មទណ្ឌ អំពីអំពើដែលមានចែងក្នុងច្បាប់នេះ។ តុលាការអាចផ្តន្ទាទោសណាមួយ ឬច្រើនមុខដូចតទៅ៖

- ពិន័យដែលមានទឹកប្រាក់អតិបរមាស្មើនឹង ៥ដងនៃអតិបរមានៃទោស ដែលមានចែងក្នុងច្បាប់នេះ។
- លាយនីតិបុគ្គល កាលណានីតិបុគ្គលនោះបានបង្កើតឡើងក្នុងគោលបំណង បង្វែរកម្មវត្ថុរបស់នីតិបុគ្គលដើម្បីប្រព្រឹត្តបទល្មើស ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារលើសពី ៥ឆ្នាំ។
- ហាមឃាត់ជាស្ថាពរ ឬសម្រាប់ចិរវេលា ៥ឆ្នាំ យ៉ាងយូរមិនឱ្យប្រកបវិជ្ជាជីវៈ ឬធ្វើសកម្មភាពសង្គមណាមួយ ទោះបីដោយផ្ទាល់ ឬដោយប្រយោល។
- ដាក់ឱ្យស្ថិតនៅក្រោមការឃ្លាំមើលរបស់តុលាការក្នុងចិរវេលា ៥ឆ្នាំ យ៉ាងយូរ។
- បិទទ្វារជាស្ថាពរ ឬសម្រាប់ចិរវេលា ៥ឆ្នាំ យ៉ាងយូរ គ្រឹះស្ថានទាំងឡាយ ឬគ្រឹះស្ថានរបស់សហគ្រាសដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស។
- មិនឱ្យចូលរួមដេញថ្លៃជាសាធារណៈជាស្ថាពរ ឬសម្រាប់ចិរវេលា ៥ឆ្នាំ យ៉ាងយូរ។
- ហាមឃាត់ជាស្ថាពរ ឬសម្រាប់ចិរវេលា ៥ឆ្នាំ យ៉ាងយូរ អំពាវនាវឱ្យ សាធារណជនយកប្រាក់មកបើកគណនេយ្យសន្សំ។
- ហាមឃាតសម្រាប់ចិរវេលា ៥ឆ្នាំ យ៉ាងយូរ ចេញមូលប្បទានប័ត្រផ្សេង ក្រៅពីមូលប្បទានប័ត្រសម្រាប់បេឡា ឬមូលប្បទានប័ត្របញ្ជាក់ ឬមិនឱ្យប្រើប្រាស់ប័ណ្ណសងប្រាក់។
- រឹបអូសតាមបញ្ញត្តិដែលមានចែងក្នុងមាត្រា ៥០ ដល់ ៥៩។
- បិទផ្សាយសេចក្តីសម្រេចរបស់តុលាការ ឬផ្សាយសេចក្តីសម្រេចនេះតាមសារព័ត៌មាន ឬទូរទស្សន៍។[17]

អ្វីដែលមានចែងខាងលើនេះ គឺជាទណ្ឌកម្មសម្រាប់ផ្តន្ទាទោសនីតិបុគ្គលដែលបានប្រព្រឹត្តបទល្មើស។ ប៉ុន្តែច្បាប់ពុំបានបរិយាយថា តើក្នុងលក្ខខណ្ឌណាដែលច្បាប់ចាត់ទុកថានីតិបុគ្គលបានប្រព្រឹត្តបទល្មើសឡើយ។

[17] មាត្រា ៤៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២

តាមកថាខណ្ឌចុងក្រោយនៃមាត្រា ៤៦ ខាងលើ បានគូសបញ្ជាក់ឱ្យឃើញថា នីតិបុគ្គលដែលច្បាប់សំដៅយក គឺអាចជានីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ ហើយច្បាប់បានហាមឃាត់តុលាការមិនឱ្យយកទោសមួយចំនួន មកប្រកាសចំពោះនីតិបុគ្គលសាធារណៈដូចជា **ទោសពិន័យ (ទោសទី ១)** និង**ទោសហាមឃាត់ប្រកបវិជ្ជាជីវៈ (ទោសទី ៣)**។ ម្យ៉ាងវិញទៀត បទប្បញ្ញត្តិខាងលើបានហាមឃាត់ការដាក់**ទោសពិន័យ(ទោសទី ១)** ទៅលើស្ថាប័នតំណាងបុគ្គលិកទៀតផង។

ទន្ទឹមនឹងនេះដែរ មាត្រា ៥៥ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ក៏បានលើកឡើងផងដែរពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អង្គភាពដែលរំលោភបំពានមាត្រាមួយចំនួននៃច្បាប់នេះ ដោយត្រូវតែពិន័យជាប្រាក់ពី ៥លានរៀលដល់ ១៥០លានរៀល រួមទាំងការបិទគ្រឹះស្ថានផង។

មាត្រា ៤២ នៃក្រមព្រហ្មទណ្ឌ បានកំណត់យ៉ាងច្បាស់លាស់ពីលក្ខខណ្ឌ នៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលដោយចែងដូចខាងក្រោម ៖

ក្នុងករណីដែលមានចែងដាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គលលើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬ អ្នកតំណាងរបស់ខ្លួនដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ។

កាលបើលក្ខខណ្ឌកំណត់ដោយច្បាប់មានគ្រប់គ្រាន់ហើយ (៤.១.១) នីតិបុគ្គលអាចត្រូវប្រកាសថាទទួលខុសត្រូវព្រហ្មទណ្ឌបាន។ ព្រមជាមួយគ្នានេះ ដោយសារតែលក្ខណៈពិសេសរបស់នីតិបុគ្គល ទោសដែលអាចប្រកាសបានទៅលើនីតិបុគ្គល មានភាពខុសប្លែកពីទោសដែលអាចប្រកាសបានលើរូបវន្តបុគ្គល (៤.២.១) ហើយដំណើរការនីតិវិធីប្រឆាំងនឹងនីតិបុគ្គលក៏ត្រូវសម្របសម្រួលទៅ តាមសភាពនេះដែរ (៤.៣.១)។ ទោះបីជាមានបទប្បញ្ញត្តិពិសេស សម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលក្តី ការដាក់ឈ្មោះបទល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គលថាជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ត្រូវកំណត់ដោយយោងទៅតាមទោសដែលច្បាប់បានកំណត់សម្រាប់រូបវន្តបុគ្គល។[18]

[18] មាត្រា ១៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

### ៤.១.១. លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

យោងតាមបទប្បញ្ញត្តិនៃមាត្រា ៤២ នៃក្រមព្រហ្មទណ្ឌ នីតិបុគ្គលគ្រប់ប្រភេទសុទ្ធតែអាចទទួលខុសត្រូវព្រហ្មទណ្ឌ រួមបញ្ចូលទាំងនីតិបុគ្គលសាធារណៈផង។[19] ក៏ប៉ុន្តែ **រដ្ឋ** ដែលជានីតិបុគ្គលសាធារណៈពុំទទួលខុសត្រូវព្រហ្មទណ្ឌទេ។ នីតិបុគ្គល អាចត្រូវប្រកាសថាទទួលខុសត្រូវព្រហ្មទណ្ឌបាន លុះត្រាតែមានច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតចែងទុកជាមុន **(ក)** ហើយបទល្មើសត្រូវបានប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់នីតិបុគ្គល **(ខ)** ដើម្បីជាប្រយោជន៍ដល់ នីតិបុគ្គលនោះ **(គ)**។

#### ៤.១.១.១. អត្ថិភាពនៃច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត

នីតិបុគ្គលមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈទូទៅទេ បានន័យថា នីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌ កាលបើច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតបានចែងយ៉ាងជាក់លាក់ថា នីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសបទល្មើសណាមួយជាកំណត់។

ហេតុដូច្នេះ ចំពោះបទល្មើសដែលមានចែងនៅមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌអំពីបទឃាតកម្ម ក្រមព្រហ្មទណ្ឌពុំបានចែងបញ្ជាក់បន្ថែមពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលទេ បានសេចក្តីថានីតិបុគ្គលមិនអាចត្រូវបានប្រកាសថាទទួលខុសត្រូវព្រហ្មទណ្ឌពីបទឃាតកម្មបានឡើយ។ **ឧទាហរណ៍ ៖** ប្រធានក្រុមហ៊ុន **ក.** បានធ្វើឃាតប្រធានក្រុមហ៊ុន **ខ.** ព្រោះតែការប្រកួតប្រជែងគ្នាផ្នែកពាណិជ្ជកម្ម។ តុលាការបានសម្រេចផ្តន្ទាទោសប្រធានក្រុមហ៊ុន **ក.** ពីបទឃាតកម្ម ក្នុងនាមជារូបវន្តបុគ្គល ក៏ប៉ុន្តែ តុលាការមិនអាចដាក់ទោសក្រុមហ៊ុន **ក.** ពី **បទឃាតកម្ម** ឡើយ ពីព្រោះតែពុំមានច្បាប់ចែងថា នីតិបុគ្គលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពី **បទឃាតកម្ម** ឡើយ។

ផ្ទុយទៅវិញ ទាក់ទងនឹង **បទមនុស្សឃាតដោយអចេតនា** ដែលមានចែងនៅមាត្រា ២០៧ នៃក្រមព្រហ្មទណ្ឌ មាត្រា ២០៩ នៃក្រមព្រហ្មទណ្ឌបានចែង ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលដែរ។ ការចែងយ៉ាងដូច្នេះ មានន័យថា នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទមនុស្សឃាត ដោយអចេតនាបាន កាលបើលក្ខខណ្ឌផ្សេងទៀតត្រូវបានបំពេញ។

ជាមួយគ្នានេះដែរ សម្រាប់បទសូកប៉ាន់ដល់និយោជិត ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧៩ នៃក្រមព្រហ្មទណ្ឌ ក៏នីតិបុគ្គលអាចត្រូវប្រកាសថា ទទួលខុសត្រូវព្រហ្មទណ្ឌបានដែរ កាលបើមានគ្រប់គ្រាន់នូវលក្ខខណ្ឌនៃមាត្រា ៤២ នៃក្រមព្រហ្មទណ្ឌ។[20]

#### ៤.១.១.២. បទល្មើសប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងនីតិបុគ្គល

នីតិបុគ្គល គឺជាបុគ្គលដែលកើតឡើងពីការសន្មតរបស់ច្បាប់។ នីតិបុគ្គល រមែងមានអង្គការតំណាងក្រោម

---

[19] មាត្រា ៤២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[20] មាត្រា ២៧៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

រូបភាពជាក្រុមប្រឹក្សា ឬអ្នកតំណាងជារូបវន្តបុគ្គលដែលធ្វើសកម្មភាពតំណាងឱ្យនីតិបុគ្គលជានិច្ច។

អង្គភាពតំណាង ឬអ្នកតំណាងនៃនីតិបុគ្គល គឺជាជន ឬអង្គភាពដែលច្បាប់ ឬលក្ខន្តិកៈផ្តល់នូវមុខងារជាអ្នកដឹកនាំគ្រប់គ្រងហើយមាននីតិសម្បទាគ្រប់គ្រាន់ ( **មានសិទ្ធិគ្រប់គ្រាន់តាមផ្លូវច្បាប់** ) ក្នុងការសម្រេចសេចក្តីដែលអាចធ្វើឱ្យនីតិបុគ្គលទទួលខុសត្រូវបាន ឬនិយាយម្យ៉ាងទៀតថា គឺជាអង្គភាព ឬជាអ្នកតំណាងដែលមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការប្រព្រឹត្តសកម្មភាពណាមួយក្នុងនាមនីតិបុគ្គល។

អង្គភាពដែលតំណាងឱ្យនីតិបុគ្គលមានឧទាហរណ៍ដូចជា ៖ ក្រុមប្រឹក្សាភិបាលក្រុមហ៊ុន សន្និបាតរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាឃុំសង្កាត់ ។ល។ និង ។ល។

អ្នកតំណាងឱ្យនីតិបុគ្គលរួមមានដូចជា ៖ ប្រធានសមាគម អភិបាល ( **អ្នកគ្រប់គ្រង** ) មេឃុំ ចៅសង្កាត់ ។ល។ និង ។ល។

### ៤.១.១.៣. ការប្រព្រឹត្តដើម្បីជាប្រយោជន៍ដល់នីតិបុគ្គល

ជាធម្មតា មានតែការប្រព្រឹត្តបទល្មើស ដើម្បីជាប្រយោជន៍ដល់នីតិបុគ្គលតែប៉ុណ្ណោះ ដែលជាកត្តាធ្វើឱ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌបាន ពីព្រោះថាបុគ្គលដែលទទួលប្រយោជន៍ពីការប្រព្រឹត្តបទល្មើស គប្បីត្រូវទទួលយកផលវិបាកនៃបទល្មើសនេះផងដែរ។ ត្រង់ចំណុចនេះ ប្រយោជន៍សំដៅលើផលប្រយោជន៍ ខាងសេដ្ឋកិច្ចដែលមានលក្ខណៈច្បាស់លាស់ ឬគ្រាន់តែជាយថាហេតុក៏បានដែរ។ **ឧទាហរណ៍ ៖** អភិបាលរបស់ក្រុមហ៊ុនមួយមិនបានចាត់នូវវិធានការសន្តិសុខ ឱ្យបានគ្រប់គ្រាន់តាមច្បាប់ ដើម្បីធានានូវសុវត្ថិភាពដល់កម្មករនិយោជិតរបស់ក្រុមហ៊ុនទេ ពីព្រោះតែគាត់មិនចង់ឱ្យក្រុមហ៊ុនចំណាយប្រាក់ច្រើនសម្រាប់ចាត់វិធានការសន្តិសុខនេះ។ អំពើនេះគឺធ្វើឡើងដើម្បីផលប្រយោជន៍របស់នីតិបុគ្គលហើយ។ ហេតុដូច្នេះ ប្រសិនបើការមិនបានចាត់វិធានការនោះជាមូលហេតុធ្វើឱ្យកម្មករនិយោជិតស្លាប់បាត់បង់ជីវិត ក្រុមហ៊ុននឹងត្រូវប្រកាសថាទទួលខុសត្រូវព្រហ្មទណ្ឌពី **បទមនុស្សឃាតដោយអចេតនា** បាន។

ផ្ទុយទៅវិញ បទល្មើសដែលប្រព្រឹត្តដោយអ្នកតំណាងរបស់នីតិបុគ្គល ក៏ប៉ុន្តែធ្វើឡើងក្នុងផលប្រយោជន៍ផ្ទាល់ខ្លួនរបស់អ្នកតំណាង មិនអាចឱ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ **ឧទាហរណ៍ ៖** ក្រុមហ៊ុនមួយត្រូវបានបង្កើតឡើង ដោយមានកម្មវត្ថុបើកភោជនីយដ្ឋានមួយកន្លែង។ នៅក្នុងការគ្រប់គ្រងភោជនីយដ្ឋាននេះអ្នកគ្រប់គ្រងភោជនីយដ្ឋាន បានអនុគ្រោះឱ្យមានការប្រកបរបរពេស្យាចារ នៅក្នុងភោជនីយដ្ឋាន ហើយបានកាត់យកប្រាក់ពីនារីពេស្យាដើម្បីជាប្រយោជន៍ផ្ទាល់របស់ខ្លួន។ អំពើនេះគឺជា **បទយល់ព្រមឱ្យធ្វើសកម្មភាពពេស្យាចារនៅក្នុងគ្រឹះស្ថាន និងសញ្ជារកម្ម** តែអំពើនេះប្រព្រឹត្តឡើងដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនរបស់អ្នកគ្រប់គ្រងដោយសារតែប្រាក់កម្រៃដែលកាត់យកពីនារីពេស្យាត្រូវអ្នកគ្រប់គ្រងនោះរក្សាទុកខ្លួនឯង។ ក្នុងករណីនេះ នីតិបុគ្គលមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ គឺអ្នកគ្រប់គ្រងនេះឯង ដែលជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌក្នុងនាមជារូបវន្តបុគ្គល។

**៤.២.១. ការដាក់ទណ្ឌកម្មលើនីតិបុគ្គល**

- មាត្រា ១៦៧ នៃក្រមព្រហ្មទណ្ឌបានកំណត់អំពីទោសទាំងឡាយសម្រាប់នីតិបុគ្គលរួមមាន ៖

• ទោសពិន័យក្នុងឋានៈជាមូលទោស។

• ទោសបន្ថែមដែលរៀបរាប់នៅក្នុងមាត្រា ១៦៨ នៃក្រមនេះ។[21]

ទោសបន្ថែមសម្រាប់នីតិបុគ្គលអាចត្រូវប្រកាសដោយតុលាការ ប្រសិនបើទោសនោះត្រូវបានចែងយ៉ាងជាក់លាក់ ចំពោះបទល្មើសដែលចោទប្រកាន់។ យោងតាមបទប្បញ្ញត្តិនៃមាត្រា ១៦៨ នៃក្រមព្រហ្មទណ្ឌទោសបន្ថែមជារួមដែល វត្តទៅលើនីតិបុគ្គលមានចំនួន ១៤ ប្រភេទ និងដែលត្រូវបានកំណត់ដូចរៀបរាប់ខាងក្រោមនេះ ៖

**១**-ការរំលាយចោល។

**២**-ការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ។

**៣**-ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬច្រើន។

**៤**-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។

**៥**-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ។

**៦**-ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូរបានដែលកំណត់ដោយធនាគារ។

**៧**-ការហាមឃាត់ចំពោះការប្រើបណ្ណទូទាត់។

**៨**-ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬប្រព្រឹត្តបទល្មើស។

**៩**-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលបានប្រើប្រាស់ដោយសាធារណជន។

**១០**-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើសម្រាប់បទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស។

**១១**-ការរឹបអូសនូវវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។

**១២**-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

**១៣**-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត។

**១៤**-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍។[22] **ឧទាហរណ៍ ៖** តាមមាត្រា ២៣០ នៃក្រម

[21] មាត្រា ១៦៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[22] មាត្រា ១៦៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ព្រហ្មទណ្ឌ នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌនៃមាត្រា ៤២ នៃក្រមនេះ[23] ចំពោះបទល្មើសដែលមានចែងនៅមាត្រា ២២៦ **(អំពើលក់ ធ្វើអនុប្បទាន ឬឱ្យចំណី ឬភេសជ្ជៈដោយដឹងថា ចំណី ឬភេសជ្ជៈនោះ មានសារជាតិពុលនាំឱ្យខូចសុខភាពនោះ ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា)**[24] និងមាត្រា ២២៧ **(អំពើប្រព្រឹត្ត ឡើងដោយចេតនាដោយដាក់បញ្ចូលនូវសារជាតិពុលនាំឱ្យខូចសុខភាព ទៅក្នុងទឹកសម្រាប់ហូបជាសាធារណៈ ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា)**[25] នៃក្រមនេះ។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០លានរៀល ទៅ ៥០លានរៀល។

បទប្បញ្ញត្តិពិសេសសម្រាប់បទល្មើសនីមួយៗ នឹងកំណត់ពីទោសបន្ថែម ដែលតុលាការអាចប្រកាសសម្រាប់បទល្មើសនោះ។ ក្នុងករណីបែបនេះ តុលាការមិនអាចប្រកាសទោសបន្ថែមណាផ្សេងបានឡើយ។ ជាក់ស្តែង មាត្រា ៣៣៦ នៃក្រមព្រហ្មទណ្ឌបានកំណត់ពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ចំពោះ **បទញុះញង់ឱ្យបោះបង់ទារក បទអន្តរការរវាងអ្នកសុំកូន និងអ្នកបោះបង់កូន និង រវាងអ្នកសុំកូន និងស្ត្រីពពោះ** ដោយតម្រូវឱ្យផ្តន្ទាទោសពិន័យជាប្រាក់ពី ១លានរៀល ទៅ ៥លានរៀលព្រមទាំងទោសបន្ថែមចំនួនត្រឹមតែ ៦ចំណុចប៉ុណ្ណោះរួមមាន ៖

**១**-ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ នៃក្រមនេះ។

**២**-ការហាមឃាត់ ចំពោះការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ នៃក្រមនេះ។

**៣**-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ នៃក្រមនេះ។

**៤**-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ និងមាត្រា ១៧៩ នៃក្រមនេះ។

**៥**-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយ មាត្រា ១៨០ នៃក្រមនេះ។

**៦**-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ នៃក្រមនេះ។[26]

ក្នុងន័យនេះ ចៅក្រមមិនអាចប្រកាសទោសបន្ថែមផ្សេង ក្រៅពីទោសបន្ថែមទាំង ៦ ដែលបានរៀបរាប់ខាងលើឡើយ សម្រាប់បទល្មើសនេះ។

---

[23] មាត្រា ២៣០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[24] មាត្រា ២២៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[25] មាត្រា ២២៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[26] មាត្រា ៣៣៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

### ៤.៣.១. ដំណើរការនីតិវិធីប្រឆាំងនឹងនីតិបុគ្គល

នីតិបុគ្គល គឺជាបុគ្គលដែលកើតឡើងពីការសន្មតរបស់ច្បាប់ ហើយរាល់សកម្មភាពរបស់នីតិបុគ្គលមែងធ្វើឡើងតាមរយៈអ្នកតំណាងជានិច្ច ដោយមូលហេតុថា នីតិបុគ្គលមិនមានរូបរាងដូចជារូបវន្តបុគ្គលទេ។ ហេតុដូច្នេះ ការចោទប្រកាន់ប្រឆាំងនឹងនីតិបុគ្គល ត្រូវធ្វើឡើងតាមរយៈអ្នកតំណាងស្របច្បាប់ក្នុងពេលធ្វើការចោទប្រកាន់នោះ[27] ដូចជាអភិបាលក្រុមហ៊ុនជាដើម ដែលជាអ្នកតំណាងឱ្យនីតិបុគ្គលក្នុងការបំពេញគ្រប់កិច្ចទាំងអស់នៃនីតិវិធី។ ដូច្នេះ ដីកាកោះហៅ និងសេចក្តីសម្រេចទាំងឡាយនឹងត្រូវបញ្ជូនទៅឱ្យ ឬក៏ឱ្យដំណឹងទៅនីតិបុគ្គល ដោយធ្វើតាមរយៈអ្នកតំណាងស្របច្បាប់របស់នីតិបុគ្គលនោះ។ ប្រសិនបើអ្នកតំណាងស្របច្បាប់មានធុរៈ ព្រះរាជអាជ្ញាអាចស្នើសុំដល់ប្រធានសាលាដំបូង ឱ្យចាត់តាំង អាណត្តិគាហក **(អ្នកតំណាង)** ម្នាក់ដើម្បីតំណាងឱ្យនីតិបុគ្គល។ ម្យ៉ាងវិញទៀត អាណត្តិគាហកក៏ត្រូវចាត់តាំងដោយប្រធានសាលាដំបូងដែរ កាលបើនីតិបុគ្គល និងអ្នកតំណាងស្របច្បាប់របស់នីតិបុគ្គល ត្រូវបានចោទប្រកាន់ចំពោះអង្គហេតុដូចគ្នា ឬចំពោះអង្គហេតុទាក់ទងគ្នា។ ក្នុងករណីដូច្នេះ អ្នកតំណាងស្របច្បាប់របស់នីតិបុគ្គលជាអ្នកដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរជូនប្រធានសាលាដំបូង ដើម្បីឱ្យមានការចាត់តាំងអាណត្តិគាហកដូចខាងលើនេះ។

អ្នកតំណាងស្របច្បាប់របស់នីតិបុគ្គលដែលតំណាងឱ្យនីតិបុគ្គលនៅក្នុងដំណើរការនីតិវិធី គឺមិនមែនជាជនត្រូវចោទ ឬជនជាប់ចោទនោះទេ ដូច្នេះអ្នកតំណាងនេះមិនអាចទទួលរងនូវវិធានការបង្ខំណាមួយឡើយ។ ក៏ប៉ុន្តែវិធានការដែលអាចយកមកអនុវត្តចំពោះសាក្សី អាចយកមកប្រើប្រាស់ចំពោះអ្នកតំណាង ស្របច្បាប់របស់នីតិបុគ្គលបាន។[28] ហេតុដូច្នេះ វិធានការបង្ខំដូចមានចែងនៅមាត្រា ១៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអនុញ្ញាតឱ្យចៅក្រមស៊ើបសួរ បញ្ជាឱ្យកងកម្លាំងសាធារណៈបង្ខំឱ្យសាក្សីរឹងទទឹងឱ្យចូលមកបង្ហាញខ្លួនដោយចេញ **បញ្ជាឱ្យចូលមកបង្ហាញខ្លួន** គឺអាចយកមកអនុវត្តបានចំពោះអ្នកតំណាងរបស់នីតិបុគ្គលនៅ ក្នុងនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងនីតិបុគ្គលនោះ។[29]

## ៥.១. និយមន័យ និងការទទួលខុសត្រូវរបស់អនីតិជន

អនីតិជន គឺជាជនដែលមានអាយុក្រោម ១៨ឆ្នាំ។ ជាទូទៅយើងដឹងហើយថា ជនដែលមានអាយុក្រោម ១៨ឆ្នាំ គឺមិនទាន់មានការគិតត្រឹមត្រូវនៅឡើយទេ ដោយសារតែនៅមានភាពវ័យក្មេងដែលការគិតនៅខ្លី ជាហេតុធ្វើឱ្យក្មេងអាយុក្រោម ១៨ឆ្នាំ ទន្ទឹមនឹងនោះអាចឆាប់បង្កើតនូវបទល្មើសដែលផ្ទុយទៅនឹងច្បាប់កំណត់ ដោយសារតែកម្រិតនៃការយល់ដឹងនៅមិនទានជ្រៅជ្រះនៅឡើយ។

[27] មាត្រា ៥៩៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[28] មាត្រា ៦០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[29] ចំពោះកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការដែលអាចប្រកាសបានចំពោះនីតិបុគ្គល មានចែងនៅមាត្រា ៦០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ជាគោលការណ៍ គេមិនអាចឱ្យជនដែលមិនដឹងខុសត្រូវពីភាពធ្ងន់ធ្ងរនៃអំពើរបស់ខ្លួនឱ្យទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ការយល់ដឹងខុសត្រូវ គឺជាកត្តាមួយដែលនាំឱ្យបុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។ ប្រសិនបើក្មេងអាយុ ៥ឆ្នាំ ម្នាក់បានចាក់សម្លាប់ក្មេងម្នាក់ទៀត ក្មេងដែលបានប្រព្រឹត្តអំពើល្មើសមិនអាច ទទួលខុសត្រូវព្រហ្មទណ្ឌបានទេ ដោយសារតែក្មេងអាយុ ៥ឆ្នាំ នោះមិនមានសមត្ថភាពដឹងខុសត្រូវពីអំពើរបស់ខ្លួនឡើយ។ ដោយឡែក ចំពោះអនីតិជនដែលមានអាយុ ១៥ឆ្នាំវិញ ការអះអាងថា អនីតិជននោះមិនដឹងខុសត្រូវទាល់តែសោះនោះ គឺជាអំណះអំណាងមួយដែលពិបាកនឹងទទួលយកបាន។ យ៉ាងណាមិញ មាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ កំណត់នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺនៅត្រឹមអាយុ ១៨ឆ្នាំ បានន័យថា អនីតិជនដែលមានអាយុតិចជាង ១៨ឆ្នាំ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។[30]

ថ្វីត្បិតតែអនីតិជនមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ក៏ប៉ុន្តែទន្ទឹមនឹងនោះ ក្រមព្រហ្មទណ្ឌតម្រូវឱ្យមានវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភសម្រាប់អនីតិជនដែលប្រព្រឹត្តបទល្មើស។ ហេតុដូច្នេះប្រសិនបើអនីតិជនបានប្រព្រឹត្តបទល្មើស ជាគោលការណ៍ត្រូវប្រើវិធានការតាមដាន អប់រំ ការពារ និងឧបត្ថម្ភចំពោះអនីតិជននោះ ព្រមទាំងវិធានការផ្សេងទៀតដែលមិនមែនជាការផ្តន្ទាទោស។ មិនត្រឹមតែប៉ុណ្ណោះ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ ក្រមព្រហ្មទណ្ឌអនុញ្ញាតឱ្យតុលាការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ឡើងទៅបាន ដោយអនីតិជនត្រូវតែទទួលការផ្តន្ទាទោសដោយឡែក។

### ៥.១.១. វិធានការអនុវត្តចំពោះអនីតិជនក្រៅពីទោស

មាត្រា ៤០ នៃក្រមព្រហ្មទណ្ឌ បានរៀបរាប់ពីវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភដែលជាធម្មតាត្រូវយកមកអនុវត្តលើអនីតិជនដែលបានប្រព្រឹត្តបទល្មើស រួមមានដូចតទៅ៖

**១**-ការប្រគល់អនីតិជនឱ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត។

**២**-ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន។

**៣**-ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន។

**៤**-ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស។

**៥**-ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។[31]

[30] មាត្រា ៩១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[31] មាត្រា ៤០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ក្នុងករណីដែលអនីតិជនបានប្រព្រឹត្តបទល្មើស ហើយត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ តុលាការចាត់តាំងបុគ្គលមួយរូបឱ្យទទួលភារៈធ្វើការតាមដានអនីតិជនរូបនោះ។ បុគ្គលរូបនេះមានភារកិច្ចត្រូវតែធ្វើរបាយការណ៍ស្តីពីកិរិយាមារយាទរបស់អនីតិជនឱ្យបានជាទៀងទាត់ជូនដល់ព្រះរាជអាជ្ញា។ បុគ្គលនេះត្រូវផ្តល់ព័ត៌មានដល់ព្រះរាជអាជ្ញាពីព្រឹត្តិការណ៍ទាំងអស់ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ។[32]

តាមខ្លឹមសារនៃមាត្រា ៣៩ មាត្រា ៤០ និងមាត្រា ៤១ នៃក្រមព្រហ្មទណ្ឌតុលាការជាស្ថាប័នមានសមត្ថកិច្ចក្នុងការចាត់វិធានការ ដែលបានរៀបរាប់នៅ មាត្រា ៤០ នៃក្រមព្រហ្មទណ្ឌ ក៏ប៉ុន្តែក្រមព្រហ្មទណ្ឌក៏ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌ ពុំបានចែងលម្អិតអំពីនីតិវិធីពិសេស សម្រាប់ការចាត់វិធានការទាំងអស់នេះឱ្យមានប្រសិទ្ធភាពនោះទេ។

ដោយឡែក ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០១៦ បាន ចែងពីវិធានការថ្មីមួយប្រភេទហៅថា **ការបង្វែរ** ដែលអាចសម្រេចបានដោយតំណាងអយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះនៃសាលាដំបូង និងក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍[33] សម្រាប់អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ។ យោងតាមច្បាប់នេះការបង្វែរអនីតិជនអាចធ្វើទៅបាន លុះត្រាតែបានបំពេញនូវលក្ខខណ្ឌអប្បបរមាដូចតទៅ ៖

- មានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ ឬបង្ហាញអំពីពិរុទ្ធភាព (**ភាពមានកំហុស**) របស់អនីតិជន។

- អនីតិជនសារភាពទទួលកំហុសដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ និងមានការសុំទោសជនរងគ្រោះ។

- បទល្មើសដែលបានប្រព្រឹត្តជាបទលហុ ឬបទមជ្ឈិម។

- អនីតិជនយល់ព្រមឱ្យធ្វើការបង្វែរ បន្ទាប់ពីបានទទួលការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬមេធាវីអំពីសិទ្ធិរបស់អនីតិជន និងពិចារណាផងដែរអំពីអានុភាព និងផលប៉ះពាល់នៅពេលអនុវត្តវិធានបង្វែរ។

ក្នុងករណីដែលសម្រេចថាត្រូវបង្វែរ វិធានមួយ ឬច្រើន អាចត្រូវសម្រេចឱ្យអនីតិជនបំពេញជាកាតព្វកិច្ចពោលគឺ ៖

- ចំណុចមួយ ឬច្រើនដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌស្តីពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ។ យោងតាមមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ មានចំនួន ១២ចំណុច រួមមានដូចខាងក្រោម ៖

- មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ។

---

[32] មាត្រា ៤១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[33] មាត្រា ៦០ ដល់មាត្រា ៧១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

- មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

- មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ។

- ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

- ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

- ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ។

- មិនត្រូវបើកបររថយន្ត។

- មិនត្រូវទទួល ឬ ជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ។

- ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងថិរវេលាបង់ប្រាក់នេះ ត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ។

- មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់។

- ត្រូវប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុ ដាក់ឱ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ។

- មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។[34]

• ទៅសាលារៀនឱ្យបានទៀងទាត់តាមផែនការកំណត់មិនលើសពី ៦ខែ

• ចំណាយពេលវេលាជាក់លាក់ជាមួយក្រុមគ្រួសារមិនលើសពី ៦ខែ

• តម្រូវឱ្យចូលរួមក្នុងការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងថិរវេលាមិនលើសពី ៦ខែ

• ធ្វើការងារសហគមន៍ដោយមិនលើសពី ១០០ម៉ោង។វិធានការនេះអាច ប្រើប្រាស់បានសម្រាប់តែអនីតិជនដែលមានអាយុចាប់ពី ១៦ឆ្នាំ ឡើងទៅ ហើយមានលក្ខណៈជាការងារបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ

• ចូលរួមក្នុងកម្មវិធីសហគមន៍ ឬមណ្ឌលដែលមានអត្ថប្រយោជន៍ សម្រាប់ជួយអនីតិជនមិនឱ្យប្រព្រឹត្តបទល្មើសសារជាថ្មី

• ឱ្យស្នាក់នៅទីកន្លែងណាមួយដោយកំណត់ពេលវេលាជាក់លាក់

• ជួសជុលសំណងការខូចខាតទៅជនរងគ្រោះ

[34] មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

•វិធានការសមស្របផ្សេងទៀតដែលបំពេញនូវគោលបំណងនៃការបង្វែរ។

ភ្នាក់ងារសង្គមកិច្ច និង បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវធានារ៉ាប់រងអនុវត្តសេចក្តីសម្រេច និងផែនការបង្វែរក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើអនីតិជនដែលត្រូវអនុវត្តផែនការបង្វែរ។ បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលជោគជ័យ ឬបរាជ័យ ឬឧបសគ្គដែលកើតមាននៅក្នុងការអនុវត្តផែនការខាងលើទៅភ្នាក់ងារសង្គមកិច្ច ហើយបន្ទាប់មកភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនរបាយការណ៍ និងយោបល់របស់ខ្លួនទៅអាជ្ញាធរទទួលបន្ទុកបង្វែរ ( **តំណាងអយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះ ឬក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍**)។

ក្នុងករណីដែលអនីតិជនមិនបានគោរពតាមកាតព្វកិច្ចនៅក្នុងវិធានការបង្វែរ នោះគឺជាបរាជ័យក្នុងការអនុវត្តវិធានការបង្វែរ។ ក្នុងករណីយ៉ាងដូច្នោះ អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវកោះហៅអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងភ្នាក់ងារសង្គមកិច្ច បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ និងមេធាវីរបស់អនីតិជនប្រសិនបើមានឱ្យចូលមកបង្ហាញខ្លួនក្នុងចិរវេលាមិនលើសពី ១៥ថ្ងៃ ដើម្បីសាកសួរពីមូលហេតុដែលអនីតិជនមិនគោរពតាមវិធានការបង្វែរ។ បន្ទាប់ពីបានពិចារណា និងពិគ្រោះយោបល់ជាមួយនឹងភ្នាក់ងារសង្គមកិច្ច អាជ្ញាធរទទួលបន្ទុកបង្វែរអាចចេញដីកាបង្វែរថ្មី ឬបន្តចាត់ការតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

យ៉ាងណាមិញ ប្រសិនបើការអនុវត្តផែនការបង្វែរទទួលបានជោគជ័យ អាជ្ញាធរទទួលបន្ទុកបង្វែរ នៅតាមដំណាក់កាលនៃនីតិវិធីនីមួយៗត្រូវសម្រេចចេញ **ដីកាតម្កល់រឿងទុកឥតចាត់ការ**[35] **(បើអាជ្ញាធរទទួលបន្ទុកបង្វែរគឺជាតំណាងអយ្យការ)** ដីកាដំណោះស្រាយលើកលែងចោទប្រកាន់[36] **(បើអាជ្ញាធរទទួលបន្ទុកបង្វែរ គឺជាចៅក្រមស៊ើបសួរ)** សាលក្រម ឬសាលដីកាសម្រេចឱ្យអនីតិជនមិនទទួលខុសត្រូវព្រហ្មទណ្ឌ[37] **(បើអាជ្ញាធរទទួលបន្ទុកបង្វែរ គឺជាតុលាការជំនុំជម្រះ នៅសាលាដំបូង ឬសាលាឧទ្ធរណ៍)**។ **ឧទាហរណ៍ ៖** ពិសី ភេទប្រុស អាយុ ១៦ ឆ្នាំ បានប្រព្រឹត្តអំពើលួច ហើយត្រូវបានឃាត់ខ្លួន និងបន្ទាប់មកទៀត ត្រូវបានបញ្ជូនមកតំណាងអយ្យការ។ ក្នុងករណីដូចនេះ តំណាងអយ្យការអាចចាត់វិធានការបង្វែរបាន ប្រសិនបើមានភស្តុតាងគ្រប់គ្រាន់ ដើម្បីចោទប្រកាន់លើ ពិសី ពីបទលួច ដែលជាបទមជ្ឈិម ហើយ ពិសី ក៏បាន សារភាពទទួលកំហុស និងសុំទោសជនរងគ្រោះ ព្រមទាំងមានការយល់ព្រមរបស់ ពិសី ក្នុងការទទួលយកវិធានការបង្វែរ។ តំណាងអយ្យការអាចចាត់វិធានការ ដូចជាតម្រូវឱ្យ ពិសី ត្រូវទៅសាលារៀនឱ្យបានទៀងទាត់តាមផែនការកំណត់មិនលើសពី ៦ខែ។ ប្រសិនបើ

[35] មាត្រា ២៨ កថាខណ្ឌទី៥ នៃច្បាប់ស្តីយុត្តិធម៌អនីតិជន

[36] មាត្រា ៣៨ កថាខណ្ឌទី៣ នៃច្បាប់ស្តីយុត្តិធម៌អនីតិជន

[37] មាត្រា ៥២ កថាខណ្ឌទី៨ និងមាត្រា ៥៨ នៃច្បាប់ស្តីយុត្តិធម៌អនីតិជន

ពិសី បានអនុវត្តតាមវិធានការនេះបានយ៉ាងត្រឹមត្រូវនោះតំណាងអយ្យការនឹងចេញ ដីកាតម្កល់រឿងទុកឥតចាត់ការ ចំពោះបទល្មើសដែល ពិសី បានប្រព្រឹត្ត។

### ៥.២.១. ទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជន

មុននឹងប្រកាសទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជន តុលាការត្រូវកំណត់ពីអាយុរបស់អនីតិជនឱ្យបានច្បាស់លាស់។ យោងតាមមាត្រា ៩ នៃច្បាប់ស្តីពី យុត្តិធម៌អនីតិជន បញ្ជាក់ឱ្យឃើញថា អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន កំណត់យកអាយុនៅពេលដែលអនីតិជននោះប្រព្រឹត្តបទល្មើស។ ចំណែកភស្តុតាងនៃអាយុរបស់អនីតិជន ត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារផ្សេងទៀតដែលអាចបញ្ជាក់បានអំពីកំណើត។ នៅក្នុងករណីពុំមានឯកសារនោះ ភស្តុតាងនៃអាយុរបស់អនីតិជនអាចផ្តល់តាមគ្រប់មធ្យោបាយផ្សេងទៀតដែលអាជ្ញាធរតុលាការអាចជឿទុកចិត្តបាន។ នៅក្នុងករណីមានការសង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវជាប្រយោជន៍ដល់អនីតិជននោះ។

ក្រមព្រហ្មទណ្ឌក៏ដូចជាច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែរ បានកំណត់អាយុចាប់ពី ១៤ឆ្នាំ រហូតដល់ក្រោម ១៨ឆ្នាំ ដើម្បីអាចឱ្យតុលាការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌបាន។[38] នៅត្រង់ចំណុចនេះ ក្រមព្រហ្មទណ្ឌមានភាពខុសប្លែកបញ្ញត្តិនៃច្បាប់ចាស់ដែលបានអនុវត្តកន្លងមក ដោយកំណត់យកអាយុត្រឹម ១៣ឆ្នាំមក ធ្វើជាមូលដ្ឋាននៃការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌ។ ទណ្ឌកម្មព្រហ្មទណ្ឌដែលក្រមព្រហ្មទណ្ឌសំដៅដល់គឺ **ទោស** នេះឯងតែម្តង។ ជាក់ស្តែង ការកំណត់យកអាយុ ១៤ ឆ្នាំ សម្រាប់លទ្ធភាពនៃការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌ គឺមានភាពសមស្របទៅនឹងបទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអនុញ្ញាតឱ្យឃុំខ្លួនជាបណ្តោះអាសន្ន ចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ក្នុងលក្ខខណ្ឌកំណត់ដោយច្បាប់ និងក្នុងថិរវេលាមួយតិចជាងការឃុំខ្លួនបណ្តោះអាសន្នលើនីតិជន។[39] ចំណែកឯអនីតិជនអាយុក្រោម ១៤ ឆ្នាំ វិញ មិនអាចត្រូវទទួលរងនូវការផ្តន្ទាទោសណាមួយឡើយ បើទោះបីជាអនីតិជននោះបានប្រព្រឹត្តបទល្មើសប្រភេទណាមួយក៏ដោយ[40] ក៏ប៉ុន្តែតុលាការអាចចាត់នូវវិធានការណាមួយដូចមានចែង នៅមាត្រា ៤០ នៃក្រមព្រហ្មទណ្ឌបាន។

ការប្រកាសទោសទៅលើអនីតិជនអាចធ្វើទៅបាន លុះត្រាណាកាលៈទេសៈ នៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។ ក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជនពុំបានកំណត់និយមន័យ ឬផ្តល់នូវលក្ខណៈវិនិច្ឆ័យនៃពាក្យ កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជន ដែលជា លក្ខខណ្ឌនៃការប្រកាសទោសទៅលើអនីតិជនឡើយ។ ក្នុងន័យនេះ តុលាការធ្វើការ វិនិច្ឆ័យទៅតាមរឿងក្តីនីមួយៗថា តើមានលក្ខខណ្ឌ

[38] មាត្រា ៧ នៃច្បាប់ស្តីយុត្តិធម៌អនីតិជន

[39] មាត្រា ២១៣ និងមាត្រា ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[40] មាត្រា ២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

តម្រូវឱ្យប្រកាសទោសទៅលើអនីតិជនដែរឬទេ។ ក្នុងករណីដែលអនីតិជនមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ បានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ កាចសាហាវ ដូចជាករណីប្រព្រឹត្ត បទឃាតកម្ម ជាដើម កាលៈទេសៈនៃការប្រព្រឹត្តបទល្មើសនេះអាចជាមូលហេតុឱ្យតុលាការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជនបាន។ ផ្ទុយទៅវិញ ក្នុងករណីដែលអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ បានលួចស្បែកជើងមួយគូ តើកាលៈទេសៈនៃការប្រព្រឹត្តបទល្មើសនេះ តម្រូវឱ្យតុលាការប្រកាសទោសលើអនីតិជនបានដែរឬទេ ? នេះជាចំណោទគតិយុត្តិមួយដែលនឹងត្រូវដោះស្រាយដោយយុត្តិសាស្ត្រនៃតុលាការកម្ពុជា។

ក្រមព្រហ្មទណ្ឌបានកំណត់យ៉ាងជាក់លាក់នូវទោស ដែលអាចអនុវត្តចំពោះអនីតិជនបានកាលណាតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជន។ តាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌមូលទោសលើបទល្មើសចោទប្រកាន់ដែលត្រូវយកមកអនុវត្តលើអនីតិជន ត្រូវតែបន្ថយនៅក្នុងលក្ខខណ្ឌមានកំណត់ខាងក្រោម ៖

- អតិបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល។

- ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារគឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្របន្ថយមកដាក់ពន្ធនាគារ ២០ឆ្នាំ។

- អប្បបរមានៃទោសដាក់ពន្ធនាគារត្រូវ បន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ថ្ងៃ។

- អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល។ **ឧទាហរណ៍ ៖** បទរំលោភសេពសន្ថវៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ តាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។ ប្រសិនបើជនល្មើសជាអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ មាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌតម្រូវឱ្យបន្ថយមូលទោសលើបទល្មើសដែលត្រូវចោទប្រកាន់ ពោលគឺអតិបរមានៃទោស (១០ឆ្នាំ) ត្រូវបន្ថយពាក់កណ្តាល មកនៅត្រឹម ៥ឆ្នាំ ចំណែកឯអប្បបរមានៃទោសវិញគឺ (៥ឆ្នាំ មានន័យថាលើសពី ១ថ្ងៃ) ក៏ត្រូវបន្ថយពាក់កណ្តាលដែរ គឺមកនៅត្រឹម ២ឆ្នាំ និង ៦ខែ។ ដូច្នេះមានន័យថា នៅពេលដែលជនល្មើសជាអនីតិជន ទោសដែលត្រូវផ្តន្ទា គឺជាការដាក់ពន្ធនាគារចាប់ពី ២ឆ្នាំ និង ៦ខែ ទៅ ៥ឆ្នាំ សម្រាប់ បទរំលោភសេពសន្ថវៈ។ និយាយម្យ៉ាងទៀតថា ទោសខាងលើនេះ គឺជាមូលទោស ចំពោះបទរំលោភសេពសន្ថវៈ ដែលអនុវត្តលើអនីតិជន។ ហេតុដូច្នេះ តុលាការ មិនអាចប្រកាសដាក់ទោសឱ្យជនជាប់ចោទជាអនីតិជនជាប់ពន្ធនាគារលើសពី ៥ឆ្នាំ បានឡើយ ពីព្រោះថា នេះគឺជាអតិបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់ជនជាប់ចោទជាអនីតិជន។

ក្នុងករណីដូចខាងលើនេះ ថ្វីត្បិតតែមូលទោសត្រូវបានបន្ថយក៏ដោយ ក៏បទរំលោភសេពសន្ថវៈប្រព្រឹត្តដោយអនីតិជន នៅតែត្រូវចាត់ទុកថាជាបទឧក្រិដ្ឋដដែល ពុំមែនក្លាយទៅជាបទមជ្ឈិមឡើយ។ **ឧទាហរណ៍ ៖** បទលួចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៦លានរៀល តាមមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។ ករណីដែលជនជាប់ចោទមានអាយុ ១៦ឆ្នាំ នោះអតិបរមានៃទោសត្រូវបន្ថយ

ពាក់កណ្តាល ដូច្នេះ ទោសដាក់ពន្ធនាគារចំនួន ៣ឆ្នាំ (អតិបរមា) ត្រូវបន្ថយមក នៅត្រឹម ១ឆ្នាំ ៦ខែ ចំណែកឯអប្បបរមានៃទោសដាក់ពន្ធនាគារវិញ ក៏ត្រូវបន្ថយពាក់កណ្តាល ដែរ ពោលគឺទោសដាក់ពន្ធនាគារចំនួន ៦ខែ (អប្បបរមា) ត្រូវតែបន្ថយមកនៅត្រឹម ៣ខែ។ ដោយឡែក ចំពោះទោសពិន័យជាប្រាក់អប្បបរមា និងអតិបរមានៃទោសក៏ត្រូវបន្ថយពាក់កណ្តាលដែរ បានសេចក្តីថា ត្រូវបន្ថយមកនៅត្រឹមទោសពិន័យជាប្រាក់ចាប់ពី ៥សែនរៀល ទៅ ៣លានរៀល។

សរុបសេចក្តីមក មូលទោសនៃបទលួចដែលត្រូវអនុវត្តទៅលើអនីតិជន គឺទោសដាក់ពន្ធនាគារពី ៣ខែ ទៅ ១ឆ្នាំ ៦ខែ និងទោសពិន័យជាប្រាក់ពី ៥សែនរៀល ទៅ ៣លានរៀល។

ជាងនេះទៅទៀត បទប្បញ្ញត្តិដែលផ្តល់ភាពអនុគ្រោះចំពោះអនីតិជន ក៏ត្រូវបានកំណត់ដោយឡែកបន្ថែមទៀត ជាពិសេសរួមមាន បញ្ញត្តិទាក់ទងនឹង ការមិនរាងចាល ទោសបន្ថែម ទោសជំនួស ស្ថានសម្រាលទោស និងការព្យួរទោសជាដើម ដែលនឹងត្រូវលើកយកមកពិភាក្សាបកស្រាយនៅត្រង់ផ្នែកពាក់ព័ន្ធផ្សេងៗទៀតនៃសៀវភៅសិក្សានេះ។[41]

[41] មាត្រា ១៦១ ដល់មាត្រា ១៦៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវពីប្រធានបទខាងលើរួចមក យើងសង្កេតឃើញថា ជនល្មើសដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ទោះបីជនល្មើសនោះជា នីតិបុគ្គលក្តី អនីតិជនក្តី គឺត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌដោយឡែកបើយើងក្រឡេកទៅមើលមាត្រា ៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនវិញ បញ្ជាក់ឱ្យឃើញថា អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ត្រូវកំណត់យកអាយុនៅពេលដែលអនីតិជននោះប្រព្រឹត្តបទល្មើស ដោយត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារផ្សេងៗទៀតដែលអាចបញ្ជាក់បានអំពីកំណើត។ ជាទូទៅយើងដឹងហើយថា អនីតិជនអាយុចាប់ពី ១៤ឆ្នាំ រហូតដល់ក្រោម ១៨ឆ្នាំ អាចឱ្យតុលាការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌបាន ហើយទណ្ឌកម្មព្រហ្មទណ្ឌ ដែលក្រមព្រហ្មទណ្ឌសំដៅដល់គឺ **ទោស** នេះឯងតែម្តង។ ចំណែកឯអនីតិជនអាយុក្រោម ១៤ឆ្នាំវិញ មិនអាចត្រូវទទួលរងនូវការផ្តន្ទាទោសណាមួយឡើយ បើទោះបីជាអនីតិជននោះបានប្រព្រឹត្តបទល្មើសប្រភេទណាក៏ដោយ ក៏ប៉ុន្តែតុលាការអាចចាត់នូវវិធានការណាមួយដូចមានចែងនៅមាត្រា ៤០ នៃក្រមព្រហ្មទណ្ឌ។ ដោយឡែកចំពោះនីតិបុគ្គលវិញ ក៏មានច្បាប់ចែងពីការទទួលខុសត្រូវផងដែរ ដោយមាត្រា ៤២ នៃក្រមព្រហ្មទណ្ឌ នីតិបុគ្គលអាចត្រូវប្រកាសថាទទួលខុសត្រូវព្រហ្មទណ្ឌបាន លុះត្រាតែមានច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតចែងទុកជាមុន ហើយជាងនេះទៅទៀត បទល្មើសត្រូវប្រព្រឹត្តដោយអង្គការ ឬដោយអ្នកតំណាងរបស់នីតិបុគ្គល ដើម្បីផ្តល់នូវអត្ថប្រយោជន៍ដល់នីតិបុគ្គលនោះ មានន័យថា ការប្រព្រឹត្តបទល្មើស ដើម្បីជាប្រយោជន៍ដល់នីតិបុគ្គលតែប៉ុណ្ណោះ ដែលជាកត្តាធ្វើឱ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌបាន នៅត្រង់ចំណុចនេះ ប្រយោជន៍ គឺសំដៅទៅលើផលប្រយោជន៍ខាងសេដ្ឋកិច្ចដែលមានលក្ខណៈច្បាស់លាស់ ឬគ្រាន់តែមានលក្ខណៈជាយថាហេតុក៏បានដែរទន្ទឹមនឹងនោះបទល្មើសដែលប្រព្រឹត្តដោយអ្នកតំណាងរបស់នីតិបុគ្គល ប៉ុន្តែបានធ្វើឡើងក្នុងផលប្រយោជន៍ផ្ទាល់ខ្លួនរបស់អ្នកតំណាង នោះគឺប្រាកដជាមិនអាចឱ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

សរុបសេចក្តីមក នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមាត្រា ៣៨ បានកំណត់ថា ការទទួលខុសត្រូវព្រហ្មទណ្ឌបាន លុះត្រាតែមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ដោយហេតុថាអាយុក្រោម ១៨ ឆ្នាំ គឺជាអនីតិជន ដូចនេះការយល់ដឹងរបស់ពួកគេនៅមានភាពខ្វះខាតនៅឡើយ ប៉ុន្តែប្រសិនជាអនីតិជនបានប្រព្រឹត្តិបទល្មើសអ្វីមួយនោះ វិធានការអនុវត្តចំពោះអនីតិជនគឺមានតែ វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភតែប៉ុណ្ណោះ ប៉ុន្តែចំណុចនេះអាចមានភាពពិបាក ដោយហេតុថា ក្នុងករណីដែលមានអនីតិជនអាយុក្រោម១៨ឆ្នាំ ប្រព្រឹត្តបទល្មើសដែលមានស្ថានទម្ងន់ទោសធ្ងន់ធ្ងរណាមួយ។ ក៏ប៉ុន្តែនៅក្នុងមាត្រា៣៩ បានបញ្ញត្តិបន្ថែមថា តុលាការអាចប្រកាសទណ្ឌកម្ម ព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅបាន ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ មានន័យថា អនីតិជនអាយុ

១៤ ឆ្នាំដល់ ១៨ ឆ្នាំអាចនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើរបស់ខ្លួនប្រសិន កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ ហើយចំពោះនីតិបុគ្គលវិញ ការតម្រូវឱ្យនីតិបុគ្គលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាភាពចាំបាច់នៅក្នុងបរិបទសង្គមជាក់ស្តែង ទន្ទឹមនឹងនេះ អ្នកនីតិបញ្ញត្តិក៏ធ្វើការសម្របសម្រួលពីទោសដែលត្រូវអនុវត្តលើនីតិបុគ្គល ដែលជាបុគ្គលបង្កើតឡើងពីការសន្មតដោយច្បាប់ផងដែរ។

# អនុសាសន៍

# អនុសាសន៍

យើងខ្ញុំទាំងពីរនាក់ បានធ្វើការស្រាវជ្រាវទៅលើប្រធានបទទាក់ទងនឹងជនល្មើសនៅក្នុងរឿងព្រហ្មទណ្ឌ ឃើញថាពិតជាមានសារៈប្រយោជន៍ ព្រមទាំងមាននូវគុណប្រយោជន៍ជាច្រើន ប៉ុន្តែក៏បានលេចឡើងនូវចំណុចខ្វះខាតមួយចំនួនផងដែរ។ បញ្ហាកង្វះខាតធនធានទាក់ទងសម្ថតភាពខាងផ្លូវច្បាប់ដូចជាបច្ចេកទេស ឧបករណ៍ស្រាវជ្រាវ ការធ្វើកោសល្យវិច្ច័យ ការយកចិត្តទុកដាក់ក្នុងពេលបំពេញតួនាទីនៅមិនទាន់មានភាពប្រសើរនៅឡើយ មានចំណុចអសកម្មផ្សេងៗ ពាក់ព័ន្ធនឹងគោលការណ៍អនុវត្តច្បាប់ផ្សេងៗ មិនទាន់មានអនុវត្តពេញលេញក៏ដូចការអនុវត្តច្បាប់នៅមានកម្រិត ការបកស្រាយអត្ថបទច្បាប់នៅមិនទាន់មិនទាន់ភាពពេញលេញនៅឡើយ ដែលជាហេតុធ្វើអោយមានចន្លោះប្រហោងរាំងស្ទះដំណើរការក្នុងការបំពេញការងារ។ ដើម្បីជាចូលរួមចំណែកធ្វើអោយកាន់តែប្រសើឡើងក្នុងវិស័យយុត្តិធម៌ ក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែរីកលូតលាស់ទៅនឹងវិវត្តន៍ទៅកាន់ភាពរីកចំម្រើន បម្រើរាស្ត្រទាំងអោយភាពតម្លាភាពនៃយុត្តិធម៌ ស្របតាមបទដ្ឋានគិតយុត្តិផ្សេងៗដែលបានកំណត់ ជាពិសេសសិទ្ធក្នុងការការពារស្របច្បាប់ដែលជាចំណុចមួយសំខាន់ក្នុងការរស់នៅក៏ស្របទៅតាមការកំណត់របស់ច្បាប់ជាតិ លើសពីនេះថ្នាក់ដឹកនាំក្រសួងយុត្តិធម៌ មេត្តាចាត់វិធានការបន្ថែមដល់មន្ត្រីរាជការ គ្រប់ជាន់ថ្នាក់បន្តផ្សព្វផ្សាយ ក្រមព្រហ្មទណ្ឌនេះ ដល់ប្រជាពលរដ្ឋឲ្យបានដឹងកាន់តែច្បាស់ពីក្រម មួយនេះ ជាពិសេសស្ថាប័នតុលាការមេត្តាស៊ើបសួរ និងរកភស្តុតាងឲ្យបានច្បាស់លាស់ សិនមុននឹងធ្វើការជំនុំជម្រះ ដើម្បីជាភាពយុត្តិធម៌ដល់មហាជន។ បន្ថែមពីនេះរដ្ឋបាលថ្នាក់ក្រោមជាតិមេត្តាជួយចាត់វិធានការ ឬជួយសម្រួលដល់អាជ្ញាធរដែលមានសមត្ថកិច្ចក្នុងការផ្សព្វផ្សាយច្បាប់ និង រដ្ឋាភិបាល ក៏ដូចជាក្រសួងសាមីត្រូវសហការគ្រឹះស្ថានឧត្តមសិក្សា និងគ្រប់សាកលវិទ្យាល័យទាំងអស់គួរតែបញ្ចូល កម្មវិធីសិក្សាអំពីមុខវិជ្ជាច្បាប់ជាពិសេសពីក្រមព្រហ្មទណ្ឌនេះ ដល់សិស្ស និស្សិតដែលមកសិក្សានៅសាលារបស់ខ្លួន ត្រូវលើកទឹកចិត្តអ្នកដែលមានជំនាញខាងផ្លូវច្បាប់ អ្នកប្រកបវិជ្ជាជីវៈច្បាប់ដែលសរសេរសៀវភៅច្បាប់ដែលមានការបកស្រាយក្បោះក្បាយ ងាយយល់ ងាយចាប់បាន ដើម្បីឱ្យអ្នកដែលមិនចេះច្បាប់ចេះត្រឹមតែអានអក្សរ ក៏ដូចសិក្សានុសិស្ស អ្នកអាន អ្នកស្តាប់ អ្នកស្រាវជ្រាវអាចយល់បានកាន់តតែច្បាស់អំពីផ្លូវច្បាប់ មិនត្រឹមតែប៉ុណោះស្ថានីយ៍ទូរទស្សន៍ ស្ថានីយ៍វិទ្យុ ប្រព័ន្ធអ៊ីនធឺណែតបើកឱ្យមាននូវកម្មវិធីផ្តល់យោបល់ និងបកស្រាយផ្នែកជំនាញច្បាប់ ក្នុងគោលបំណងផ្សព្វផ្សាយអំពីវិស័យច្បាប់នៅកម្ពុជា ដើម្បីជាប្រយោជន៍ដល់អ្នកសិក្សាផ្នែកច្បាប់ ក៏ដូចជាអ្នកដែលមានបញ្ហាក្នុងវិស័យច្បាប់នេះផងដែរ។ បណ្តាប្រជាពលរដ្ឋកម្ពុជាគ្រប់រូប មេត្តាព្យាយាមសិក្សាស្វែងយល់អំពីច្បាប់ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ និងត្រូវតែទទួលយក និងជួយគ្នាអនុវត្តទាំងអស់គ្នា ជៀសវាងកុំអោយធ្លាក់លង់ទៅនឹងការប្រព្រឹត្តបទល្មើសក្លាយទៅជាជនល្មើសនាំត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីតុលាការ និងបណ្តាលអោយខូចប្រយោជន៍ និងពេលវេលាក៏ដូចជាក្រុមគ្រួសារ និងសង្គមជាតិទាំងមូល។

# ឯកសារយោង

## ឯកសារយោង

### ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត


1. ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើកាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩
2. ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើកាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧
3. ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើកាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
4. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
5. សន្ទានុក្រមផ្នែករដ្ឋប្បវេណី រៀបចំដោយ គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០០៧
6. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨
7. ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២
8. ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២
9. ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងប្រកាសលេខ ០៩ កយ.ប្រក/០៦ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៦ របស់ក្រសួងយុត្តិធម៌ ស្តីពី **នីតិវិធីនៃការប្រគល់ឱ្យមានការឃ្លាំមើល និងការញុះញង់ឱ្យលក់ដោយខុសច្បាប់**


### សៀវភៅ


10. សៀវភៅស្តីពីនីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត បោះពុម្ពឆ្នាំ២០១៧
11. សៀវភៅស្តីពីនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាតបោះពុម្ពឆ្នាំ២០២២
12. សៀវភៅស្តីពីនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ ហៀង ឡេង


### សារព័ត៌មាន និងហ្វេសប៊ុកផេក


13. ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ រៀបរៀងដោយលោកមេធាវី សេង ឈុនលី និងលោក វ៉ាត់ ចាន់ធី
14. សារព័ត៌មានជ្រេហ្គន និងកាសែតនគរវត្ត ចុះផ្សាយថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២១
15. សារព័ត៌មានកម្ពុជាថ្មី ចុះផ្សាយថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១
16. ហ្វេសប៊ុកផេក Khoun Naret-ឃួន ណារ៉េត ចុះផ្សាយថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១
17. ហ្វេសប៊ុកផេក ស្រី ពន្លក - Srey Ponlok ចុះផ្សាយថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩
18. សារព័ត៌មាន FRESH NEWS ចុះផ្សាយថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៨

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធទី ១ ៖ ក្រមរដ្ឋប្បវេណី**
- **ឧបសម្ព័ន្ធទី ២ ៖ ក្រមព្រហ្មទណ្ឌ**
- **ឧបសម្ព័ន្ធទី ៣ ៖ ក្រមនីតិវិធីព្រហ្មទណ្ឌ**
- **ឧបសម្ព័ន្ធទី ៤ ៖ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន**
- **ឧបសម្ព័ន្ធទី ៥ ៖ ករណីសិក្សា**

ឧបសម្ព័ន្ធទី ១

# ក្រមរដ្ឋប្បវេណី

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME du CAMBODGE • LE MINISTRE du PALAIS ROYAL •

## កថាភាគទី ២

## ជននៅក្រោមអាណាព្យាបាលទូទៅ

**មាត្រា ២៤.-** ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ

១-ចំពោះជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសាមីខ្លួនមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំនៅពេលដែលមានពាក្យសុំ ។

២-ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសាមីខ្លួនជាជននៅក្រោមហិតូបត្ថម្ភ តុលាការត្រូវលុបចោលការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភចំពោះជននោះ ។

**មាត្រា ២៥.-** អត្ថន័យនៃជននៅក្រោមអាណាព្យាបាលទូទៅ និង ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ

ជនដែលបានទទួលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ត្រូវហៅថា ជននៅក្រោមអាណាព្យាបាលទូទៅ ហើយត្រូវស្ថិតនៅក្រោមអ្នកអាណាព្យាបាលទូទៅ ។

**មាត្រា ២៦.-** សិទ្ធិលុបចោលសកម្មភាព

សកម្មភាពរបស់ជននៅក្រោមអាណាព្យាបាលទូទៅ អាចលុបចោលបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។

**មាត្រា ៧៤៦.-** ការទទួលខុសត្រូវរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យ

១-បុគ្គលដែលមានករណីយកិច្ចដែលបានកំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ឬ បុគ្គលដែលស្ថិតក្នុងស្ថានភាពដែលមិនអាចយល់ដឹង និង វិនិច្ឆ័យបានអំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ឬ មូលហេតុផ្សេងទៀត មានករណីយកិច្ចត្រូវសងការខូចខាតរបស់អ្នកដទៃ ដែលកើតឡើង ដោយអំពើបំពានរបស់បុគ្គលនៅក្រោមការត្រួតពិនិត្យរបស់ខ្លួននេះ ។

២-បុគ្គលដែលមានករណីយកិច្ចដែលបានកំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពជាមួយអនីតិជន ចំពោះការខូចខាតរបស់អ្នកដទៃដែលកើតឡើង ដោយអំពើអនីត្យានុកូលរបស់អនីតិជននោះ ។

៣-បុគ្គលដែលមានករណីយកិច្ចត្រួតពិនិត្យដែលទទួលខុសត្រូវក្នុងការសងការខូចខាត តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ អាចរួចខ្លួនពីការទទួលខុសត្រូវក្នុងការសងការខូចខាតបាន ដោយបញ្ជាក់បង្ហាញថា ខ្លួនបានបំពេញករណីយកិច្ចត្រួតពិនិត្យជាប្រក្រតី ។

**មាត្រា ៧៤៧.-** ការទទួលខុសត្រូវរបស់និយោជក

១-បុគ្គលដែលប្រើនិយោជិតដើម្បីអនុវត្តកិច្ចការ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលនិយោជិតបានបង្កដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា នៅក្នុងការអនុវត្តកិច្ចការនោះ ។

២-បុគ្គលដែលស្ថិតក្នុងឋានៈត្រូវត្រួតពិនិត្យនិយោជិតជំនួសនិយោជក ត្រូវទទួលខុសត្រូវដូចគ្នានឹងនិយោជកដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះបានត្រួតពិនិត្យដោយត្រឹមត្រូវ ។

៣-និយោជក ឬ អ្នកត្រួតពិនិត្យជំនួស អាចទាមទារសំណងពីនិយោជិតបាន ដោយយោងទៅតាមកម្រិតនៃកំហុសរបស់និយោជិតនោះ ។

ឧបសម្ព័ន្ធទី ២

# ក្រមព្រហ្មទណ្ឌ

**ព្រះរាជក្រម**

**នស/រកម/១១០៩/០២២**

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១៩៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៦ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

**មាត្រា ១៨.-** ការកំណត់បទល្មើសប្រព្រឹត្តដោយនីតិបុគ្គល

ការដាក់ឈ្មោះបទល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គលថាជា បទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ត្រូវកំណត់ដោយទណ្ឌកម្មដែលទទួលរងដោយរូបវន្តបុគ្គល ។

## ផ្នែកទី ២
## បទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១៩.-** បទឧក្រិដ្ឋ ឬបទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទមជ្ឈិមដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរ នៅក្នុងប្រទេសក្រៅណាមួយ ប្រសិនបើអំពើនោះត្រូវបានផ្តន្ទាទោសតាមច្បាប់នៃប្រទេសនោះផងដែរ។

បទប្បញ្ញត្តិទាំងនេះត្រូវអនុវត្តផងដែរ ទោះបីជាជនជាប់ចោទបានទទួលសញ្ជាតិខ្មែរក្រោយអំពើដែលចោទប្រកាន់នេះក៏ដោយ ។

**មាត្រា ២០.-** ជនរងគ្រោះជាជនជាតិខ្មែរ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវបានអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពលរដ្ឋខ្មែរ ឬដោយជនបរទេស ទៅលើជនរងគ្រោះដែលមានសញ្ជាតិខ្មែរ នៅក្នុងពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

**មាត្រា ២១.-** ការផ្ញើបណ្តឹងចោទប្រកាន់

នៅក្នុងករណីដែលមានចែងនៅក្នុងមាត្រា ១៩ (បទឧក្រិដ្ឋ ឬបទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ) និងមាត្រា ២០ (ជនរងគ្រោះជាជនជាតិខ្មែរ) នៃក្រមនេះ ការចោទប្រកាន់អាចប្រព្រឹត្តទៅបានតាមបណ្តឹងរបស់អយ្យការតែប៉ុណ្ណោះ ។ ការ

ប៉ុន្តែ ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីជាក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ :

១-ជនល្មើសនោះបានប្រព្រឹត្តអំពើដែលបញ្ញត្ត អនុញ្ញាត ឬមិនហាមឃាត់ដោយច្បាប់ជាធរមាន ។

២-បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ ។

**មាត្រា ៣៣.-** ការការពារស្របច្បាប់

បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ

-បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និង

-គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន ។

**មាត្រា ៣៤.-** សច្ចធារណ៍នៃការការពារស្របច្បាប់

ត្រូវសន្មតថាជាការការពារស្របច្បាប់ នៅក្នុងករណីដូចតទៅ :

១-បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ ។

២-បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា ។

សច្ចធារណ៍នៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ ។ សច្ចធារណ៍នេះ អាចត្រូវរំលាយដោយភស្តុតាងផ្ទុយ ។

**មាត្រា ៣៩.-** វិធានការអនុវត្តចំពោះអនីតិជន

អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ។

ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ ។

**មាត្រា ៤០.-** ប្រភេទនៃវិធានការ

វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភមានដូចតទៅ :

១-ការប្រគល់អនីតិជនឱ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត ។

២-ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន ។

៣-ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន ។

៤-ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស ។

៥-ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ ។

**មាត្រា ៤១.-** ការដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ

ក្នុងករណីដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន ។ បុគ្គលនេះធ្វើរបាយការណ៍ស្តីពីកិរិយាមារយាទរបស់អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្តល់ព័ត៌មាន ដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ ។

## ជំពូកទី ៤
## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

**មាត្រា ៤២.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គល លើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ ។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ក្នុងអំពើដដែលនោះទេ ។

## មាតិកាទី ៣
## ទោស
## ជំពូកទី ១
## ប្រភេទនៃទោស
## ផ្នែកទី ១
## មូលទោស

**មាត្រា ៤៣.-** មូលទោស

មូលទោសរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យ ។

ការពិន័យត្រូវគិតជាប្រាក់រៀល ។

**មាត្រា ៤៤.-** អប្បបរមា និងអតិបរមានៃមូលទោស

កាលបើបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ច្បាប់កំណត់អំពី អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ ។

កាលបើបទល្មើសត្រូវផ្តន្ទាទោសពិន័យ ច្បាប់កំណត់អំពីអប្បបរមា និង អតិបរមា នៃចំនួនទឹកប្រាក់ពិន័យដែលត្រូវទទួល ។

តាមអានុភាពនៃការមិនរាងចាល ក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារលើសពី ៥ (ប្រាំ) ឆ្នាំ បទល្មើសនៅតែជាបទមជ្ឈិមដដែល ទោះបីជាមានការបន្ថែមទម្ងន់ទោសយ៉ាងណាក៏ដោយ ។

**មាត្រា ៨៩.-** ការប្រមូលបទល្មើស ដើម្បីបង្កើតឱ្យមានការមិនរាងចាល

ដើម្បីអនុវត្តបទប្បញ្ញត្តិស្ដីពីការមិនរាងចាល បទលួច បទរំលោភលើទំនុកចិត្ត និងបទឆបោក ត្រូវចាត់ទុកថាជាបទល្មើសដូចគ្នាដដែល ។

បទល្មើសទទួលផលចោរកម្ម ត្រូវប្រដូចជាបទល្មើសដែលជាប្រភពនៃទ្រព្យសម្បត្តិដែលទទួលលាក់បំបាំង ។

បទល្មើសសំអាតប្រាក់ ត្រូវប្រដូចជាបទល្មើសដែលការសំអាតប្រាក់នេះបានសម្រេច ។

**មាត្រា ៩០.-** ការមិនរាងចាល និងកិច្ចនៃការចោទប្រកាន់

ការមិនរាងចាលអាចត្រូវតុលាការជំនុំជម្រះកត់ត្រាទុក និងអាចជាមូលហេតុនៃការបន្ថែមទម្ងន់ទោសដាក់ពន្ធនាគារបាន ប្រសិនបើមានចែងយ៉ាងជាក់លាក់នៅក្នុងលិខិតចោទប្រកាន់ ។

**មាត្រា ៩១.-** ការមិនរាងចាល និងសេចក្ដីសម្រេចស្ថាពរ

សេចក្ដីសម្រេចត្រូវបានចាត់ទុកថាជាស្ថាពរ កាលណាសេចក្ដីសម្រេចនេះមិនអាចមានផ្លូវតវ៉ាបានទៀតឡើយ ។

ដើម្បីអនុវត្តបទប្បញ្ញត្តិស្ដីពីការមិនរាងចាល ត្រូវគិតគូរតែលើការផ្ដន្ទាទោសស្ថាពរខាងបណ្ដឹងអាជ្ញាប៉ុណ្ណោះ ។

**មាត្រា ៩២.-** បទប្បញ្ញត្តិដោយឡែក

ការមិនរាងចាលអាចត្រូវកត់ត្រាទុក ទោះបីទោសដែលកើតចេញពីការផ្ដន្ទាទោសនោះត្រូវផុតអាជ្ញាយុកាលក៏ដោយ ។

# ជំពូកទី ៦
# ទោសដែលអាចអនុវត្តចំពោះអនីតិជន
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦០.-** មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ

កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបាន បន្ថយក្នុងលក្ខខណ្ឌដូចតទៅ :

១-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។

២-ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ ។

៣-អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ ។

៤-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬតិចជាង ៥ (ប្រាំ) ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល ។

**មាត្រា ១៦១.-** ទោសបន្ថែម

មានតែទោសបន្ថែមដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជន :

១-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

២-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងតិចជាង ២ (ពីរ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយត្រឹម ១ (មួយ) ថ្ងៃ ។

៥-អប្បបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្ដាល ។

**មាត្រា ១៦៥.-** កាតព្វកិច្ចដោយឡែកក្នុងករណីនៃការព្យួរទោសសាកល្បង

នៅក្នុងករណីនៃការព្យួរទោសសាកល្បង មានតែកាតព្វកិច្ចដោយឡែកដូចតទៅនេះប៉ុណ្ណោះដែលអាចអនុវត្តទៅលើអនីតិជន :

១-ទទួលការបង្ហាត់បង្រៀន ឬការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ។

២-ស្ថិតនៅទីកន្លែងមួយជាកំណត់ ។

៣-ដាក់ខ្លួនឱ្យពេទ្យពិនិត្យ ឬព្យាបាល ។

៤-ជួសជុលព្យសនកម្មដែលបណ្ដាលមកអំពីបទល្មើស ទៅតាមធនធានរបស់ខ្លួន ។

៥-បង្ហាញភស្តុតាង បញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋរួចហើយ តាមលទ្ធភាពនៃធនធានរបស់ខ្លួន បន្ទាប់ពីការផ្ដន្ទាទោស ។

៦-មិនត្រូវបង្ហាញមុខនៅទីកន្លែងខ្លះ ។

៧-មិនត្រូវសេពគប់ ទីកន្លែងលក់ភេសជ្ជៈស្រវឹង ។

៨-មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ដោយឡែកជាមួយសហចារី អ្នកផ្ដើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស ។

៩-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។ធ

## ផ្នែកទី ២

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៦៦.-** លក្ខខណ្ឌនៃការឃុំខ្លួនអនីតិជនក្នុងពន្ធនាគារ

អនីតិជនដែលជាប់ពន្ធនាគារ ត្រូវឃុំខ្លួននៅទីកន្លែងពិសេស ខណ្ឌដាច់ពីនីតិជន ។ អនីតិជនស្ថិតនៅក្រោមរបបដោយឡែកជាឯកត្តបុគ្គល ដែលជាទីកន្លែង

សម្រាប់អប់រំ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ។

របបឃុំឃាំងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ។

## ជំពូកទី ៧
## ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល
### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦៧.-** ទោសដែលត្រូវរងដោយនីតិបុគ្គល

ទោសជាយថាប្រភេទដែលត្រូវរងដោយនីតិបុគ្គលមានដូចតទៅ :

១-ទោសពិន័យក្នុងឋានៈជាមូលទោស ។

២-ទោសបន្ថែមដែលរៀបរាប់នៅក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមនេះ ។

### ផ្នែកទី ២
### ទោសបន្ថែម

**មាត្រា ១៦៨.-** ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល

ទោសបន្ថែមត្រូវអនុវត្តទៅលើនីតិបុគ្គលមានដូចតទៅ :

១-ការរំលាយចោល ។

២-ការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ ។

៣-ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬច្រើន ។

៤-ការបណ្ដេញចេញពីលទ្ធកម្មសាធារណៈ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ ។

៦-ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូរបាន ដែលកំណត់ដោយធនាគារ ។

៧-ការហាមឃាត់ចំពោះការប្រើបណ្ណទូទាត់ ។

៨-ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬប្រព្រឹត្តបទល្មើស ។

៩-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលបានប្រើប្រាស់ដោយសាធារណជន ។

១០-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស ។

១១-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

១២-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

១៣-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។

១៤-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បទប្បញ្ញត្តិដោយឡែកអាចបង្កើតទោសបន្ថែមដទៃទៀតបាន ។

**មាត្រា ១៦៩.-** លក្ខខណ្ឌនៃការសម្រេចអំពីទោសបន្ថែម

ទោសបន្ថែមអាចនឹងប្រកាសបានដោយតុលាការ ប្រសិនបើទោសនោះត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទល្មើសដែលចោទប្រកាន់ ។

**មាត្រា ១៧០.-** ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល

សេចក្ដីសម្រេចដែលបង្គាប់ឱ្យរំលាយនីតិបុគ្គល នាំឱ្យមានការបញ្ជូននីតិបុគ្គលនេះទៅតុលាការមានសមត្ថកិច្ច ដើម្បីធ្វើការជម្រះបញ្ជី ។

**មាត្រា ១៧១.-** ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ

ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការមិនអាចលើសពី ៥ (ប្រាំ) ឆ្នាំ ទេ ។ សេចក្ដីសម្រេចដាក់ការត្រួតពិនិត្យតាមដានរបស់តុលាការនាំឱ្យមានការចាត់តាំងអាណត្តិគាហកតុលាការដែលតុលាការបញ្ជាក់បេសកកម្ម ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង ។

**មាត្រា ២១២.–** ស្ថានទម្ងន់ទោសដោយសារគោលដៅ

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា ២១០ (បទទារុណកម្ម និងអំពើឃោរឃៅ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើនេះ ត្រូវបានប្រព្រឹត្តទៅលើ :

១-ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរារាំងជននេះកុំឱ្យប្តឹងបរិហារពីបទល្មើស ឬសុំឱ្យធ្វើការជួសជុលព្យសនកម្ម ។

២-សាក្សី ដើម្បីរារាំងកុំឱ្យឆ្លើយផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

៣-ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះជននេះបានបរិហារពីបទល្មើស ឬសុំឱ្យជួសជុលព្យសនកម្ម ។

៤-សាក្សី ដោយមូលហេតុសាក្សីនេះបានផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

**មាត្រា ២១៣.–** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងចារី

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា ២១០ (បទទារុណកម្ម និងអំពើឃោរឃៅ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើបទឧក្រិដ្ឋនេះ ត្រូវបានប្រព្រឹត្តដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

**មាត្រា ២១៤.–** ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬពិការភាព

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា ២១០ (បទទារុណកម្ម និងអំពើឃោរឃៅ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ)

ឆ្នាំ កាលបើបទឧក្រិដ្ឋនេះនាំឱ្យមានការកាត់អវយវៈ ឬឱ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ។

**មាត្រា ២១៥.-** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា ២១០ (បទទារុណកម្ម និងអំពើឃោរឃៅ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើបទឧក្រិដ្ឋនេះ បណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់ ឬនាំឱ្យមានអត្តឃាតរបស់ជននោះ។

**មាត្រា ២១៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំយ៉ាងច្រើន ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែយ៉ាងច្រើន ។

១០ ០០០ ០០០ (ដប់លាន) រៀល កាលបើអំពើហិង្សានេះ ត្រូវបានប្រព្រឹត្តដោយសហព័ទ្ធ ឬដោយអនីតិសង្វាសជនរបស់ជនរងគ្រោះ ។

**មាត្រា ២២៣.-** ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬពិការភាព

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើអំពើនេះនាំឱ្យមានការកាត់អវយវៈ ឬឱ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ។

**មាត្រា ២២៤.-** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះបណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់។

**មាត្រា ២២៥.-** ការចាត់ទុកការប្រើសារជាតិពុលដូចជាអំពើហិង្សាដោយចេតនា

អំពើដែលឱ្យអ្នកដទៃផឹក លេប ឬបញ្ចូលទៅក្នុងខ្លួនអ្នកដទៃ តាមមធ្យោបាយណាក៏ដោយ ដោយចេតនានូវសារជាតិពុលដែលបណ្តាលឱ្យខូចសុខភាព ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា ។

**មាត្រា ២២៦.-** ការចាត់ទុកការផ្តល់អាហារដែលមានសារជាតិពុល ដូចជាអំពើហិង្សាដោយចេតនា

អំពើលក់ ធ្វើអនុប្បទាន ឬឱ្យចំណី ឬភេសជ្ជៈ ដោយដឹងថាចំណី ឬភេសជ្ជៈនោះមានសារជាតិពុលនាំឱ្យខូចសុខភាពនោះ ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា ។

**មាត្រា ២២៧.-** ការចាត់ទុកការបញ្ចូលសារជាតិពុលក្នុងទឹកសម្រាប់បរិភោគដូចជាអំពើហិង្សាដោយចេតនា

អំពើប្រព្រឹត្តឡើងដោយចេតនា ដោយដាក់បញ្ចូលនូវសារជាតិពុលនាំឱ្យខូចសុខភាពទៅក្នុងទឹកសម្រាប់ហូបជាសាធារណៈ ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា ។

**មាត្រា ២៣០.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ២២៦ (ការចាត់ទុកការផ្ដល់អាហារដែលមានសារជាតិពុលដូចជាអំពើហិង្សាដោយចេតនា) និងមាត្រា ២២៧ (ការចាត់ទុកការបញ្ចូលសារជាតិពុលក្នុងទឹកសម្រាប់បរិភោគ ដូចជាអំពើហិង្សាដោយចេតនា) នៃក្រមនេះ ។

នីតិបុគ្គលត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ :

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ ។

២-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមនេះ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៤-ការបណ្ដេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្ដេញចេញពីលទ្ធកម្មសាធារណៈ) នៃក្រមនេះ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ដល់ការសន្សំសំចៃ តាមបែបបទកំណត់ដោយមាត្រា ១៧៤ (ការហាមឃាត់ចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) នៃក្រមនេះ ។

៦-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមនេះ ។

៧-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន តាមបែបបទកំណត់ដោយមាត្រា ១៧៧ (ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន) នៃក្រមនេះ ។

៨-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និង មាត្រា ១៧៩(ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៩-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និង មាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

១០-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

១១-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

១២-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## ផ្នែកទី ៣
## ការគំរាមកំហែង

**មាត្រា ២៣១.-** បទគំរាមកំហែង

អំពើគំរាមកំហែងថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមប្រឆាំងនឹងបុគ្គល កាលបើការគំរាមកំហែងនេះធ្វើឡើងម្តងហើយម្តងទៀត ឬសម្តែងចេញតាមលិខិត រូបភាព ឬវត្ថុអ្វីមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ១ ០០០ ០០០ (មួយលាន) រៀល ។

១០-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

១១-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្ដីសម្រេច) នៃក្រមនេះ ។

១២-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្ដីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## ផ្នែកទី ៤
## អំពើពុករលួយនៃនិយោជិត និងអភិបាល ជាអាទិ៍

**មាត្រា ២៧៨.–** បទស៊ីសំណូកនៃនិយោជិត

អំពើប្រព្រឹត្តដោយនិយោជិតដែលសុំ ឬយល់ព្រមទទួលអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍ណាមួយ ដើម្បីបំពេញ ឬមិនបំពេញកិច្ចណាមួយនៃមុខងាររបស់ខ្លួន ដោយនិយោជកមិនបានដឹង និងគ្មានការព្រមព្រៀងពីនិយោជកទេនោះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ។

**មាត្រា ២៧៩.–** បទសូកប៉ាន់ដល់និយោជិត

បុគ្គលដែលប្រគល់ឱ្យនិយោជិតនូវអំណោយ ឬជូនជំនូន ធ្វើការសន្យាជាមួយ ឬយល់ព្រមឱ្យអត្ថប្រយោជន៍អ្វីមួយដល់និយោជិត ដើម្បីឱ្យបំពេញ ឬមិនបំពេញកិច្ចអ្វីមួយនៃមុខងាររបស់ខ្លួនដោយនិយោជកមិនបានដឹង និងគ្មានការព្រមព្រៀងពីនិយោជកទេនោះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ។

(ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ១ ០០០ ០០០ (មួយ លាន) រៀល ។

**មាត្រា ៣៣៣.-** បទជិនួស ក្លែង ឬលាក់បំបាំងអត្តិភាពនៃទារក

អំពើដែលយកទារកមួយជំនួសទារកមួយទៀត ក្លែង ឬលាក់បំបាំងអត្តិភាពនៃទារក កាលបើអំពើនេះនាំឱ្យមានការក្លែងបន្លំអត្រានុកូលដ្ឋាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ២ ០០០ ០០០ (ពីរលាន) រៀល ។

**មាត្រា ៣៣៤.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងការប្រព្រឹត្តបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៣៣៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៣-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ៣៣៦.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៣៣០ (បទញុះញង់ឱ្យបោះបង់ទារក)

មាត្រា ៣៣១ (បទអន្តរាការរវាងអ្នកសុំកូន និងអ្នកបោះបង់កូន) និងមាត្រា ៣៣២(បទអន្តរាការរវាងអ្នកសុំកូន និងស្ត្រីពពោះ) នៃក្រមនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៥ ០០០ ០០០ (ប្រាំលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចតទៅនេះ :

១-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមនេះ ។

២-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៣-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមនេះ ។

៤-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៥-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបទល្មើសនោះ នាំឱ្យជនរងគ្រោះស្លាប់ ។

**មាត្រា ៣៤១.-** បទអាសប្រព្រឹត្តទៅលើអនីតិជនអាយុតិចជាង ១៥ ឆ្នាំ

អំពើអាស គឺជាអំពើនៃការប៉ះពាល់ ឬការបង្ហាញកេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់ជនដទៃ ឬការឱ្យជនដទៃប៉ះពាល់កេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់ជនល្មើសខ្លួនឯង ឬរបស់តតិយជន ក្នុងគោលបំណងធ្វើឱ្យរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស ។

ជនណាដែលប្រព្រឹត្តអំពើអាសទៅលើអនីតិជនអាយុតិចជាង ១៥ (ដប់ប្រាំ) ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៣៤២.-** ស្ថានទម្ងន់ទោស

បទល្មើសដែលមានចែងក្នុងមាត្រា ៣៤១ (បទអាសប្រព្រឹត្តទៅលើអនីតិជនអាយុតិចជាង ១៥ ឆ្នាំ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល កាលបើបទល្មើសនេះបានប្រព្រឹត្ត :

១-ដោយបុព្វញាតិ ។

២-ដោយបុគ្គលដែលមានអំណាចលើអនីតិជន ។

៣-ដោយបុគ្គលច្រើនរូប ដែលធ្វើសកម្មភាពក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត ។

៤-ដោយការបង់លាភការ ។

## ផ្នែកទី ២

## ការញុះញង់អនីតិជនឱ្យប្រព្រឹត្តអំពើខុសច្បាប់ ឬអំពើគ្រោះថ្នាក់

**មាត្រា ៣៤៣.-** បទញុះញង់អនីតិជនឱ្យបរិភោគគ្រឿងស្រវឹង

អំពើញុះញង់អនីតិជនដោយផ្ទាល់ឱ្យបរិភោគជាប្រចាំ និងយ៉ាងច្រើននូវ

គ្រឿងស្រវឹង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ។

**មាត្រា ៣៤៤.-** បទញុះញង់អនីតិជនឱ្យសុំទាន

អំពើញុះញង់អនីតិជនដោយផ្ទាល់ឱ្យសុំទាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ២ ០០០ ០០០ (ពីរលាន) រៀល ។

**មាត្រា ៣៤៥.-** បទញុះញង់អនីតិជនឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម

អំពើញុះញង់អនីតិជនដោយផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។

**មាត្រា ៣៤៦.-** បទរៀបចំបង្ហាញភេទ ឬទំនាក់ទំនងខាងផ្លូវភេទដោយមានការចូលរួមរបស់អនីតិជន

អំពើរបស់នីតិជនដែលរៀបចំការជួបជុំ ដែលរួមមាន ការបង្ហាញភេទ ឬមានទំនាក់ទំនងខាងផ្លូវភេទ ដោយមានអនីតិជនបានមើល ឬចូលរួមផងនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។

## ផ្នែកទី ៣

## ការរំលោភអំណាចមេបា

**មាត្រា ៣៤៧.-** បទរំលោភអំណាចមេបា

អំពើរបស់អ្នកមានអំណាចមេបា ឬអ្នកមានអំណាចអាណាព្យាបាល ដែលដកហូតសេរីភាពរបស់អនីតិជន ដោយរំលោភអំណាចរបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០

៦-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៧-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៨-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២
## បទល្មើសក្នុងវិស័យអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

### មាត្រា ៤៨៨.- បទផលិត ឬធ្វើចរាចរណ៍អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ

ការផលិត ការនាំចូល ការនាំចេញ និងសន្និធិអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

អាវុធ សំដៅដល់កាំភ្លើងគ្រប់ប្រភេទដែលផលិត ឬកែច្នៃតម្លើង និងដែលអាចប្រើប្រាស់ដើម្បីសម្លាប់ ឬធ្វើឱ្យរបួស ឬធ្វើឱ្យប៉ះពាល់ខូចខាតដល់ទ្រព្យសម្បត្តិ ។

គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ សំដៅដល់ឧបករណ៍ ឬសម្ភារៈដែលគេផលិត ឬកែច្នៃ ដែលអាចប្រើប្រាស់សម្លាប់ ឬធ្វើឱ្យរបួស ឬធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិ ។

អាវុធគីមី អាវុធជីវសាស្ត្រគ្រប់ប្រភេទ ឬគ្រាប់ដទៃទៀត ដែលផ្ទុកជាតិគីមីផ្ទុកជីវសាស្ត្រ សំដៅដល់សារធាតុ ដែលគេផលិត ឬកែច្នៃតម្លើង និងដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាព អាយុជីវិត ឬទ្រព្យសម្បត្តិ និងបរិស្ថាន ។

### មាត្រា ៤៨៩.- បទផលិត ឬធ្វើចរាចរណ៍អាវុធសម្រាប់ប្រហារផ្សេងទៀត

ការផលិត ការនាំចូល ការនាំចេញ និងសន្និធិអាវុធសម្រាប់ប្រហារផ្សេងទៀត ដូចជា ចំពុះទុង ដាវ ស្នាប់ដៃ ជាអាទិ៍ សម្រាប់សម្លាប់ ឬធ្វើឱ្យរបួស ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ

៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។

**មាត្រា ៤៩០.-** បទកាន់កាប់ ឬដឹកជញ្ជូនអាវុធ ដោយគ្មានការអនុញ្ញាត

គ្រប់បុគ្គលដែលនៅក្រៅលំនៅឋានរបស់ខ្លួន យកតាមខ្លួន ឬដឹកជញ្ជូននូវអាវុធ គ្រឿងផ្ទុះ ឬគ្រាប់រំសេវគ្រប់ប្រភេទ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល ។

ត្រូវផ្តន្ទាទោសដូចគ្នា គ្រប់បុគ្គលដែលនៅក្រៅលំនៅឋានរបស់ខ្លួន យកតាមខ្លួន ឬដឹកជញ្ជូនអាវុធដែលចូលក្នុងដែនអនុវត្តរបស់មាត្រា ៤៨៩ (បទផលិត ឬធ្វើចរាចរណ៍អាវុធសម្រាប់ប្រហារផ្សេងទៀត) នៃក្រមនេះ ។

**មាត្រា ៤៩១.-** បទបោះបង់អាវុធក្នុងទីកន្លែងសាធារណៈ

អំពើបោះបង់អាវុធ ឬវត្ថុដទៃទៀតដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់បុគ្គលនៅក្នុងទីកន្លែងសាធារណៈ ឬទីកន្លែងដែលសាធារណជនអាចចូលទៅបាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៤៩២.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

## ផ្នែកទី ៣
## ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស

**មាត្រា ៤៩៤.-** លក្ខខណ្ឌអត្ថិភាពនៃការញុះញង់

ដើម្បីអនុវត្តផ្នែកនេះ ការញុះញង់អាចត្រូវផ្តន្ទាទោស កាលបើអំពើនេះត្រូវបានប្រព្រឹត្ត :

១-ដោយសំដីតាមប្រភេទណាក៏ដោយ ដែលប្រកាសនៅក្នុងទីកន្លែងសាធារណៈ ឬនៅក្នុងពេលប្រជុំជាសាធារណៈ ។

២-ដោយសំណេរ ឬគំនូរ តាមប្រភេទណាក៏ដោយ ដែលត្រូវផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬតាំងឱ្យសាធារណជនមើល ។

៣-ដោយគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន ។

**មាត្រា ៤៩៥.-** បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ជាអាទិ៍

អំពើញុះញង់ដោយផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬប្រព្រឹត្តអំពើបង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម តាមមធ្យោបាយណាមួយ ក្នុងចំណោមមធ្យោបាយដែលមានចែងក្នុងមាត្រា ៤៩៤ (លក្ខខណ្ឌអត្ថិភាពនៃការញុះញង់) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ប្រសិនបើការញុះញង់នេះគ្មានប្រសិទ្ធភាពទេ ។

**មាត្រា ៤៩៦.-** បទញុះញង់ឱ្យមានការរើសអើង

អំពើញុះញង់ដោយផ្ទាល់តាមមធ្យោបាយណាមួយ ដែលមានចែងក្នុងមាត្រា ៤៩៤ (លក្ខខណ្ឌអត្ថិភាពនៃការញុះញង់) នៃក្រមនេះ ឱ្យប្រព្រឹត្តការរើសអើង ការគុំកួន ឬហិង្សា ចំពោះបុគ្គលណាម្នាក់ ឬក្រុមណាមួយ ដោយមូលហេតុបុគ្គលនេះជាសមាជិក ឬមិនមែនជាសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់នោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី)

ឧបសម្ព័ន្ធទី ៣

# ក្រមនីតិវិធីព្រហ្មទណ្ឌ

នស/រកម/០៨០៧/០២៤

# ព្រះរាជក្រម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
34/2007K

**មាត្រា ៤. – ការចាប់ផ្តើមដំណើរការនៃបណ្តឹងអាជ្ញាដោយអយ្យការ**

បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ ។

អយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ។

**មាត្រា ៥. – ការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ**

ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ ។ ពាក្យប្តឹងដោយមានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរ អំពីបណ្តឹងអាជ្ញានៅក្នុងលក្ខខណ្ឌដែលបញ្ញត្តដោយមាត្រា ១៣៩ (ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា) និងមាត្រា ១៤០ (ការបង់ប្រាក់តម្កល់ទុក) នៃក្រមនេះ ។

យុត្តាធិការព្រហ្មទណ្ឌក៏អាចទទួលបណ្តឹងពីមន្ត្រីរាជការ ឬភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកបានប្រគល់អំណាចឱ្យផងដែរ ។

**មាត្រា ៦. – ការដាក់ពាក្យប្តឹងទាមទារដោយជនរងគ្រោះ**

បុគ្គលគ្រប់រូបដែលប្រកាសថា ខ្លួនជាអ្នករងគ្រោះនៃបទល្មើស អាចដាក់ពាក្យប្តឹងបាន ។ ពាក្យប្តឹងសាមញ្ញ គ្មានអានុភាពនាំឱ្យធ្វើការចោទប្រកាន់ជាបទព្រហ្មទណ្ឌទេ ។

នៅក្នុងករណីដែលពាក្យប្តឹងស្ថិតនៅដោយគ្មានចម្លើយ ឬត្រូវបានតម្កល់ទុកឥតចាត់ការដោយព្រះរាជអាជ្ញា ជនរងគ្រោះអាចប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ទៅតាមរបៀបដូចដែលមានចែងទុកដោយមាត្រា ៤១ (ការតម្កល់រឿងទុកឥតចាត់ការ) នៃក្រមនេះ ។

**មាត្រា ៧. – ការរលត់នៃបណ្តឹងអាជ្ញា**

មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅគឺ :

១-មរណភាពនៃជនល្មើស ។

២-ការផុតអាជ្ញាយុកាល ។

៣-ការលើកលែងទោសជាទូទៅ ។

៤-និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ ។

៥-អាជ្ញាអស់ជំនុំ ។

កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់ ។

មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃ បុគ្គលនោះត្រូវអានកំណត់ហេតុឡើងវិញ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានដោយសំលេងខ្លាំងៗ នូវខ្លឹមសារកំណត់ហេតុ ។ មន្ត្រីនគរបាលយុត្តិធម៌ អាចហៅអ្នកបកប្រែបាន ។ កាលណាបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬមិនព្រមផ្តិតម្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។

**មាត្រា ៩៤.** - បទបញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបាន ។

បុគ្គលដែលកោះហៅនោះ ត្រូវចូលបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ដែលអាចចេញបញ្ជាឱ្យចូលខ្លួនបាន ។ បញ្ជាឱ្យចូលខ្លួននេះ ត្រូវមានអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ មានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផង ។ បញ្ជាឱ្យចូលខ្លួន អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះ ឱ្យចូលបង្ហាញខ្លួន ។ កថាខណ្ឌទី ២ ដល់ទី ៥ នៃមាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ) នៃក្រមនេះ ត្រូវយកមកអនុវត្ត ។

**មាត្រា ៩៥.** - ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ

ប្រសិនបើត្រូវធ្វើការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បាន មន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញ ។ ប្រសិនបើបុគ្គលនោះមិនទាន់បានចុះឈ្មោះនៅក្នុងបញ្ជីអ្នកជំនាញដូចចែងនៅមាត្រា ១៦៣ (បញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ) នៃក្រមនេះទេ បុគ្គលនេះត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា នឹងជួយដោយភក្តីភាពដល់តុលាការ ។

## **ជំពូកទី ៣**
## **ការឃាត់ខ្លួន**

**មាត្រា ៩៦.** - ការឃាត់ខ្លួន

ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ អាចឃាត់ខ្លួនបុគ្គលដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបានដែរ ប្រសិនបើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

-បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន

-មានការយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា ។

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យឃាត់ខ្លួន

-អត្តសញ្ញាណនៃបុគ្គលដែលត្រូវឃាត់ខ្លួន

-មូលហេតុនៃការឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្តើមឃាត់ខ្លួន

-ការឱ្យដំណឹងអំពីសិទ្ធិដែលបានបញ្ញត្តនៃមាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនេះ

-ជាយថាហេតុ ឈ្មោះអ្នកបកប្រែ ។

កំណត់ហេតុនេះត្រូវមានចុះហត្ថលេខា ឬផ្តិតស្រាមមេដៃរបស់ជនឃាត់ខ្លួន ក្រោយពីបានអានកំណត់ហេតុរួច ឬបើសាមីខ្លួនមិនចេះអក្សរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានកំណត់ហេតុឱ្យស្តាប់ ។ ប្រសិនបើជននេះប្រកែកមិនព្រមចុះហត្ថលេខា ឬផ្តិតស្រាមមេដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស ។ កំណត់ហេតុត្រូវភ្ជាប់ជាមួយសំណុំរឿង ។

**មាត្រា ៩៨.** – ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន

ក្នុងរយៈពេល ២៤ ម៉ោងបានកន្លងផុតទៅ គាំងពីពេលផ្តើមនៃការឃាត់ខ្លួនមកនោះ បុគ្គលដែលឃាត់ខ្លួន អាចសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំឱ្យតែជននេះមានការទាក់ទិននៅក្នុងរឿងជាមួយ ។ ជននេះត្រូវបានទទួលដំណឹងពីការស្នើសុំជ្រើសរើសនេះ តាមគ្រប់មធ្យោបាយ និងជាបន្ទាន់ ។ ជននេះអាចចូលទៅកាន់កន្លែងឃាត់ខ្លួន និងទាក់ទងជាមួយបុគ្គលសាមីខ្លួនបាន ៣០ (សាមសិប) នាទី ក្នុងលក្ខខណ្ឌធានាការសម្ងាត់នៃការសន្ទនានេះ ។ ក្រោយការសន្ទនាជននេះ អាចធ្វើកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរដែលត្រូវភ្ជាប់ជាមួយសំណុំរឿង។

**មាត្រា ៩៩.** – ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន

ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ សុំឱ្យគ្រូពេទ្យមកពិនិត្យបុគ្គលដែលឃាត់ខ្លួនបានគ្រប់ពេលវេលា ។ គ្រូពេទ្យផ្ទៀងផ្ទាត់មើលថា តើស្ថានភាពសុខភាពនៃបុគ្គលឃាត់ខ្លួននេះ សមស្របនឹងការឃាត់ខ្លួនដែរឬទេ ។

ប្រសិនបើគ្រូពេទ្យយល់ឃើញថា ស្ថានភាពសុខភាពរបស់បុគ្គលនោះ ពុំសមស្របជាមួយនឹងការឃាត់ខ្លួនទេនោះ មន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ជាបន្ទាន់ដល់ព្រះរាជអាជ្ញា ។ គ្រូពេទ្យចេញវិញ្ញាបនប័ត្របញ្ជាក់សុខភាពដែលត្រូវភ្ជាប់ជាមួយសំណុំរឿង ។ មន្ត្រីនគរបាលយុត្តិធម៌ ចុះនិទ្ទេសនៅលើកំណត់ហេតុអំពីឈ្មោះរបស់គ្រូពេទ្យ ព្រមទាំងថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការពិនិត្យ

សុខភាព ។

ព្រះរាជអាជ្ញាអាចចុះទៅកាន់ទីកន្លែងផ្ទាល់ ដើម្បីផ្ទៀងផ្ទាត់លក្ខខណ្ឌនៃការឃាត់ខ្លួន ។

**មាត្រា ១០០.** – អនីតិជនដែលត្រូវបានឃាត់ខ្លួន

កាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុក ម្ដាយ ដល់អ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារកិច្ចលើអនីតិជននេះ ។

**មាត្រា ១០១.** – បញ្ជីនៃការឃាត់ខ្លួន

នៅក្នុងកន្លែងនីមួយៗ របស់នគរបាល ឬកងរាជអាវុធហត្ថ ដែលសម្រាប់ទទួលជនដែលត្រូវឃាត់ខ្លួន ត្រូវមានបញ្ជីស្ដីពីការឃាត់ខ្លួនមួយ ។

គ្រប់ការឃាត់ខ្លួនត្រូវមានចុះនៅក្នុងបញ្ជីដោយមានសេចក្ដីដូចតទៅនេះ :

-ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យធ្វើការឃាត់ខ្លួន

-អត្តសញ្ញាណរបស់បុគ្គលដែលឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលចាប់ផ្ដើមឃាត់ខ្លួន និងបញ្ចប់ការឃាត់ខ្លួន

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលបានអនុញ្ញាតឱ្យបន្តការឃាត់ខ្លួន ជាយថាហេតុ

-ឈ្មោះរបស់គ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន ជាយថាហេតុ

-ប្រភេទនៃសេចក្ដីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលផុតកំណត់ការឃាត់ខ្លួន ។

បញ្ជីនេះត្រូវកាន់កាប់ជាប្រចាំសម្រាប់ជូនអាជ្ញាធរតុលាការតាមត្រូវការ ។

**មាត្រា ១០២.** – កំណត់ហេតុសរុបនៃការឃាត់ខ្លួន

គ្រប់ការឃាត់ខ្លួនត្រូវតែមានធ្វើកំណត់ហេតុសរុបនៃការឃាត់ខ្លួន ។

កំណត់ហេតុសរុបនេះត្រូវមានចុះនិទ្ទេសដូចតទៅ :

-ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបង្គាប់ឱ្យឃាត់ខ្លួន

-អត្តសញ្ញាណរបស់បុគ្គលដែលត្រូវឃាត់ខ្លួន

-មូលហេតុនៃការឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្ដើមការឃាត់ខ្លួន

-បែបបទនៃការជូនដំណឹងដល់ព្រះរាជអាជ្ញា

-បែបបទនៃការជូនដំណឹងដោយអនុវត្តតាមមាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន) នៃក្រមនេះ

-ឈ្មោះគ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន

-អត្តសញ្ញាណរបស់ជនដែលបានសន្ទនាជាមួយបុគ្គលឃាត់ខ្លួនស្របតាមមាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនេះ

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលជាយថាហេតុបានអនុញ្ញាតឱ្យបន្តការឃាត់ខ្លួន

-ថិរវេលានៃការស្ដាប់ចម្លើយនីមួយៗ និងថិរវេលានៃការសម្រាកដែលនៅចន្លោះការស្ដាប់ចម្លើយនីមួយៗ

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការឃាត់ខ្លួន

-ប្រភេទនៃសេចក្ដីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលបញ្ចប់ការឃាត់ខ្លួន

-លក្ខខណ្ឌនៃការប្រព្រឹត្តិទៅនៃការឃាត់ខ្លួន ព្រមទាំងឧប្បត្តិហេតុជាយថាហេតុ ។

កំណត់ហេតុសរុបនៃការឃាត់ខ្លួនត្រូវភ្ជាប់ជាមួយសំណុំរឿង ។

## ជំពូកទី ៤

## ការបញ្ជូនខ្លួន

**មាត្រា ១០៣.** – ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន

នៅពេលផុតកំណត់នៃរយៈពេលឃាត់ខ្លួន បុគ្គលដែលត្រូវបានឃាត់ខ្លួននោះត្រូវ :

-បញ្ជូនខ្លួនទៅព្រះរាជអាជ្ញា ឬ

-ដោះលែងឱ្យមានសេរីភាពឡើងវិញ ។

សេចក្ដីសម្រេចនេះធ្វើឡើងដោយព្រះរាជអាជ្ញា ។

**មាត្រា ១០៤.** – រយៈពេលនៃការបញ្ជូនខ្លួន

កាលណាបុគ្គលដែលត្រូវឃាត់ខ្លួន ត្រូវបញ្ជូនខ្លួនទៅព្រះរាជអាជ្ញា នោះបុគ្គលនេះត្រូវបានគេនាំខ្លួនភ្លាមយកទៅចំពោះមុខព្រះរាជអាជ្ញា ។

ប្រសិនបើការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ពុំអាចធ្វើឡើងនៅថ្ងៃតែមួយបានដោយសារមានមូលហេតុពិសេសដែលបណ្ដាលមកពីការលំបាកក្នុងការដឹកជញ្ជូន ឬចម្ងាយផ្លូវនៃការដឹកជញ្ជូននោះ រយៈពេលបន្ថែមអាចផ្ដល់ឱ្យដោយព្រះរាជអាជ្ញាបាន ។

នៅក្នុងគ្រប់ករណីទាំងអស់ ការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ត្រូវធ្វើឡើងនៅក្នុងរយៈពេលដ៏ឆាប់បំផុតតាមការដែលអាចធ្វើទៅបាន ។

មូលហេតុនៃការយឺតយ៉ាវត្រូវចុះក្នុងកំណត់ហេតុ ដែលត្រូវប្រគល់ជូនព្រះរាជអាជ្ញាដោយមន្ត្រីនគរបាលយុត្តិធម៌ ។

ក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋសង្គ្រាម ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ១ (មួយ) ឆ្នាំបានទេ ចំពោះបទល្មើសនីមួយៗ ។ ប៉ុន្តែ នៅពេលផុតចិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្តោះអាសន្នម្តងបាន ១ (មួយ) ឆ្នាំ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ។

ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យពន្យារការឃុំខ្លួនបណ្តោះអាសន្ននេះបានតែ ២ (ពីរ) ដងគត់ ។

**មាត្រា ២១១.** – ការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ន

កាលណាចៅក្រមស៊ើបសួរសម្រេចថាពន្យារពេលឃុំខ្លួនជាបណ្តោះអាសន្ន ចៅក្រមស៊ើបសួរត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សំគាល់របស់ជននេះ ។ កាលណាជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវបង្គាញមតិលោបាយការពារខ្លួនកូនក្តីរបស់ខ្លួន ។

ចៅក្រមស៊ើបសួរពន្យារការឃុំខ្លួនបណ្តោះអាសន្ន តាមដីកាដោយមានសំអាងហេតុ ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងទៅតាមបទប្បញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមនេះ ។ ដីកានេះត្រូវឱ្យដំណឹងជាបន្ទាន់ដល់ជនត្រូវចោទ ។

**មាត្រា ២១២.** – សេចក្តីសម្រេចទាក់ទងនឹងអនីតិជនមានអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ

អនីតិជនអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្តោះអាសន្នទេ ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះឱ្យឪពុកម្តាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្ន រង់ចាំសេចក្តីសម្រេចរបស់តុលាការ ។

**មាត្រា ២១៣.** – ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទឧក្រិដ្ឋទាក់ទងនឹងអនីតិជន មានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ

ចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ និងត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ចិរវេលាឃុំខ្លួនបណ្តោះអាសន្នមានដូចតទៅ :

១-ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ កាលណាអនីតិជននេះមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ ។

២-ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែ បានទេ កាលណាអនីតិជននេះមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

**មាត្រា ២១៤.** – ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ក្នុងបទមជ្ឈិមទាក់ទងនឹងអនីតិជន មានអាយុ

ចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ

ចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ និងត្រូវចោទប្រកាន់ពីបទមជ្ឈិម ថិរវេលាឃុំខ្លួនបណ្ដោះអាសន្នមានដូចតទៅ :

១-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ២ (ពីរ) ខែ បានទេ កាលណាអនីតិជននេះមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ ។

២-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ កាលណាអនីតិជននេះមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នតាមចំណុចទី ១ និងចំណុចទី ២ ខាងលើនេះ មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ ។

**មាត្រា ២១៥.** – ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំវិញបានគ្រប់ពេលវេលា ។

កាលណាចៅក្រមស៊ើបសួរមានបំណងដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំនោះ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ហើយបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ ។ ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។

ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យដោះលែងជនត្រូវចោទភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា ។ ចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់មូលហេតុនៃការបន្ទាន់នេះនៅក្នុងដីកាសម្រេចរបស់ខ្លួន ។

**មាត្រា ២១៦.** – ការដោះលែងឱ្យនៅក្រៅឃុំ តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាអាចសុំឱ្យដោះលែងជនត្រូវចោទបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្ដឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

ដីកាដែលសម្រេចមិនព្រមដោះលែងត្រូវមានសំអាងហេតុ ។

**មាត្រា ២១៧.** – ការដោះលែងឱ្យនៅក្រៅឃុំ តាមបណ្ដឹងរបស់ជនត្រូវចោទ

ជនត្រូវចោទអាចដាក់ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរបញ្ជូនពាក្យនោះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីផ្ដល់យោបល់ និងបញ្ជូនសំណុំរឿងទៅ

ឃុំខ្លួនជនត្រូវចោទ ។

ចៅក្រមស៊ើបសួរអាចនឹងចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន លុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន ។

**មាត្រា ២២១.** – និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យឃុំខ្លួន

ដីកាបង្គាប់ឱ្យឃុំខ្លួនមានចុះនិទ្ទេសដូចតទៅ :

-អត្តសញ្ញាណរបស់ជនត្រូវចោទ

-ប្រភេទនៃបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។

ដីកាបង្គាប់ឱ្យឃុំខ្លួនត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រា ។

**មាត្រា ២២២.** – ការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួន

ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឱ្យឃុំខ្លួនរហូតទាល់តែបានទទួលការឱ្យដំណឹងអំពីការដោះលែងឱ្យមានសេរីភាពវិញ ។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន រក្សាទុកដើមដីកាបង្គាប់ឱ្យឃុំខ្លួន ឬចុងដីកានេះ ដែលបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម ។

## ផ្នែកទី ៧
## ការត្រួតពិនិត្យតាមផ្លូវតុលាការ

**មាត្រា ២២៣.** – កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ប្រសិនបើជនត្រូវចោទនេះ ត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ ។

ការត្រួតពិនិត្យតាមផ្លូវតុលាការមានអានុភាពបង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំ ឱ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ :

១-មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ ។

២-មិនត្រូវផ្លាស់ប្ដូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ។

៣-មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ ។

៤-ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ដែលចាត់តាំងដោយចៅក្រមស៊ើបសួរ ។

៥-ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ ។

៦-ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ ។

៧-មិនត្រូវបើកបររថយន្ត ។

៨-មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ ។

៩-ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងថិរវេលាបង់ប្រាក់នេះ ត្រូវបានកំណត់ ដោយចៅក្រមស៊ើបសួរ ដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ ។

១០-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ ។ ត្រូវប្រគល់ជូនដល់ការិយាល័យ ក្រឡាបញ្ជី នូវអាវុធដែលជនត្រូវចោទកាន់កាប់ ។

១១-ត្រូវប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុ ដាក់ឱ្យស្ថិតនៅក្រោម របបព្យាបាលរោគក្នុងមន្ទីរពេទ្យ ។

១២-មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ ។

ដើម្បីអនុវត្តចំណុចទី ១២ ខាងលើ ចៅក្រមស៊ើបសួរមិនអាចហាមឃាត់ការអនុវត្ត នូវ អាណត្តិបោះឆ្នោត ឬសកម្មភាពខាងសហជីពបានទេ ។

**មាត្រា ២២៤.** – ការមិនអនុវត្តការត្រួតពិនិត្យតាមផ្លូវតុលាការ ចំពោះអនីតិជនមានអាយុ ក្រោម ១៤ (ដប់បួន) ឆ្នាំ

អនីតិជនអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ តាមផ្លូវតុលាការបានទេ ។

**មាត្រា ២២៥.** – ការប្រគល់បង្កាន់ដៃ

នៅក្នុងករណីដែលមានចែងត្រង់ចំណុចទី ៦ ទី៩ និងចំណុចទី ១០ នៃមាត្រា ២២៣ (កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ) ខាងលើនេះ ជនត្រូវចោទទទួលបង្កាន់ដៃស្តីពីការ ប្រគល់ឯកសារអត្តសញ្ញាណ ប្រាក់ធានា ឬអាវុធ ។ បង្កាន់ដៃប្រគល់ឯកសារបញ្ជាក់អំពី អត្តសញ្ញាណ ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី ។

បង្កាន់ដៃប្រគល់ប្រាក់ធានា ឬអាវុធ ត្រូវចុះហត្ថលេខារួមដោយ ប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ។

ប្រាក់ធានាត្រូវតម្កល់ទុកនៅគណនីពិសេសដែលបើកនៅធនាគារ ឬត្រូវរក្សាទុកនៅទីកន្លែងមួយដែលមានការធានាសន្តិសុខរឹងមាំ ។ ទីកន្លែងនេះត្រូវជ្រើសរើសតាមការឯកភាពគ្នាដោយប្រធានតុលាការ និងព្រះរាជអាជ្ញា ។

អាវុធត្រូវរក្សាទុកនៅទីកន្លែងដូចបានពោលខាងលើ ។

**មាត្រា ២២៦.** – ដីកាបង្គាប់ឱ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តាមគំនិតផ្តើមផ្ទាល់របស់ខ្លួន ឬតាមសេចក្តីសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា ។ ចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួន អំពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ ។

ដីកាសម្រេចដាក់ខ្លួនឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវផ្ញើនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ ។

កាលណាចៅក្រមស៊ើបសួរដែលទទួលបណ្តឹងតាមសេចក្តីសន្និដ្ឋានពីព្រះរាជអាជ្ញា សុំឱ្យដាក់ខ្លួនជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មិនព្រមសម្រេចតាមការសុំទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធការសុំនេះ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ។

ដីកាសម្រេចនេះត្រូវផ្ញើនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

**មាត្រា ២២៧.** – ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយឯកឯង ដោយចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរអាចកែប្រែខ្លឹមសារនៃកាតព្វកិច្ច អាចលុបចោល ឬបញ្ចូលកាតព្វកិច្ចថ្មីបានគ្រប់ពេលវេលា ។

ចៅក្រមស៊ើបសួរក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការបានដែរ ។

ចៅក្រមស៊ើបសួរសម្រេចតាមដីកា ដែលត្រូវផ្ញើនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ ។

**មាត្រា ២២៨.** – បណ្តឹងសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាអាចសុំឱ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ។ ដីកាសម្រេចនេះត្រូវផ្ញើនដំណឹងក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេលនេះទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យ

ចំពោះការចោទប្រកាន់ ការស៊ើបសួរ និងការជំនុំជម្រះបទល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គល អាជ្ញាធរមានសមត្ថកិច្ចមានដូចតទៅ ៖

-ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ និងសាលាដំបូងនៃទីកន្លែងដែលមានការប្រព្រឹត្តិបទល្មើស

-ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ និងសាលាដំបូងនៃទីកន្លែងដែលនីតិបុគ្គលតាំងទីស្នាក់ការរបស់ខ្លួន ។

**មាត្រា ៥៩៨.** – ការតំណាងនីតិបុគ្គលនៅចំពោះមុខតុលាការ

ការចោទប្រកាន់ត្រូវបានអនុវត្តប្រឆាំងនឹងនីតិបុគ្គល តាមរយៈអ្នកតំណាងស្របច្បាប់ក្នុងពេលធ្វើការចោទប្រកាន់នោះ ។ អ្នកតំណាងស្របច្បាប់ តំណាងឱ្យនីតិបុគ្គលក្នុងការបំពេញគ្រប់កិច្ចទាំងអស់នៃនីតិវិធី ។

កាលណាអ្នកតំណាងស្របច្បាប់មានធុរៈ ព្រះរាជអាជ្ញា អាចស្នើសុំដល់ប្រធានសាលាដំបូងឱ្យចាត់តាំងអាណត្តិគាហកម្នាក់ ដើម្បីតំណាងឱ្យនីតិបុគ្គល ។

កាលណាការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ត្រូវបានធ្វើឡើងចំពោះអង្គហេតុដដែល ឬចំពោះអង្គហេតុទាក់ទងគ្នាប្រឆាំងនឹងនីតិបុគ្គល និងអ្នកតំណាងស្របច្បាប់នៃនីតិបុគ្គលនេះ អ្នកតំណាងស្របច្បាប់នេះ អាចប្ដឹងសុំដល់ប្រធានសាលាដំបូងឱ្យចាត់តាំង អាណត្តិគាហកម្នាក់ដើម្បីតំណាងនីតិបុគ្គល ។

បណ្ដឹងសុំនេះ អាចធ្វើឡើងតាមរយៈពាក្យសុំជាលាយលក្ខណ៍អក្សរ ។

**មាត្រា ៥៩៩.** – អត្តសញ្ញាណនៃអ្នកតំណាងរបស់នីតិបុគ្គល

បុគ្គលដែលទទួលបន្ទុកតំណាងឱ្យនីតិបុគ្គល ត្រូវតែបង្ហាញអត្តសញ្ញាណរបស់ខ្លួនចំពោះតុលាការដែលបានទទួលពាក្យប្ដឹង ។ ការបង្ហាញអត្តសញ្ញាណនេះក៏ត្រូវធ្វើដូចគ្នាផងដែរ ក្នុងករណីផ្លាស់ប្ដូរអ្នកតំណាងស្របច្បាប់ ក្នុងពេលដំណើរការនីតិវិធី ។

**មាត្រា ៦០០.** – វិធានការបង្ខំដែលយកមកអនុវត្តចំពោះនីតិបុគ្គល

ក្នុងឋានៈជាអ្នកតំណាងឱ្យនីតិបុគ្គល អ្នកតំណាងនេះពុំអាចទទួលរងវិធានការបង្ខំណាមួយបានឡើយ ក្រៅពីវិធានការដែលអាចយកមកអនុវត្តបានចំពោះសាក្សី ។

**មាត្រា ៦០១.** – ការដាក់នីតិបុគ្គលឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរអាចដាក់នីតិបុគ្គលឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។ ចៅក្រម

នេះ អាចប្រកាសបាននូវកាតព្វកិច្ចដូចតទៅ ៖

១-ដាក់ប្រាក់ធានា ដែលមានកំណត់ចំនួនទឹកប្រាក់ ថិរវេលានៃការបង់ និងបែបបទទាំងឡាយ ។

២-មិនត្រូវអនុវត្តសកម្មភាពវិជ្ជាជីវៈមួយចំនួន ។

៣-ស្ថិតនៅក្រោមការតាមដានរបស់តុលាការ ក្នុងថិរវេលាមួយដែល មិនលើសពី ៦ (ប្រាំមួយ) ខែ ។

សេចក្តីសម្រេចដាក់ឱ្យស្ថិតនៅក្រោមការតាមដានរបស់តុលាការ បណ្តាលឱ្យមានការចាត់តាំងអាណត្តិគាហកខាងតុលាការម្នាក់ ដែលមានបេសកកម្មត្រូវបានបញ្ជាក់ដោយចៅក្រមស៊ើបសួរ ។

**មាត្រា ៦០២.** – ដីកាកោះ និងដីកាជូនដំណឹងដល់នីតិបុគ្គល

ដីកាកោះហៅ និងសេចក្តីសម្រេចទាំងឡាយ ដែលមានចែងនៅក្នុងក្រមនេះ ត្រូវបានបញ្ជូន និងឱ្យដំណឹងទៅនីតិបុគ្គល តាមរយៈអ្នកតំណាងស្របច្បាប់របស់នីតិបុគ្គលនោះ នៅក្នុងលក្ខខណ្ឌដូចគ្នានឹងលក្ខខណ្ឌដែលមានចែងសម្រាប់រូបវន្តបុគ្គលដែរ ។

## មាតិកាទី ២
## ការបាត់បង់លិខិតស្នាម ការបកស្រាយ និងការកែសម្រួលសេចក្តីសម្រេច
### ជំពូកទី ១
### ការបាត់បង់លិខិតស្នាម

**មាត្រា ៦០៣.** – បទប្បញ្ញត្តិដែលអនុវត្តក្នុងករណីបាត់បង់លិខិតស្នាម

បទប្បញ្ញត្តិនៃមាតិកានេះត្រូវអនុវត្តនៅក្នុងករណីមានការបំផ្លិចបំផ្លាញ ការបំបាត់ ឬការបាត់បង់លិខិតស្នាមដូចខាងក្រោម ៖

-សេចក្តីសម្រេចដើមរបស់តុលាការ ឬ

-លិខិតនៃនីតិវិធី ។

**មាត្រា ៦០៤.** – លិខិតចម្លងដែលជំនួសលិខិតដើម

ប្រសិនបើបានលិខិតចម្លងនៃសេចក្តីសម្រេចរបស់តុលាការ ដែលមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើមដោយក្រឡាបញ្ជី ឬដោយអាជ្ញាធរមួយផ្សេងទៀត លិខិតចម្លងនោះត្រូវចាត់ទុកថាជាសេចក្តីសម្រេចដើមរបស់តុលាការ ។ អ្នកដែលមានលិខិតចម្លងដោយមានបញ្ជាក់ថាត្រឹមត្រូវ

ឧបសម្ព័ន្ធទី ៤

# ច្បាប់ស្តីពីយុត្តិធម៌អនីតិជន

# ព្រះរាជក្រម

នស/រកម/០៧១៦/០០៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE — LE MINISTRE DU PALAIS ROYAL

**មាត្រា ៦.- សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី**

អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ ៖

- សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល
- សិទ្ធិទទួលបានការឲ្យដំណឹងអំពីបទចោទប្រកាន់
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកកម្រៃ ស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី
- សិទ្ធិឲ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់
- សិទ្ធិបង្ហាញភស្តុតាង
- សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី និងសួរសាក្សី
- សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ
- សិទ្ធិស្នើសុំឲ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស
- សិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន ។

## ជំពូកទី ៣

## ការទទួលខុសត្រូវព្រហ្មទណ្ឌ និងវដ្តប្បវេណីរបស់អនីតិជន

**មាត្រា ៧.- ការទទួលខុសត្រូវព្រហ្មទណ្ឌ**

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ចាប់ពីអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។ ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ លើកលែងតែករណីមានចែងពិសេសនៅក្នុងច្បាប់ផ្សេងទៀត ។

ROYAUME DU CAMBODGE • LE MINISTÈRE DU PALAIS ROYAL

កំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការ ដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ អាចដាក់ពាក្យប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណីបាន ។

## មាត្រា ២៨.- អំណាចរបស់តំណាងអយ្យការក្នុងការបង្វែរ

ករណីអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ប្រព្រឹត្តបទលហុ ឬបទមជ្ឈិម ព្រះរាជអាជ្ញាត្រូវពិចារណាជាបឋមទៅលើការបង្វែរដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ។

ករណីព្រះរាជអាជ្ញាសម្រេចបង្វែរ បទប្បញ្ញត្តិនៃជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្ត ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវសម្រេចផ្អាកនីតិវិធីចោទប្រកាន់ដោយដីកាសម្រេច ។

ប្រសិនបើការរៀបចំផែនការបង្វែរត្រូវការពេលវេលា ព្រះរាជអាជ្ញាត្រូវផ្អាកនីតិវិធីចោទប្រកាន់ និងបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រងនិងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ ។

ព្រះរាជអាជ្ញាជូនដំណឹងដល់ជនរងគ្រោះឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ក្នុងករណីជនរងគ្រោះជាអនីតិជន និងមេធាវីរបស់អនីតិជនអំពីការសម្រេចផ្អាកនីតិវិធីចោទប្រកាន់ ។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី ។

ព្រះរាជអាជ្ញា ត្រូវសម្រេចចេញដីកាតម្កល់រឿងទុកឥតចាត់ការក្នុងករណីដែលការអនុវត្តផែនការបង្វែរទទួលបានជោគជ័យ ដោយផ្អែកលើលទ្ធផលនៃរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ ។

ក្នុងករណីអនីតិជនអនុវត្តផែនការបង្វែរមិនបានជោគជ័យ ព្រះរាជអាជ្ញាអាចចេញដីកាសម្រេចបង្វែរជាថ្មី ដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី ។

## មាត្រា ២៩.- ការឲ្យដំណឹងអំពីការចោទប្រកាន់

ក្នុងករណីណាក៏ដោយ ការសម្រេចចោទប្រកាន់របស់ព្រះរាជអាជ្ញាត្រូវឲ្យដំណឹងភ្លាមដោយផ្ទាល់និងជាលាយលក្ខណ៍អក្សរទៅអនីតិជន ហើយប្រសិនបើសមស្រប ត្រូវឲ្យដំណឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ឬអ្នកទំនុកបម្រុងនិងមេធាវីរបស់អនីតិជន ដើម្បីរៀបចំមធ្យោបាយការពារអនីតិជន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

## មាត្រា ៣៧.- ការព្យួរការសិក្សា និងការងារសម្រាប់អនីតិជន

ចៅក្រមស៊ើបសួរអាចបង្គាប់ទៅគ្រឹះស្ថានសិក្សា ឬនិយោជក មិនឲ្យព្យួរការសិក្សា ឬព្យួរការងាររបស់អនីតិជន ប្រសិនបើអនីតិជនមិនត្រូវបានឃុំខ្លួនបណ្ដោះអាសន្នទេ ។

ក្នុងករណីអនីតិជនត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន ឬត្រូវអនុវត្តផែនការបង្វែរ គ្រឹះស្ថាន ឬនិយោជកអាចព្យួរការសិក្សា ឬព្យួរការងាររហូតដល់មានសេចក្ដីសម្រេចរបស់តុលាការជាស្ថាពរ ។ ក្នុងករណីតុលាការសម្រេចសេចក្ដីថាគ្មានទោសទេ នោះគ្រឹះស្ថានសិក្សា ឬនិយោជកត្រូវអនុញ្ញាតឲ្យអនីតិជនចូលសិក្សា ឬធ្វើការជាធម្មតាឡើងវិញ ។

## មាត្រា ៣៨.- អំណាចរបស់ចៅក្រមស៊ើបសួរក្នុងការបង្វែរ

ចៅក្រមស៊ើបសួរត្រូវពិចារណាជាបឋមទៅលើការបង្វែរ ដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ចំពោះអនីតិជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទមជ្ឈិម ។ បទមជ្ឈិមដែលមានស្ថានទម្ងន់ទោស អាចត្រូវបានយកមកពិចារណាអំពីការបង្វែរផងដែរ ។ ករណីចៅក្រមស៊ើបសួរសម្រេចបង្វែរ បទប្បញ្ញត្តិក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្ត ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវផ្អាកនីតិវិធីនៃការស៊ើបសួរដោយដីកាសម្រេច និងបង្គាប់ឲ្យដោះលែងអនីតិជនដែលត្រូវបានឃុំខ្លួន ប្រសិនបើអនីតិជននោះត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន ។ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រងនិងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ ទោះបីផែនការបង្វែរត្រូវការពេលវេលារៀបចំក៏ដោយ ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ក្នុងករណីជនរងគ្រោះជាអនីតិជន និងមេធាវីរបស់អនីតិជន អំពីការសម្រេចផ្អាកនីតិវិធីនៃការស៊ើបសួរ ។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្ដឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី ។

ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ ក្នុងករណីដែលការអនុវត្តផែនការបង្វែរទទួលបានជោគជ័យ ដោយផ្អែកលើលទ្ធផលរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ ។

ក្នុងករណីដែលអនីតិជនអនុវត្តផែនការបង្វែរមិនបានជោគជ័យ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចបង្វែរជាថ្មីដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរ ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី ។

## មាត្រា ៣៩.- ការឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនអនីតិជនបណ្ដោះអាសន្ន ជាវិធានការចុងក្រោយ ។

## មាត្រា ៥១.- ការផ្ដល់ព័ត៌មានអំពីសិទ្ធិដល់អនីតិជន

នៅពេលចាប់ផ្ដើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលអនីតិជនអាចយល់បាន អំពីសិទ្ធិដូចខាងក្រោម ៖

- សិទ្ធិដែលទាក់ទងនឹងដំណាក់កាលនៃការជំនុំជម្រះដូចមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ
- សិទ្ធិមានវត្តមាននៅពេលជំនុំជម្រះក្ដី
- សិទ្ធិទទួលបានការការពារពីតុលាការនូវទង្វើមិនគប្បី ឬការសួរដេញដោលមិនសមរម្យ
- សិទ្ធិប្ដឹងជំទាស់ចិត្តចៅក្រមជំនុំជម្រះ
- សិទ្ធិធ្វើសំណូមពរចុងក្រោយ និង
- សិទ្ធិប្ដឹងឧទ្ធរណ៍ ។

## មាត្រា ៥២.- អំណាចរបស់តុលាការក្នុងការបង្វែរ

នៅដំណាក់កាលនៃការជំនុំជម្រះលើអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ជាប់ចោទពីបទលហុ បទមជ្ឈិម តុលាការត្រូវពិចារណាជាបឋម ទៅលើការបង្វែរដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ។ បទមជ្ឈិមដែលមានស្ថានទម្ងន់ទោស អាចត្រូវបានយកមកពិចារណាអំពីការបង្វែរផងដែរ ។

ក្នុងករណីលក្ខខណ្ឌអប្បបរមាត្រូវបានបំពេញ តុលាការត្រូវចេញសាលក្រមបង្អង់រឿងទុកសិនបន្ទាប់មកត្រូវ ៖

- ពិគ្រោះយោបល់ជាមួយអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុងមេធាវី ភ្នាក់ងារសង្គមកិច្ច ជនរងគ្រោះ ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកពាក់ព័ន្ធផ្សេងទៀត
- រៀបចំផែនការបង្វែរ
- ឲ្យអនីតិជនចុះហត្ថលេខា ឬផ្ដិតម្រាមដៃអនុវត្តផែនការបង្វែរ ។

ក្នុងករណីតុលាការសម្រេចបង្វែរ បទប្បញ្ញត្តិក្នុងជំពូកទី ១០(ការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្ត ។ តុលាការអាចចេញសាលក្រមសម្រេចអំពីសំណងរដ្ឋប្បវេណី ក្នុងករណីមានការប្ដឹងសុំ ។

ប្រសិនបើអនីតិជនកំពុងជាប់ឃុំ តុលាការត្រូវបង្គាប់ឲ្យដោះលែងអនីតិជននោះភ្លាម ទោះបីមានបណ្ដឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ តុលាការត្រូវបញ្ជូនអនីតិជននោះ ទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់ចែងធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីអនីតិជនអនុវត្តបានជោគជ័យនូវផែនការបង្វែរ ដោយមានរបាយការណ៍បញ្ជាក់រួមគ្នារបស់ភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ តុលាការត្រូវចេញសាលក្រមសម្រេចឲ្យអនីតិជនមិនទទួលខុសត្រូវព្រហ្មទណ្ឌ ។

ក្នុងករណីការអនុវត្តផែនការបង្វែរទទួលបរាជ័យ តុលាការអាចចេញដីកាសម្រេចបង្វែរជាថ្មីដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរ ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់ចែងធានការតាមនីតិវិធី ។

## មាត្រា ៥៣.- ចម្លើយសារភាពនៅពេលសវនាការ

តុលាការត្រូវពិនិត្យ ថ្លឹងថ្លែង និងបញ្ជាក់ថាចម្លើយសារភាពទទួលយកពិរុទ្ធភាពរបស់អនីតិជននៅពេលសវនាការ ត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត គ្មានការគំរាមកំហែង ឬបង្ខិតបង្ខំ និងយល់បានអំពីផលវិបាកនៃការសារភាពនេះ ។ ចម្លើយសារភាពដែលបានមកពីការគំរាមកំហែងការបង្ខិតបង្ខំ ឬការមិនយល់ដឹងអំពីផលវិបាកនៃការសារភាពមិនត្រូវចាត់ទុកជាភស្តុតាង នៃពិរុទ្ធភាពឡើយ ។

ការសារភាពទទួលយកផែនការបង្វែរមិនត្រូវចាត់ទុកជាភស្តុតាងសម្រាប់ពិរុទ្ធភាពក្នុងបទល្មើសដដែល សម្រាប់នីតិវិធីព្រហ្មទណ្ឌបន្តបន្ទាប់នោះឡើយ ។

ក្នុងពេលសវនាការតុលាការត្រូវផ្ទៀងផ្ទាត់ពីភាពស៊ីចង្វាក់នៃចម្លើយសារភាព និងភស្តុតាងផ្សេងទៀតនៃបទល្មើស ។

## មាត្រា ៥៤.- ការប្រកាសសាលក្រម

សាលក្រមត្រូវប្រកាសនៅពេលសវនាការ ក្រោយពីធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយ ។

ជាគោលការណ៍ សាលក្រមត្រូវប្រកាសជាអសាធារណៈនៅចំពោះមុខអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ភ្នាក់ងារសង្គមកិច្ច និងភាគីដែលមានប្រយោជន៍នៅក្នុងរឿងក្តី ។

សាលក្រមអាចប្រកាសកំបាំងមុខអនីតិជនបាន ក្នុងករណីដែលការប្រកាសសាលក្រមចំពោះមុខធ្វើឲ្យខូចដល់ឧត្តមប្រយោជន៍របស់អនីតិជននោះ។

## ជំពូកទី ៩
## សមត្ថកិច្ចរបស់តុលាការជាន់ខ្ពស់

### មាត្រា ៥៥.‒ សមាសភាពនៃក្រុមប្រឹក្សាជំនុំជម្រះ

ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ និងតុលាការកំពូលត្រូវមានសមាសភាពជាចៅក្រមជំនាញទាក់ទងនឹងអនីតិជនយ៉ាងតិច ១ (មួយ) រូប ។

### មាត្រា ៥៦.‒ ការបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍ និងតុលាការកំពូល

ក្នុងករណីមានបណ្ដឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៃសាលាដំបូងត្រូវរៀបចំសំណុំរឿងដើម្បីបញ្ជូនទៅសាលាឧទ្ធរណ៍ ក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃ គិតពីថ្ងៃប្ដឹងឧទ្ធរណ៍ លើកលែងតែមានកាលៈទេសៈមិនអាចជម្នះបានដែលត្រូវតែមានបញ្ជាក់នៅក្នុងលិខិតបញ្ជូន ។

ក្នុងករណីមានបណ្ដឹងសាទុក្ខ ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ត្រូវរៀបចំសំណុំរឿងដើម្បីបញ្ជូនទៅតុលាការកំពូល ក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃ គិតពីថ្ងៃប្ដឹងសាទុក្ខ លើកលែងតែមានកាលៈទេសៈមិនអាចជម្នះបានដែលត្រូវតែមានបញ្ជាក់នៅក្នុងលិខិតបញ្ជូន ។

### មាត្រា ៥៧.‒ អាទិភាពនៃរឿងក្ដីអនីតិជន

សាលាឧទ្ធរណ៍ និងតុលាការកំពូល ត្រូវលើកយករឿងក្ដីរបស់អនីតិជនមកចាត់ការ ជំនុំជម្រះជាអាទិភាព ពិសេសរឿងក្ដីអនីតិជនដែលជាប់ឃុំ ។ ចំពោះរឿងក្ដីដែលអនីតិជនជាប់ឃុំ ត្រូវលើកយកមកជំនុំជម្រះក្នុងអំឡុងពេល ៣ (បី) ខែ យ៉ាងយូរគិតពីថ្ងៃទទួលសំណុំរឿង លើកលែងតែមានមូលហេតុសត្យានុម័តដែលមិនអាចជម្នះបាន ។

ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលរង់ចាំការជំនុំជម្រះ សាលាឧទ្ធរណ៍ឬតុលាការកំពូលត្រូវពិចារណាដោះលែងអនីតិជនដែលជាប់ឃុំបណ្ដោះអាសន្នឲ្យមានសេរីភាព ។ ក្នុងករណីរឿងក្ដីត្រូវបានលើកពេលជំនុំជម្រះ សាលាឧទ្ធរណ៍ ឬតុលាការកំពូលត្រូវពិចារណាផងដែរអំពីការដោះលែងអនីតិជនដែលជាប់ឃុំបណ្ដោះអាសន្នឲ្យមានសេរីភាព ។

### មាត្រា ៥៨.‒ អំណាចរបស់សាលាឧទ្ធរណ៍ក្នុងការបង្វែរ

បទប្បញ្ញត្តិនៃមាត្រា ៥២ (អំណាចរបស់តុលាការក្នុងការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្តចំពោះអំណាចក្នុងការបង្វែររបស់សាលាឧទ្ធរណ៍ ។

### មាត្រា ៥៩.- ការពន្លាតវិធានដល់តុលាការជាន់ខ្ពស់

វិធានដែលត្រូវអនុវត្តចំពោះសាលាដំបូង ត្រូវយកមកអនុវត្តចំពោះសាលាឧទ្ធរណ៍ និងតុលាការកំពូល លើកលែងតែវិធាននោះមានភាពផ្ទុយពីលក្ខណៈនៃវិធានដែលអនុវត្តនៅតុលាការជាន់ខ្ពស់ ។

## ជំពូកទី ១០
## ការបង្វែរ

### មាត្រា ៦០.- ការបង្វែរ

ការបង្វែរជាវិធានដែលអាចប្រើប្រាស់ក្នុងករណីអនីតិជនបានសារភាពថា បានប្រព្រឹត្តបទល្មើស ហើយដែលអាចជឿជាក់បានថាបានប្រព្រឹត្តបទល្មើសមែន ចេញពីដំណាក់កាលនីមួយៗ នៃនីតិវិធីតុលាការ ។

### មាត្រា ៦១.- អាជ្ញាធរទទួលបន្ទុកបង្វែរ

អាជ្ញាធរទទួលបន្ទុកបង្វែររួមមាន តំណាងអង្គការអយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះនៃសាលាដំបូង និងក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ ។

### មាត្រា ៦២.- គោលបំណងនៃការបង្វែរ

ការបង្វែរអនីតិជនមានគោលបំណងដូចខាងក្រោម៖

- លើកទឹកចិត្តអនីតិជនឲ្យទទួលស្គាល់កំហុស និងការខូចខាតដែលខ្លួនបានបង្កឡើង
- ជំរុញឲ្យមានការសះជារវាងជនរងគ្រោះជាមួយនឹងអនីតិជន
- លើកទឹកចិត្តឲ្យមានការជួសជុលការខូចខាត ឬសំណងជំងឺចិត្តដល់ជនរងគ្រោះ
- អប់រំ និងកែប្រែអាកប្បកិរិយារបស់អនីតិជន
- ឆ្លើយតបនឹងសេចក្តីត្រូវការផ្ទាល់របស់អនីតិជន ដើម្បីធ្វើសមាហរណកម្មទៅក្នុងគ្រួសារ ឬសហគមន៍ ឬសង្គមវិញ
- ចៀសវាងការមានស្លាកស្នាមអាក្រក់ក្នុងអារម្មណ៍ និងបញ្ចៀសការទទួលបាននូវបទពិសោធអាក្រក់នៃការប្រព្រឹត្តបទល្មើសពីជនដទៃក្នុងពេលអនុវត្តទោស និងចៀសវាងការប្រព្រឹត្តបទល្មើសសាជាថ្មី
- បង្ការការរើសអើងលើអនីតិជន និងចៀសវាងមានប្រវត្តិថាជាប់ទោសក្នុងបញ្ជីថ្កោលទោស ។

## មាត្រា ៦៣.- លក្ខខណ្ឌអប្បបរមានៃការបង្វែរ

ការបង្វែរត្រូវមានលក្ខខណ្ឌអប្បបរមាដូចខាងក្រោម ៖

ក- មានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ ឬបង្ហាញអំពីពិរុទ្ធភាពរបស់អនីតិជន ។

ខ- អនីតិជនសារភាពទទួលកំហុសដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ និងមានការសុំទោសជនរងគ្រោះ ។

គ- បទល្មើសដែលបានប្រព្រឹត្តជាបទលហុ ឬបទមជ្ឈិម ។

ឃ- អនីតិជនយល់ព្រមឲ្យធ្វើការបង្វែរ បន្ទាប់ពីបានទទួលការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬមេធាវីអំពីសិទ្ធិរបស់អនីតិជន និងពិចារណាផងដែរអំពីអានុភាព និងផលប៉ះពាល់នៅពេលអនុវត្តវិធានបង្វែរ ។

## មាត្រា ៦៤.- លក្ខណវិនិច្ឆ័យសម្រាប់បង្វែរ

ក្នុងករណីរឿងក្ដីបំពេញទៅតាមលក្ខខណ្ឌអប្បបរមានៃការបង្វែរ ដូចមានចែងនៅក្នុងមាត្រា ៦៣ (លក្ខខណ្ឌអប្បបរមានៃការបង្វែរ) នៃច្បាប់នេះ អាជ្ញាធរទទួលបន្ទុកបង្វែរ មុននឹងសម្រេចបង្វែរ ឬមិនបង្វែរ ត្រូវពិចារណាលើកត្តាដូចខាងក្រោម ៖

ក- កាលៈទេសៈនៃបទល្មើស ។

ខ- ស្ថានភាពនៃបទល្មើស ។

គ- បុគ្គលិកលក្ខណៈរបស់អនីតិជនដូចជា អាយុ កម្រិតយល់ដឹង បញ្ញា អត្តចរិត ។

ឃ- ការទទួលរងឥទ្ធិពលពីគ្រួសារ និងបរិយាកាសជុំវិញការរស់នៅរបស់អនីតិជន ។

ង- ព្យសនកម្មរបស់ជនរងគ្រោះ ។

ច- សុវត្ថិភាពរបស់ជនរងគ្រោះ សហគមន៍ និងសង្គម ។

## មាត្រា ៦៥.- វិធានការបង្វែរ

ក្នុងករណីដែលត្រូវបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរអាចសម្រេចជ្រើសរើសយកវិធានមួយ ឬច្រើនដូចខាងក្រោម សម្រាប់ឲ្យអនីតិជនបំពេញជាកាតព្វកិច្ច ៖

- ចំណុចមួយ ឬច្រើនដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌស្ដីពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ
- ទៅសាលារៀនឲ្យបានទៀងទាត់តាមផែនការកំណត់មិនលើសពី ៦ (ប្រាំមួយ) ខែ
- ចំណាយពេលវេលាជាក់លាក់ជាមួយក្រុមគ្រួសារមិនលើសពី ៦ (ប្រាំមួយ) ខែ
- តម្រូវឲ្យចូលរួមក្នុងការអប់រំ បណ្ដុះបណ្ដាលវិជ្ជាជីវៈក្នុងថិរវេលាមិនលើសពី ៦ (ប្រាំមួយ) ខែ

- ធ្វើការងារសហគមន៍ដោយមិនលើសពី ១០០ (មួយរយ) ម៉ោង ។ ការងារសហគមន៍នេះ សម្រាប់តែអនីតិជនដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ឡើងទៅ ហើយមានលក្ខណៈជាការងារបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ
- ចូលរួមក្នុងកម្មវិធីសហគមន៍ ឬមណ្ឌលដែលមានអត្ថប្រយោជន៍ សម្រាប់ជួយអនីតិជនមិនឲ្យប្រព្រឹត្តបទល្មើសសាជាថ្មី
- ឲ្យស្នាក់នៅទីកន្លែងណាមួយដោយកំណត់ពេលវេលាជាក់លាក់
- ជួសជុលសំណងការខូចខាតទៅជនរងគ្រោះ
- វិធានការសមស្របផ្សេងទៀតដែលបំពេញនូវគោលបំណងនៃការបង្វែរ ។

រាល់វិធានការបង្វែរដែលទាក់ទងនឹងការងារ ត្រូវអនុលោមតាមច្បាប់ស្តីពីការងារ និងអនុសញ្ញាអន្តរជាតិស្តីពីការងារដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ។

## មាត្រា ៦៦.– ការរៀបចំបង្កើតផែនការបង្វែរ

ក្រោយពីបានទទួលដីកាសម្រេចបង្វែរពីអាជ្ញាធរទទួលបន្ទុកបង្វែរ ភ្នាក់ងារសង្គមកិច្ចត្រូវរៀបចំបង្កើតផែនការបង្វែរ ។ ផែនការបង្វែរត្រូវសម្រេចក្នុងអំឡុងពេលមិនលើសពី ១ (មួយ) ខែ គិតពីថ្ងៃទទួលដំណឹងអំពីដីកាសម្រេចបង្វែរ លើកលែងតែមានស្ថានភាពពិសេសដែលមិនអាចជម្នះបាន ។

ក្នុងការបង្កើតផែនការបង្វែរជាឯកត្តបុគ្គលសម្រាប់អនីតិជនណាមួយ ភ្នាក់ងារសង្គមកិច្ចត្រូវពិចារណាទៅលើកត្តាដូចខាងក្រោម ៖

- ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងជនដទៃទៀតដែលទទួលរងផលប៉ះពាល់នៃអំពើល្មើស អំពីភាពសមស្របនៃផែនការបង្វែរដែលត្រូវបានស្នើឡើង
- សាវតារ វប្បធម៌ សាសនា និងភាសារបស់អនីតិជន
- កម្រិតសិក្សា សមត្ថភាពខាងបញ្ញា កាលៈទេសៈ និងស្ថានភាពគ្រួសាររបស់អនីតិជន
- សមាមាត្ររវាងផែនការដែលបានស្នើ ឬជ្រើសរើសចំពោះស្ថានភាពរបស់អនីតិជន ចរិតនៃបទល្មើស និងផលប្រយោជន៍សង្គម និង
- អាយុ និងតម្រូវការអភិវឌ្ឍរបស់អនីតិជន ។

ផែនការបង្វែរសម្រាប់អនីតិជនត្រូវ ៖

- ផ្តល់នូវអត្ថប្រយោជន៍សម្រាប់អនីតិជន
- ធ្វើឲ្យអនីតិជនយល់ពីផលប៉ះពាល់នៃអាកប្បកិរិយារបស់ខ្លួនចំពោះជនរងគ្រោះនៃបទល្មើស និងជនដទៃទៀត
- កែតម្រូវនូវកំហុសឆ្គងដែលបង្កឡើងដោយអំពើល្មើស ហើយអាចរួមបញ្ចូលទាំងសំណងការខូចខាត

- អនុវត្តនៅទីកន្លែងដែលអនីតិជនអាចអនុវត្តបាន
- ចៀសវាងការធ្វើអាជីវកម្មកេងប្រវ័ញ្ច ឬបណ្តាលឲ្យអន្តរាយ ឬធ្វើឲ្យមានគ្រោះថ្នាក់ដល់សុខភាពផ្លូវចិត្ត ឬផ្លូវកាយរបស់អនីតិជន
- មិនប៉ះពាល់ជាអវិជ្ជមានដល់ការសិក្សារបស់អនីតិជន បើអនីតិជនកំពុងសិក្សា និង
- មិនមានការពាក់ព័ន្ធនឹងការដកហូតសេរីភាព នៅក្នុងទម្រង់នៃការដាក់ទោសណាមួយឡើយ ។

## មាត្រា ៦៧.- និទ្ទេសដែលត្រូវចុះនៅក្នុងផែនការបង្វែរ

ផែនការបង្វែរត្រូវមាននិទ្ទេសដូចខាងក្រោម ៖

- វិធានការបង្វែរណាមួយដូចមានចែងក្នុងមាត្រា ៦៥ (វិធានការបង្វែរ) នៃច្បាប់នេះ និងរយៈពេលនៃការអនុវត្តវិធានការបង្វែរ
- បញ្ជាក់លម្អិតអំពីសេវា និងជំនួយដែលត្រូវផ្តល់ឲ្យអនីតិជន
- បញ្ជាក់ឲ្យច្បាស់ពីបុគ្គល ឬអង្គការដែលផ្តល់សេវា និងជំនួយទាំងនោះ
- បញ្ជាក់ពីការទទួលខុសត្រូវរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់
- បញ្ជាក់ពីគោលបំណងផ្ទាល់ខ្លួនរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់
- បញ្ចូលកម្មវិធីផ្សេងទៀតទាក់ទងនឹងការអប់រំ ការបម្រើការងារ ការកម្សាន្ត និងសុខុមាលភាពរបស់អនីតិជនទៅតាមស្ថានភាពដែលពាក់ព័ន្ធ
- បញ្ជាក់ពីអាជ្ញាធរ ឬជនសមស្របដែលទទួលបន្ទុកអនុវត្តផែនការបង្វែរ ។ អាជ្ញាធរ ឬជនសមស្របទាំងនេះអាចជានគរបាល បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គ្រូបង្រៀន ឬសមាជិកសមស្របណាមួយនៃសហគមន៍
- បញ្ជាក់ពីភ្នាក់ងារសង្គមកិច្ចដែលទទួលបន្ទុកត្រួតពិនិត្យតាមដាន និងអនុវត្តផែនការបង្វែរ
- បញ្ជាក់អំពីការយល់ព្រមរបស់អនីតិជនចំពោះផែនការបង្វែរ ។

ផែនការបង្វែរត្រូវចុះ ៖

- អត្តសញ្ញាណ និងហត្ថលេខារបស់ភ្នាក់ងារសង្គមកិច្ច
- អត្តសញ្ញាណ និងស្នាមម្រាមដៃរបស់អនីតិជន
- អត្តសញ្ញាណ ហត្ថលេខា ឬស្នាមម្រាមដៃរបស់បុគ្គលដែលពាក់ព័ន្ធ ។

ច្បាប់ចម្លងនៃផែនការបង្វែរត្រូវរក្សាទុកជាការសម្ងាត់នៅការិយាល័យរបស់ភ្នាក់ងារសង្គមកិច្ច ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## មាត្រា ៦៨.- ការសម្រេចអំពីផែនការបង្វែរដោយអាជ្ញាធរទទួលបន្ទុកបង្វែរ

ភ្នាក់ងារសង្គមកិច្ច ត្រូវបញ្ជូនផែនការបង្វែរទៅអាជ្ញាធរទទួលបន្ទុកបង្វែរ ដើម្បីពិនិត្យ និងសម្រេច ។

ករណីអាជ្ញាធរទទួលបន្ទុកបង្វែរយល់ស្របចំពោះផែនការបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវចេញដីកាសម្រេចឲ្យអនុវត្តផែនការបង្វែរ ។

ករណីអាជ្ញាធរទទួលបន្ទុកបង្វែរមិនយល់ស្រប ចំពោះផែនការបង្វែរដែលរៀបចំដោយភ្នាក់ងារសង្គមកិច្ច អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចរៀបចំឡើងវិញនូវផែនការបង្វែរថ្មី ។ ផែនការបង្វែរត្រូវសម្រេចក្នុងអំឡុងពេលមិនលើសពី ១ (មួយ) ខែ គិតពីថ្ងៃទទួលដំណឹងអំពីដីកាបង្គាប់ លើកលែងតែមានស្ថានភាពពិសេសដែលមិនអាចជម្នះបាន ។

## មាត្រា ៦៩.- ការអនុវត្តផែនការបង្វែរ

ភ្នាក់ងារសង្គមកិច្ច និងបុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវជានាប់រងអនុវត្តសេចក្តីសម្រេច និងផែនការបង្វែររបស់អាជ្ញាធរទទួលបន្ទុកបង្វែរ ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើអនីតិជនដែលត្រូវអនុវត្តផែនការបង្វែរ ។

បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលជោគជ័យ ឬបរាជ័យ ឬឧបសគ្គដែលកើតមាន នៅក្នុងការអនុវត្តផែនការខាងលើទៅភ្នាក់ងារសង្គមកិច្ច ។ ភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនរបាយការណ៍នោះរួមទាំងយោបល់របស់ខ្លួន ទៅអាជ្ញាធរទទួលបន្ទុកបង្វែរ ហើយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ។

## មាត្រា ៧០.- ការកែប្រែវិធានការបង្វែរ

ក្នុងអំឡុងពេលអនុវត្តផែនការបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរអាចកែប្រែវិធានការបង្វែរបានតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមការស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ចស្របទៅតាមស្ថានភាពជាក់ស្តែង ដើម្បីជាប្រយោជន៍របស់អនីតិជន ។

អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃបានទទួលពាក្យស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ច ។ ក្នុងករណីអាជ្ញាធរទទួលបន្ទុកបង្វែរមិនបានសម្រេចក្នុងថិរវេលានេះ ត្រូវចាត់ទុកថាយល់ស្របតាមការស្នើសុំ ។

ការកែប្រែផែនការបង្វែរ មិនចាត់ទុកថាជាការបរាជ័យក្នុងការអនុវត្តផែនការបង្វែរឡើយ ។

## មាត្រា ៧១.- បរាជ័យក្នុងការអនុវត្តវិធានការបង្វែរ

បរាជ័យក្នុងការអនុវត្តវិធានការបង្វែរ សំដៅដល់ករណីដែលអនីតិជនមិនបានគោរពតាមកាតព្វកិច្ចនៅក្នុងវិធានការបង្វែរ ឬនៅក្នុងវិធានការបង្វែរដែលត្រូវបានកែប្រែ ។

ភ្នាក់ងារសង្គមកិច្ចត្រូវផ្តល់របាយការណ៍ស្តីពី លទ្ធផលនៃការមិនគោរពកាតព្វកិច្ចដែលបាន កំណត់នៅក្នុងវិធានការបង្វែរ ឬនៅក្នុងវិធានការបង្វែរដែលត្រូវបានកែប្រែ រួមទាំងយោបល់ជូនទៅអាជ្ញាធរទទួលបន្ទុកបង្វែរដើម្បីសម្រេច ដោយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ។

ក្រោយពិនិត្យរបាយការណ៍ខាងលើ អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវកោះហៅអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ច បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ និងមេធាវីរបស់អនីតិជន ប្រសិនបើមាន ឲ្យចូលមកបង្ហាញខ្លួនក្នុងថិរវេលា មិនលើសពី ១៥ (ដប់ប្រាំ) ថ្ងៃ ។

អាជ្ញាធរទទួលបន្ទុកបង្វែរ ត្រូវសាកសួរពីមូលហេតុដែលអនីតិជននោះមិនគោរពតាមវិធានការបង្វែរ ។

ក្រោយពីបានពិចារណាអំពីទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច អាជ្ញាធរទទួលបន្ទុកបង្វែរអាចចេញដីកាបង្វែរថ្មី ឬបន្តចាត់ការតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

បទប្បញ្ញត្តិនៃមាត្រា ៦៦ (ការរៀបចំបង្កើតផែនការបង្វែរ) ដល់ មាត្រា ៧០ (ការកែប្រែវិធានការបង្វែរ)ខាងលើនេះ ត្រូវយកមកអនុវត្តក្នុងករណីដែលអាជ្ញាធរទទួលបន្ទុកបង្វែរចេញដីកាបង្វែរថ្មី ។

ក្នុងករណីអនីតិជនមិនបង្ហាញខ្លួនតាមការកោះហៅដោយគ្មានមូលហេតុសមស្រប អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវបន្តចាត់ការបន្តតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី ១១
## ការដោះលែងដោយមានលក្ខខណ្ឌ

### មាត្រា ៧២.– ការដោះលែងដោយមានលក្ខខណ្ឌ

ការដោះលែងដោយមានលក្ខខណ្ឌ អាចត្រូវផ្តល់ឲ្យដល់ទណ្ឌិតជាអនីតិជនដែលទទួលរងទោសក្នុងមណ្ឌលយុវនីតិសម្បទា ៖

- ចំនួនមួយភាគបីនៃទោស ប្រសិនបើទោសតិចជាង ឬស្មើ ១ (មួយ) ឆ្នាំ
- ចំនួនពាក់កណ្តាលនៃទោស ក្នុងករណីផ្សេងទៀត ។

### មាត្រា ៧៣.– បុគ្គលដែលមានសិទ្ធិស្នើសុំដោះលែងដោយមានលក្ខខណ្ឌ

បុគ្គលដែលមានសិទ្ធិស្នើសុំដោះលែងអនីតិជនដោយមានលក្ខខណ្ឌ រួមមាន ៖

- ទណ្ឌិតដែលជាអនីតិជន ឬមេធាវីរបស់ជននោះ
- អ្នកតំណាងដែលច្បាប់បានកំណត់
- ប្រធានមណ្ឌលយុវនីតិសម្បទា

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ឧបសម្ព័ន្ធទី ៥

# ករណីសិក្សា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

- លេខ ២៩៦៥ "ម"
  ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ២០២០
- សំណុំរឿងព្រហ្មទណ្ឌលេខ ២០៥០
  ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩
- សំណុំរឿងស៊ើបសួរលេខ២០៤០
  ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩
- សំណុំរឿងជំនុំជម្រះលេខ៤២១២
  ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ០៨ ៣០ នាទី ព្រឹក នៅសាលសវនាការទី៤ ៖

### ចៅក្រមជំនុំជម្រះ

លោក អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

### តំណាងអយ្យការ

លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោកស្រី ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ២០៥០ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ៖

ឈ្មោះ ភេទប្រុស អាយុ៣៣ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ ប្រធានក្រុមហ៊ុន មានទីកន្លែងកំណើតនៅភូមិ១ សង្កាត់អូរត្រេះ ខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ មានអាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ២១ ផ្លូវលេខ២៧១ សង្កាត់ស្ទឹងមានជ័យ១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ "ស្លាប់" ម្ដាយឈ្មោះ "រស់" ប្រពន្ធឈ្មោះ មានកូន ០២នាក់ ជានីតិជន ទោសពីមុនគ្មាន (ក្រៅឃុំ)។

- ដីកាសម្រេចមិនឃុំខ្លួនលេខ ៦២០៩ "ហ" ដ.ព.ស ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩។
- ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៦២១០ "ហ" ដ.ព.ស ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ។

ត្រូវបានចោទប្រកាន់ពីបទ **ឆបោក** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ភេទប្រុស មានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ១៣០អឺ០ ផ្លូវលេខ ១០៨ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។
- លោក លោក លោក
  ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី។
- លោក ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។៚

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**បន្ទប់ស៊ើបសួរ "ម"**
**លេខ៖** 28315 **"ម" ដដ**

# ដីកាលើកលែងចោទប្រកាន់

យើង អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ និងជាចៅក្រមស៊ើបសួរ ដោយមានលោកស្រី ជាក្រឡាបញ្ជី។

- បានឃើញ បញ្ញត្តិមាត្រា ២៤៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១៨៤៦ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១។
- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៤២២ អ.យ.ជ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ សំណុំរឿងស៊ើបសួរលេខ ១៣៨៤ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១។
- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២០៦០ អ.យ.ជ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលទាក់ទងនឹងជនត្រូវចោទដូចខាងក្រោម៖

ឈ្មោះ ហៅ ភេទស្រី អាយុ ២០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ និស្សិត ទីកន្លែងកំណើត សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ១៤៦ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ "រស់" ម្ដាយឈ្មោះ "រស់" ជានីតិជន ទោសពីមុនគ្មាន ដែលត្រូវបានចោទប្រកាន់ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្លូវ ១៣៨ កែងផ្លូវ ២៥៩ ស្ថិតនៅក្រុម ២៨ ភូមិ ១០ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។ (ក្រៅឃុំ)

- ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំលេខ ២២៩៧ "ម" ដពស ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១។
- ដីកាបង្គាប់ឱ្យដោះលែងលេខ ៣២៧២ "ម" ដឃដ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១។

- ជនរងគ្រោះ ឈ្មោះ ភេទប្រុស អាយុ ៥៩ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ៧៥ ផ្លូវ២១៧ ភូមិទ្រា សង្កាត់ស្ទឹងមានជ័យទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

- មេធាវី ឈ្មោះ អត្តលេខ ៧៧៥ មេធាវី ឈ្មោះ មេធាវី ឈ្មោះ មេធាវី ឈ្មោះ អត្តលេខ ៨៥៦ មេធាវី ឈ្មោះ អត្តលេខ ២១៦៦T មេធាវី ឈ្មោះ និង មេធាវី ឈ្មោះ ជាសហមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ។
- មេធាវី ឈ្មោះ អត្តលេខ ៤២២ មេធាវី ឈ្មោះ ពុធ ធាវី និងមេធាវី ឈ្មោះ ជាសហមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ម"

លេខ ៧២៧៤ "ម" ដ.ឃ.ដ

# ដីកាបង្គាប់ឲ្យដោះលែង

យើង [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ និងជាចៅក្រមស៊ើបសួរ។

- បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧។
- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១៨៤៦ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ១៤២២ អ.ឃ.ផ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ សំណុំរឿងស៊ើបសួរលេខ ១៣៨៤ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ ដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ២២៧៨ "ម".ដ.ព.ស ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១។
- បានឃើញ ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ៣២៣៩ "ម".ដ.ឃ.ដ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១។
- បានឃើញ ពាក្យសុំឲ្យដោះលែងនៅក្រៅឃុំចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ របស់មេធាវី មាស ស៊ីថន មេធាវី មាស សោភា មេធាវី ម៉ម ចាន់ណែត មេធាវី អ៊ុំ រតនា និង មេធាវី សួស វិទ្យា។
- បានឃើញ ដីកាបញ្ជូនឲ្យឆ្លើយលេខ ២៦២ "ម" ព្រ.ទ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញដីកាសម្រេចអនុញ្ញាតឲ្យនៅក្រៅឃុំបណ្ដោះអាសន្នលេខ២២៥៧..."ម"ដ.ព.ស ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## ហេតុដូច្នេះសម្រេច

បង្គាប់មកលោកប្រធានមណ្ឌលអប់រំកែប្រែទី២ "ម២" ឲ្យដោះលែងឈ្មោះ [redacted] ហៅ ឈូប៊ី ភេទស្រី អាយុ២០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរ និស្សិត ទីកន្លែងកំណើតនៅសង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ១៤៦ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្ដាយឈ្មោះ [redacted] "រស់" នៅលីវ ជានីតិជន ទោសពីមុនគ្មាន ដែលត្រូវបានចោទប្រកាន់ ពីបទ ៖ លួចមានស្ថានទម្ងន់ទោស ជាបទល្មើសព្រហ្មទណ្ឌ និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ជាបន្ទាន់ បើជននេះមិនជាប់ពាក់ព័ន្ធនឹងដីកាឃុំ ខ្លួននៃបទល្មើសផ្សេងទៀតទេនោះ។

ថ្ងៃព្រហស្បតិ៍ ២កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ២០២១

**ចៅក្រមស៊ើបសួរ**

[redacted]

មន្ទីរស៊ើបសួរ "ម"
លេខ ២៧.៩៣ ជ.ព.ស

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ដីកាសម្រេចដោះលែង**
**ឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន**

យើង [redacted] ចៅក្រមស៊ើបសួរ និងជាអនុប្រធានសាលាដំបូងរាជធានីភ្នំពេញ។

អមដោយលោកស្រី [redacted] ជាក្រឡាបញ្ជី។

- បានឃើញ មាត្រា ២១៧ និងមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។
- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១៨៤៦ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ១៤២២ អ.យ.ជ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ សំណុំរឿងស៊ើបសួរលេខ ១៣៨៤ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញ ពាក្យសុំឲ្យដោះលែងនៅក្រៅឃុំចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ របស់មេធាវី [redacted] មេធាវី [redacted] មេធាវី [redacted] មេធាវី [redacted] និង មេធាវី [redacted] ។
- បានឃើញ ដីកាបញ្ជូនឲ្យឆ្លើយលេខ ២៦២ "ម" ព្រ.ទ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញ កំណត់ហេតុសួរយកចម្លើយ ធ្វើនៅថ្ងៃទី១០ ទី១១ ទី១២ ខែឧសភា ឆ្នាំ២០២១ របស់ជនត្រូវចោទ ដែលមានឈ្មោះ [redacted] ហៅ [redacted] ភេទស្រី អាយុ២០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរ និស្សិត ទីកន្លែងកំណើតកើតនៅសង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ១៤៦ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្ដាយឈ្មោះ [redacted] "រស់" នៅលីវ ជា នីតិជន ទោសពីមុនគ្មាន។

ឃាត់ខ្លួនថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០២១។

ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទ៖ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្ទះលេខ ១៣៨ កែងផ្លូវលេខ២៥៩ ក្រុមទី២៨ ភូមិ១០ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ ជាបទល្មើសព្រហ្មទណ្ឌ និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្ម នៃព្រះរាជាណាចក្រកម្ពុជា។

**ក្រោយពីបានពិនិត្យលើសំណុំរឿង និងពាក្យសុំចប់សព្វគ្រប់**

- ឃើញថា ដីកាបញ្ជូនឲ្យឆ្លើយលេខ ២៦២ "ម" ព្រ.ទ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ តំណាងអយ្យការបានឆ្លើយឯកភាពក្នុងការឲ្យជនត្រូវចោទបាននៅក្រៅឃុំបណ្ដោះអាសន្ន តាមការស្នើសុំរបស់មេធាវីការពារសិទ្ធិឲ្យជនត្រូវចោទ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ..........
ចុះថ្ងៃទី......ខែ ឧសភា ឆ្នាំ ២០១៦
លេខ............................អ.យ.ណ

## ដីកាសន្និដ្ឋានស្ថាពរ

**យើង** [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ............ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ............ អ.យ.ណ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ សំណុំរឿងស៊ើបសួរលេខ .............. ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ លិខិតជូនដំណឹង ស្តីពីការបិទការស៊ើបសួរលេខ ..............ព្រ.ទ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦។

បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យលេខ ..............ព្រ.ទ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

### ក្រោយពីបានពិនិត្យឯកសារខាងលើ

**ឃើញថា៖**

១-ឈ្មោះ កក ភេទប្រុស។

ត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ **បើកកន្លែងលេងល្បែងស៊ីសងដោយខុសច្បាប់** ប្រព្រឹត្តនៅចំណុចក្នុងផ្ទះជួល ផ្លូវបេតុង ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ តាមមាត្រា**៥** នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

២-ឈ្មោះ **ខខខខ** ភេទស្រី អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបរនៅផ្ទះ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើត ភូមិបឹងក្រោម ឃុំខ្ពប់អាទាវ ស្រុកលើកដែក ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ន ផ្ទះជួល ផ្លូវបេតុង សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ **នននន** (រ) ម្តាយឈ្មោះ **ហាហាហាហា** (រ) ប្តីឈ្មោះ **ទទទទទ** (លែងលះ) មានកូន ០១នាក់ ជានីតិជន ទោសពីមុនគ្មាន។ **(ក្នុងឃុំ)**

ត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ **ភ្នាក់ងារស៊ីសងដោយខុសច្បាប់** ប្រព្រឹត្តនៅចំណុចក្នុងផ្ទះជួល ផ្លូវបេតុង ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពី ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ តាមមាត្រា**៥** នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

សាលាដំបូងរាជធានីភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ដីកាបង្គាប់ឲ្យឃុំខ្លួន

លេខ៖ ....2384....ក១.ដ.ឃ.ដ

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

បានឃើញមាត្រា ២០៦ , ២១៩, ២២០,មាត្រា២២២ និងពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១៧៥៧ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ១០០៧ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ១០១២ អ.យ.ម ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨ ដែលបាន បើកការស៊ើបសួរលើ៖

នាមត្រកូល នាមខ្លួន ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ មុខរបរ រកស៊ីគ្រឿងញៀន ទីកន្លែងកំណើត នៅភូមិល្វាង ឃុំតាំងម្លូង ស្រុកបាទី ខេត្តតាកែវ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះជួល ផ្លូវលំ ភូមិចោមចៅ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រ) ម្តាយឈ្មោះ (ស) ប្រពន្ធឈ្មោះ គ្មានកូន ជា-នីតិជន។

ប្រវត្តិនៃការផ្តន្ទាទោសតុលាការ ៖ ធ្លាប់ជាប់មណ្ឌលកែប្រែ ពីបទ ៖ ប្រើប្រាស់គ្រឿងញៀន ។

ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទ **ចោរកម្ម ,អំពើឃោរឃៅ និង ជួញដូរ ,ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចបន្ទប់ជួលគ្មាន ផ្លូវលំ ភូមិចោមចៅ២ សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ បទល្មើសដែលមានបញ្ញត្តិ និងឲ្យផ្តន្ទាទោសតាមមាត្រា ២១០ នៃក្រមព្រហ្មទណ្ឌ និង មាត្រា ៤០ ,មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-បានឃើញ ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ....1625.....ក១.ដ.ព.ស ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨។

## បង្គាប់

១.ឲ្យភ្នាក់ងារមានសមត្ថកិច្ច នៃកងកម្លាំងសាធារណៈ ធ្វើការនាំខ្លួនជនត្រូវចោទដែលមានឈ្មោះ ភេទប្រុស អាយុ៣៨ឆ្នាំ ទៅមណ្ឌលអប់រំកែប្រែទី១ ដោយអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់។

២.ឲ្យលោកប្រធានមណ្ឌលអប់រំកែប្រែទី១ ទទួលឃុំខ្លួនជននេះរហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ។

៣.ឲ្យគ្រប់ភ្នាក់ងារនៃកម្លាំងសាធារណៈទាំងអស់ សហការអនុវត្តឲ្យបានល្អនៅពេលដីកានេះត្រូវបានបង្ហាញក្នុងករណីចាំបាច់។

ថ្ងៃសុក្រ ០៧កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨

**ចៅក្រមស៊ើបសួរ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ ៦៣៧១
ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៩
លេខ ៤៣០០...... អ.យ.ក

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

យើង [redacted] តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ **៦៣៧១** ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញរបាយការណ៍លេខ **៨៥៥/១៩** រ.ប.ក.នបភក២ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៩ របស់នាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន នៃក្រសួងមហាផ្ទៃ ។

-បានឃើញលិខិតលេខ **១៨១៨ កយ រប/១៩** ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៩ របស់ក្រសួងយុត្តិធម៌ ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា មានតម្រុយសន្មតបានថា:

ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៤៩ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កាន់លិខិតឆ្លងដែនលេខ [redacted] ទីកន្លែងកំណើតសង្កាត់លេខ២ ក្រុងភ្នំពេញ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ៥៧៦ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "ស្លាប់" ប្រពន្ធឈ្មោះ [redacted] "រស់" មានកូន០៣នាក់ ជានីតិជន ។

**បានប្រព្រឹត្តដូចតទៅ[1]៖** នាយប់ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៩ ទណ្ឌិតឈ្មោះ [redacted] បាននិយាយក្នុងកិច្ចសម្ភាសន៍ជាមួយលោក [redacted] នៃ [redacted] ដោយបានប្រមាថទៅលើ [redacted] ដែលមានខ្លឹមសារថា "[redacted] ។ ពាក្យសម្តីរបស់ទណ្ឌិតឈ្មោះ [redacted] ដែលបានផ្សព្វផ្សាយជាសាធារណៈនេះ បានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ [redacted] ណាចក្រកម្ពុជាគោរពស្រឡាញ់ស្មើជីវិត ។

---

[1] សេចក្តីសង្ខេបអង្គហេតុ



អាសយដ្ឋានៈ អគារលេខ ២៥ ផ្លូវលេខ ២១៧ សង្កាត់វាលវង់ ខណ្ឌ ៧ មករា ភ្នំពេញ
Adress: #25, Street 217, Sangkat Vealvong, Khan 7makara, Phnom Penh, Cambodia.
ទូរសារ-ទូរស័ព្ទៈ (៨៥៥)-២៣ ៨៨ ២០ ៥៩
Fax-Phone : (855) - 23 88 20 59

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
មជ្ឈយុត្តិធ...
ការិយាល័យប្រឆាំងជួញដូរមនុស្ស
សំណុំរឿងលេខ: .........
លេខ: ...0...

**កំណត់ហេតុចាប់យកវត្ថុតាង**

ឆ្នាំពីរពាន់............ខែ.........ថ្ងៃទី..........វេលាម៉ោង...........

-យោង:មាត្រា៨១, ៨២, ១០៧, ១០៨, ១១៣ និង មាត្រា ១៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

យើង. ឋានៈ.. ............

ជាមន្ត្រីនគរបាលយុត្តិធម៌អង្គភាព............ ។

ដោយបានការអនុញ្ញាតពីមេបញ្ជាការកងរាជអាវុធហត្ថ. ...........បាន ធ្វើប្រតិបត្តិការ ប្រកប ដោយឯកសណ្ឋានត្រឹមត្រូវជំនួយដោយ៖

១-លោក .... ... ..................................

២-លោក ..... ..................................

ដោយមានការអនុញ្ញាតពីលោក.. ........ឋានៈ.. ..

នៃសាលាដំបូង.........................................

□ដោយផ្ទាល់មាត់

□លាយលក្ខណ៍អក្សរ

នៅ.........................បានធ្វើកំណត់ហេតុចាប់យកវត្ថុតាងពី.............

-ឈ្មោះ...... .................ឈ្មោះហៅក្រៅ..... .........ភេទ.......អាយុ...38....ឆ្នាំ

-ថ្ងៃខែឆ្នាំកំណើត...08....09.....1980..........ជនជាតិ.........សញ្ជាតិ........សាសនា.........

-ទីកន្លែងកំណើត ...................................

-ទីលំនៅបច្ចុប្បន្ន ...................................

-មុខរបរ.....................អង្គភាព.........................

-អត្តសញ្ញាណប័ណ្ណលេខ... ...100205390..........ចុះថ្ងៃទី......................ផុតកំណត់ថ្ងៃទី.....................

-លិខិតឆ្លងដែនលេខ.....................................ចុះថ្ងៃទី.........................ផុតកំណត់ថ្ងៃទី.........................